ឆ្នាំ ទី ៤

ខ្សែ ទី ១

លេខពិសេសទី ៦-៧

ខែមិថុនា-កក្កដា

ទស្សនាវដ្ដី

# កម្ពុជសុរិយា

ផ្សាយពេញ

សាសនា, អក្សរសាស្ត្រ, ប្រវត្តិសាស្ត្រ

# ឆដ្ឋសង្គាយនា

ព. ស. ២៤៩៧ — គ. ស. ១៩៥៤




មហាបាសាណគុហា ដ៏ប្រជុំធ្វើឆដ្ឋសង្គាយនា

( មើលពីក្រោយចំរូង )

រោងពុម្ព ពាក លេខ ០១១ វិថីព្រៃនគរ ភ្នំពេញ



ព្រះអរហន្តជាតិភូមា ព្រះនាម "វេភូ" គង់ព្រះជន្មនៅសព្វថ្ងៃ



ព្រះអគ្គមហាបណ្ឌិត ភទន្ត សោភណៈ

ជាបុច្ឆកៈ

(ព្រះថេរៈអង្គនេះ ប្រជាជនជាតិភូមា ជឿជាក់ថាជាអនាគាមីបុគ្គល)



ព្រះតិបិដកធរធម្មភណ្ឌាគារិកវិចិត្តសារាភិវំស

ជាវិសជ្ជកៈ

(ព្រះថេរៈអង្គនេះ ចេះចាំព្រះត្រៃបិដកទាំងបីសូត្រមាត់ទទេបានសព្វគ្រប់)

P.K - 27
R-624-9-54
1754-(6.7)



# សម្ភាសន៍



របស់សមាគមមិត្តសាលាបាលីនឹងលោកព្រះគ្រូសង្ឃសត្ថា ប៉ុណ្ណ-សុភាព(ធម្មាភោ) អំពីមហាសន្និបាតឆដ្ឋសង្គាយនា នៅទីក្រុងរ៉ង្គូន ប្រទេសភូមា ។



កាលពីថ្ងៃទី ២២ ខែមិថុនា គ.ស. ១៩៥៤ សមាគមមិត្តសាលាបាលីបានចាត់លោកមហាប៊ិច-ហាត (យោគក្ស័ត្រ) ឲ្យធ្វើជាអ្នកតំណាង ដើម្បីទៅសុំធ្វើសម្ភាសន៍គន់សំណាក់សម្តេចព្រះមហាសុមេធាធិបតី (ជ.ណា. ជោតញ្ញាណោ)សង្ឃនាយកគណៈមហានិកាយ ប្រធាននៃគណៈប្រតិភូកម្ពុជរដ្ឋ សម្រាប់មហាសន្និបាតឆដ្ឋសង្គាយនានៅទីក្រុងរ៉ង្គូន ប្រទេសភូមា ប៉ុន្តែដោយសម្តេចមានរវល់ដោយសង្ឃកិច្ចច្រើនលើសលុបពុំអាចអនុញ្ញាតឲ្យអ្នកតំណាងយើងធ្វើសម្ភាសន៍បាន សម្តេចក៏បានប្រគល់ភារៈដល់លោកព្រះគ្រូសង្ឃសត្ថា ប៉.ស. (ធម្មាភោ) ដែលជាសមាជិកគណៈប្រតិភូឲ្យធ្វើយតបសំនួរនៃអ្នកតំណាងយើង ។ សមាគមមិត្តសាលាបាលី សូមសម្តែងអំណរយ៉ាងក្រៃលែងចំពោះលោកព្រះគ្រូសង្ឃសត្ថា ប៉.ស. (ធម្មាភោ) ដែលបានចៀសឱកាសធ្វើយជាច្រើនវេលា តបសំនួរនៃអ្នកតំណាងរបស់យើងនេះ នៅក្នុងកុដិជាលំនៅរបស់លោក ។

ប៊ិច-ហាត.- សូមព្រះតេជព្រះគុណ មេត្តាពណ៌នាដោយសង្ខេបអំពីដំណើរដែលគណៈប្រតិភូយើងបានទៅកាន់ប្រទេសភូមា ដើម្បីរួមប្រជុំក្នុងពិធីឆដ្ឋសង្គាយនា នៅទីក្រុងរ៉ង្គូន តើមានព្រឹត្តិការណ៍យ៉ាងណាខ្លះ?

ព្រះគ្រូសង្ឃសត្ថា ប៉.ស. ធម្មាភោ:- សូមលោកជ្រាបថា ដោយមានសេចក្តីនិមន្តនឹងសេចក្តីអញ្ជើញអំពីរដ្ឋាភិបាល នឹងពុទ្ធសាសនសភានៃសហភាពប្រទេសភូមា ព្រះរាជរដ្ឋាភិបាលបានចាត់ប្រតិភូទៅរួមប្រជុំធ្វើឆដ្ឋសង្គាយនានៅទីក្រុងរ៉ង្គូនប្រទេសភូមានោះពីររូប គឺសម្តេចព្រះមហាសុមេធាធិបតី (ជ.ណា. ជោតញ្ញាណោ)

សង្ឃនាយកគណៈមហានិកាយជាប្រធាន និងអាត្មាព្រះគ្រូសង្ឃសត្ថា ប៉.ស៊ុក្លាដ(ធម្មាភោមា)ជាសមាជិកក្រៅពី
នោះមានព្រះថេរៈ៧រូបដែលនិមន្តទៅជាមួយសម្ដេចនិងសោហ៊ុយផ្ទាល់ខ្លួនរបស់លោកគឺ ព្រះឧបាលិវង្ស ស.ហាយ
(សុវណ្ណស្សរោ), ព្រះទេពសត្ថា គា.គូ (បទុមគ្គលោ)ព្រះធម្មវង្សាធិបតី ឆ.អ៊ុម (ធម្មជោតោ) មេគណ
ខែត្រកំពង់ធំ), ព្រះវិន័យធរអនុគណ ឃ.ញឹម (ធម្មសុភោ), ភិក្ខុ អ៊ូ ខេមាចារ(ជាតិភូមា), ព្រះមហា
ប៉.ម៉ៅ (ឥន្ទប្បញ្ញោ), និងព្រះមហា គា.ស៊ុខ (ធម្មទីបោ) ។ រាជគ្រហស្ថមានឧបាសក ៣ នាក់គឺៈ លោក
ផ៉ោ-ហ៊ុង ១ ម៉ោងចាំង (ជាតិភូមា) ១ , អ្នកមហា ញូង ផាន ១ និងឧបាសិកា ៥ នាក់គឺ ឧបាសិកា
ស៊ុន-អៀម ១ ម៉ែ-មាលី ១ អ៊ុក-ហ៊ុង-ផោង ១ លេខា ១ ឃុនស៊ី(ជាតិភូមា) ១ ។

យើងទាំងអស់គ្នា បានចេញដំណើរពីក្រុងភ្នំពេញ(ស្ថានីយអាកាសយានពោធិចិនតុង)ទៅនៅថ្ងៃ ៣ ៗ ១០ ៦ ឆ្នាំមមីឆស័ក ព.ស. ២៤៩៧ ត្រូវនឹងថ្ងៃទី ១១ ខែឧសភា គ.ស. ១៩៥៤ វេលាម៉ោង១០ នឹង ៣០ នាទី តាមអាកាសយានអែរវៀតណាម ប៉ុន្តែដោយយន្តហោះមានភារៈធ្ងន់ពេក យើងមិនអាចទៅទាំងអស់គ្នា ព្រមទាំងមិនអាចយកអីវ៉ាន់ទៅទាំងអស់បាន ហេតុនោះទើបលោក ផ៉ោ-ហ៊ុង, ម៉ោងចាំង និងឧបាសិកា ឃុនស៊ី ត្រូវបង្អង់ខានចាំចេញដំណើរទៅតាមក្រោយ ទាំងគ្រឿងគោមជាង ១០០ ខ្សែ ដែលសម្ដេចចាត់ចែងឲ្យយកទៅបូលបុណ្យក្នុងឱកាសនោះក៏ត្រូវអាក់ខាន រង់ចាំយកទៅពេលក្រោយដែរ ។ យន្តហោះបើកអស់រយៈកាលមួយម៉ោងក៏បានទៅដល់ស្ថានីយអាកាសយានសៀមរាប ; ក្រោយដែលបានចុះឈប់សម្រាកនៅទីនោះចំនួន ៣០ នាទី យន្តហោះដដែលនោះ ក៏បន្តដំណើរទៅក្រុងបាងកក ; យើងទៅដល់ស្ថានីយអាកាសយានឈ្មោះ ដនមឿង នៅម៉ោង១៣,៤៥ នាទី (ម៉ោង ១២,៤៥ នាទីម៉ោងប្រទេសថៃ) ។

នៅទីនោះ ឯ.ឧ. ងី-គីមសួ អគ្គរាជទូតប្រទេសខ្មែរប្រចាំប្រទេសថៃ និងសហការីរបស់លោក និងអគ្គរាជទូតភូមាប្រចាំប្រទេសថៃព្រមទាំងព្រះសង្ឃនិងឧបាសកឧបាសិកាជាតិខ្មែរ-ថៃខ្លះនៅក្រុងបាងកក បានមករង់ចាំទទួល នាំគណៈប្រតិភូខ្មែរទៅសំណាក់អាស្រ័យនៅវត្ត តិស្សារុក្ខារាម(ហៅវត្ត ចាងក៉ាងឌិត) ព្រោះយើងមានគ្នាច្រើន, សម្ដេចសព្វព្រះទ័យនិងទៅសំណាក់នៅវត្តនោះ ។

លុះដល់ថ្ងៃសុក្រ ឧបាសកឧបាសិកាទាំង៣រូបដែលខកខានដំណើរពុំបានទៅជាមួយនឹងយើង ក៏បានទៅជួបជុំគ្នាទាំងអស់ព្រមទាំងអីវ៉ាន់ ។ សម្ដេចបានសុំនិមន្តព្រះវីរៈធម្មវរៈមហាថេរ ឲ្យទៅកាន់ប្រទេសភូមាជាមួយផងលោកក៏ព្រមទៅ ។ ព្រឹកឡើងថ្ងៃសៅរ៍ ១៤ កើតខែ វិសាខ (១៥ ឧសភា) យើងទាំងអស់គ្នាបានចេញដំណើរពី

វត្តបានកំណត់សំដៅទៅស្ថានីយអាកាសយានដុនមឿង ដោយមានឯកឧត្តមអគ្គរាជទូតនិងព្រះសង្ឃព្រមទាំងឧបាសកឧបាសិកាខ្មែរ-ថៃជូនដំណើរទៅផង ៗ ម៉ោង៩.២០នាទី យន្តហោះអាកាសថៃ បាននាំយើងទាំងអស់គ្នាព្រមទាំងអំពើជាចំណូលបុណ្យចេញពីស្ថានីយ ដុនមឿង ឆ្ពោះទៅប្រទេសភូមា ជាមួយនឹងគណៈប្រតិភូថៃ ព្រមទាំងគណៈប្រតិភូវៀត-ណាមនឹងអ្នកដំណើរដទៃរួមទាំងអស់៦២នាក់ ៗ



សមណៈប្រតិភូខ្មែរ មានប្រតិភូអាល័ម៉ង់ឈរជិតសម្ដេចព្រះមហាសុមេធាធិបតី

ម៉ោង ១២-៣១នាទី (ម៉ោង ១១ ប្រទេសភូមា) យើងបានទៅដល់ស្ថានីយអាកាសយានប្រទេសភូមាឈ្មោះ មង្គលដុង ៗ នៅទីនោះព្រះសង្ឃនិងសប្បុរសជនព្រមទាំងឧបាសកឧបាសិកាមានលោកអ៊ូជិន ជុង អគ្គលេខាធិការ នៃពុទ្ធសាសនសភាជាដើមបានមករង់ចាំទទួលនាដណ្ដើរយន្តហោះ ហើយនិមន្តព្រះសង្ឃទាំងអស់ទៅទទួលភត្តដែលគេបានចាត់ចែងប្រគេននៅស្ថានីយនោះ ៗ លុះសម្រេចភត្តកិច្ចហើយទើបឡើងរថយន្តពីស្ថានីយអាកាសយាន ឆ្ពោះទៅកន្លែងធ្វើឆដ្ឋសង្គាយនាចម្ងាយប្រហែល ៨ គីឡូម៉ែត្រពីស្ថានីយអាកាសយានទៅ ៗ



មហាបាសាណគុហា មើលពីខាងក្រៅ

អាត្មានឹកប្លែកអស្ចារ្យក្នុងចិត្តណាស់នឹងកន្លែងធ្វើឆដ្ឋសង្គាយនានោះ ព្រោះកាលពី គ.ស.១៩៥៣ ដែលអាត្មាបានទៅប្រទេសភូមាជាមួយនឹងសម្ដេចព្រះមហាសុមេធាធិបតីបានទៅកាន់ទីនោះ ឃើញពួកកម្មករកំពុងតែជីកចូកដីចាក់គ្រឹះសោះ ស្រាប់តែឥឡូវនេះអស់រយៈកាលត្រឹមតែមួយឆ្នាំ

ពីរខែដប់ថ្ងៃប៉ុណ្ណោះ ទីនោះក៏ក្លាយទៅជាមហាធាសាលាគុហាមួយយ៉ាងធំផុសឡើងហាក់ដូចជាទេពនិម្មិតៗ មហាធាសាលាគុហានេះ គឺជាកុដិមួយយ៉ាងធំ មានបណ្ដោយ ៤៥៥ ហត្ថ, ទទឹង ៣៧០ ហត្ថ, នេះបើគិតខាងក្រៅ ។ បើគិតខាងក្នុងគុហានោះមានបណ្ដោយប្រវែង២២០ហត្ថ, ទទឹងប្រវែង ១៤០ ហត្ថ ។· គុហានោះប្រដាប់ដោយទ្វារធំសម្រាប់ចូលប្រាំមួយ មានប្រហោងតូចបីៗជាសញ្ញានៃព្រះរតនៈទាំងបី (ព្រះពុទ្ធ-ព្រះធម៌-ព្រះសង្ឃ) ។ នៅជុំវិញ មានបោះប្រហោង ២៤ មានសណ្ឋានដូចជាបង្អួច ជាសញ្ញាចំពោះបច្ច័យ ២៤ មានហេតុបច្ច័យជាដើម (ក្នុងព្រះអភិធម្ម) ។ ការកសាងគុហានេះមានតម្លៃ ៩១ សែន (រូពី) បើគិតជាប្រាក់យើងត្រូវជា ៦៨.៦៤១.៣០០ រៀល ។



មហាកុដិទាំង ៤

នៅមានមហាកុដិបួនខ្នងទៀត ដែលគេឲ្យឈ្មោះតាមទ្វីបទាំង ៤ ថា ជម្ពូទ្វីប-បុព្វវិទេហទ្វីប-ឧត្តរកុរុទ្វីប-អបរគោយានទ្វីប, មហាកុដិមួយៗមានបណ្ដោយ ១១០ ម៉ែត្រ, ទទឹង ១៨ ម៉ែត្រ មានជាន់បី, ជាន់ក្រោមចែកជាបន្ទប់ធំៗ សម្រាប់ធ្វើជាសាលារៀនហៅថាសាលាធម្មទូតទៅអនាគត ។ ជាន់កណ្ដាលនិងជាន់លើមានបន្ទប់ពុកសិប ៗ, នៅត្រង់បណ្ដោយខាងចុងជាន់ទាំងបី សុទ្ធតែមានបង្គន់-កន្លែងលុបលាងមុខ និងកន្លែងងូតទឹកម៉ាស៊ីនដូចគ្នាទាំងអស់ៗ នៅមានភត្តសាលាមួយខ្នងទៀតមានជាន់បី ដែលមានបណ្ដោយ ៨០ ម៉ែត្រ ទទឹង ៥០ ម៉ែត្រ, ហើយមានទីបរិវេណខាងមុខដ៏ធំទូលាយមួយថែមទៀត ។ គេហដ្ឋានទាំង ៤ ខ្នងនេះកសាងឡើងអស់តម្លៃ ដប់ពីរលាន ពីរសែន រូពី គិតជាប្រាក់យើងត្រូវជា ៩២.០២៤.៦០០ រៀល, រួមទាំងមហាធាសាលាគុហាផងគឺត្រូវជា ១៦០.៦៦៥.៩០០ រៀលប្រាក់យើង ៗ



បុព្វវិទេហមហាកុដិ

កិច្ចុសង្ឃជាប្រតិភូខ្មែរត្រូវទៅសំណាក់អាស្រ័យនៅបុព្វវិទេហមហាកុដិត្រង់ជាន់កណ្ដាល ។ គេរៀបចំបន្ទប់មួយដោយឡែកសម្រាប់សម្ដេចព្រះមហាសុមេធាធិបតីតែមួយព្រះអង្គ ក្រៅពីនោះត្រូវនៅរួមគ្នាមួយបន្ទប់ពីរអង្គ ១; ក្នុងបន្ទប់នីមួយ ១ មានគ្រែសម្រាប់សិង្ហពីរ-តុទូសម្រាប់ដាក់ប្រដាប់ប្រដាពីរ - តុកៅអីពីរ ១ ព្រមទាំងមានភ្លើងអគ្គិសនីដោយសព្វគ្រប់ៗ នៅមុខបន្ទប់មានក្អមទឹក ដ៏លទឹកមួយ ១ សម្រាប់ប្រើប្រាស់ ហើយមានអ្នកបំរើជានិច្ច ៗ នៅសាលពលល្វែងចំកណ្ដាលគ្រប់ជាន់ទាំងបី មានការិយាល័យ-ទូរស័ព្ទ ប្រចាំការជានិច្ច ៗ នៅបរិវេណខាងក្រោមមានរថយន្តថ្មី ១ ប្រដាប់ដោយគ្រឿងរបស់សមាគមពុទ្ធសាសនសភា



រថយន្តថ្មីៗប្រដាប់ដោយគ្រឿងរបស់សមាគមពុទ្ធសាសនសភា នៅបរិវេណខាងក្រោម

ខាតតូច-ធំ ចតដល់ហេយនៅប្រចាំការសម្រាប់ដឹកនាំប្រតិភូទៅកាន់ទីផ្សេង ១ តាមត្រូវការៗ បំណែកខាងបុរសខាងបុរសិកា មានសណ្ឋាគារមួយសម្រាប់ជាទីសំណាក់អាស្រ័យ ដោយឡែកចម្ងាយពីទីឆដ្ឋសង្គាយនាប្រហែលជាង ៨ គីឡូម៉ែត្រ ។

ថ្ងៃអាទិត្យ ១៥ កើតខែវិសាខ (១៦ ឧសភា) ក្រោយដែលបានធ្វើបាតរាស (ចង្ហាន់ព្រឹក) ក្នុងភត្តសាលារួចស្រេចហើយ នោះវេលាម៉ោង ៨ គត់ព្រះសង្ឃប្រមាណ ២.០០០ រូប មាន ព្រះអភិធម្មមហាថេរ រដ្ឋគុរុ ញោងយ៉ាន់សាយ៉ាឌ ជាប្រធាននិមន្តចូលទៅកាន់មហាបាសាណគុហា ដើម្បីធ្វើពិធីបង្ស៊ីមា ។

លុះព្រះសង្ឃទាំងអស់គង់លើអាសនៈរៀបរយហើយព្រះមហាថេរ៣រូបគឺ ព្រះចៅគាណៃតែកសាយ៉ា ឧវសិម្ប ជន្មាយុ៨២ឆ្នាំ វស្សា៦៣, ព្រះជិតសេនដីតែកសាយ៉ា ឧវស៊ីម្បជន្មាយុ៨២ឆ្នាំ វស្សា៦៣ដូចគ្នា នឹងសម្តេចព្រះ មហាសុមេធាធិបតី ជន្មាយុ ៧១ ឆ្នាំ វស្សា ៥២ គង់លើអាសនៈដ៏ខ្ពស់កណ្តាលជំនុំសង្ឃ សូត្របាលីញត្តិទុតិយកម្មវាចា សីមាសម្មូហនកម្ម (ដកសីមា) មួយលើកដំបូង ។

-ព្រះពុទ្ធឧត្តមមហាថេរសាយ៉ា ឧវ (លង្កាទ្វីប), ព្រះអានន្ទមេត្តេយ្យមហាថេរសាយ៉ា ឧវ (លង្កាទ្វីប) នឹងព្រះមហាថេរ អ៊ូ. បញ្ញាលោកៈ (ក្រុងរង្គូន) សូត្របាលីញត្តិទុតិយកម្មវាចាដដែលនោះជាលើកទី២,

-ព្រះវិមលធម្ម-ព្រះអមរវេធី នឹង ព្រះសិរីសុធស្សនៈ (ជាតិថៃ) សូត្របាលីញត្តិទុតិយកម្មវាចាដដែលនោះជាលើកទី ៣ ។

-ព្រះសុមនត្ថេរ (ប្រទេសបាគិស្ថាន), ព្រះសុភូតត្ថេរ (ប្រទេសបាគិស្ថាន) នឹងព្រះធម្មធរត្ថេរ (ប្រទេសឥណ្ឌា) សូត្របាលីញត្តិទុតិយកម្មវាចាដដែលនោះជាលើកទី ៤ ,

លុះសូត្របាលីញត្តិទុតិយកម្មវាចាដកអវិប្បវាសសីមានឹងសមានសំវាសសីមា ៤ លើករួចហើយ ទើបសម្តេចព្រះមហាសុមេធាធិបតី (ប្រទេសកម្ពុជា) នឹងព្រះមហាថេរ ៥ អង្គដទៃទៀត សូត្របាលីដណ្តឹងនិមិត្តសីមាមួយ-អង្គហើយមួយអង្គទៀត តាមលំដាប់គ្នា, មានព្រះថេរៈមួយអង្គគង់ប្រហោងប្រណម្យហត្ថាជាអ្នកឆ្លើយប្រាប់និមិត្តសីមា ។ ការដណ្តឹងនិមិត្តនោះមានមហាថេរអង្គខ្លះលើកព្រះហស្តខាងស្តាំចង្អុលឆ្ពោះទៅរកទិសដែលត្រូវសួរជាសញ្ញាផង ។ ដំបូងបង្អស់សួរថា បុរត្ថិមាយ ទិសាយ កឹ និមិត្តំ?- ព្រះថេរៈអ្នកឆ្លើយតបថា បាសាណោ ភន្តេ ។ មហាថេរអ្នកសួរសូត្រថា ឯសោ បាសាណោ និមិត្តំ? ព្រះថេរៈអ្នកឆ្លើយនោះឆ្លើយតបទៀតថា អាម ភន្តេ ។ ជួនកាលអង្គខ្លះថា ឯវំ ភន្តេ ។ (អាម ភន្តេ នឹង ឯវំ ភន្តេ ទាំង ២ បែបនេះ មានសេចក្តីដូចគ្នា, ឃើញថាប្រើបែបណាមួយក៏បាន) ។ល។ លុះដណ្តឹងនិមិត្តសីមាគ្រប់ទិស រហូតដល់មកទិសបូព៌ាថែមទៀត ច្រើនដងដដែលៗរួចហើយ; ទើបសូត្របាលីញត្តិទុតិយកម្មវាចាសម្មតិសមានសំវាសសីមា រួចសម្មតិអវិប្បវាសសីមា តាមលំដាប់គ្នាច្រើនដងដូចកាលសូត្រដកសីមាដែរ ។

លុះចប់សីមាសង្ឃកម្មនេះហើយ សម្តេចព្រះមហាសុមេធាធិបតីបានសួរមហាថេរជាតិភូមាមួយអង្គដែលគង់ជិតគ្នាថា ហេតុម្តេចក៏ចាំបាច់សូត្រដដែលៗច្រើនដង ច្រើនសាម្ល៉េះ? មហាថេរនោះឆ្លើយថា ដើម្បីឲ្យជាថាវរកម្ម; មួយទៀត, ដ្បិតខណ្ឌសីមានេះជាសីមាសាកល គឺជាសីមារបស់សង្ឃ គ្រប់ប្រទេស, បានជាធ្វើយ៉ាងនេះដើម្បី

ឲ្យសមដល់ឋានៈនៃមហាបាសាណគូហាដែលជាទីប្រជុំធ្វើឆដ្ឋសង្គាយនា ។

ម៉ោង១១ខ្ទះ ១៥ នាទី ព្រះរេវតមហាថេរ មហារដ្ឋគុរុ ញ៉ាង យ៉ាង សាយ៉ាឌវ ប្រកាសសេចក្តីឲ្យជំនុំសង្ឃជ្រាបថា ឆដ្ឋសង្គាយនា-មហាបាសាណគូហានេះ ជាទីមានសីមាដែលសង្ឃគ្រប់ប្រទេសខាងថេរវាទបាននិមន្តមកប្រជុំគ្នា បានធ្វើឲ្យសម្រេចហើយដោយសាមគ្គីភាព ។

ម៉ោង ១១ ព្រះសង្ឃទាំងអស់ត្រូវនិមន្តទៅឆាន់ឯភត្តសាលាវិញ ។

អាត្មាសូមបញ្ជាក់អំពីជាតិភូមាចាត់ចែងចង្ហាន់ប្រគេនព្រះសង្ឃនៅក្នុងភត្តសាលា ដែលចែកជាកន្លែងឆាន់មាន ៤ គឺសាលាមានជាន់បីធំវែងមួយ ។ ក្នុងកន្លែងនីមួយ ៗ មានតុតូចមួយ បណ្តោយ ៧៥ សង់ទីម៉ែត្រ, ទទឹង ៥០ សង់ទីម៉ែត្រ, កំពស់ ៣០ សង់ទីម៉ែត្រតម្រៀបហៀជាជួរ ៗ រាប់ពាន់រយ ៗ ។ នៅក្បែរតុនីមួយ ៗ មានផ្តិលទឹក, កន្ទោរ, ពានលាងដៃ, សាប៊ូ, កូនកន្សែងជូតដៃ; នៅលើតុមានបាត្រដាក់ចង្ហាន់ស្រេចស្រាប់មួយ ៗ មានម្ហូបទឹក, ម្ហូបគោក៤-៥មុខ, មាននំបង្អែម, កែវរៃ, កែវកាហ្វេព្រមទាំងស្លាមួយមាត់ ១ គ្រប់តុទាំងអស់សម្រាប់ភិក្ខុមួយរូប ៗ ដូច ៗ គ្នា រួមទាំងអស់ប្រហែល ៣០០០តុ ។ ការចាត់ចែងនេះគឺ អស់លោកជំទាវ-លោកស្រី មានលោកជំទាវឯកឧត្តមនាយករដ្ឋមន្ត្រី និងលោកជំទាវឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការជាដើម ព្រមទាំងឧបាសក-ឧបាសិកា មានសេចក្តីជ្រះថ្លា បានមកជួយខ្វល់ខ្វាយធ្វើការក្នុងពេលភត្ត ដោយបច្ច័យបរិកាជាតិផង បច្ច័យនៃអ្នកមានសទ្ធាជ្រះថ្លាយកមកចូលផង ។

ឯការបំរើព្រះសង្ឃឆាន់ជាភារៈនៅលើកងសេនាពាហន តាំងពីពាហនសាមញ្ញ រហូតដល់អ្នកមានបណ្តាស័ក្តិរាប់រយនាក់មកអង្គាសចង្ហាន់បំរើសង្ឃ អ្នកខ្លះដើរចុះឡើងរំពៃមើលគ្រប់កន្លែងមិនឲ្យមានខ្វះខាតដោយស្ងប់ស្ងាត់ឥតសូរសំឡេងអឺអរឡើយ, ពាហនទាំងនោះ មានឫកពាកិរិយាសុភសុភាពសមរម្យជាពុទ្ធសាសនិកជន ។

ដល់មកត្រង់នេះខ្ញុំ <<មហាប៊ឹង-យ៉ាត>> សូមនាំយកសេចក្តីថ្លែង របស់ព្រះតេជព្រះគុណព្រះឧបាលិវង្ស ដោយលោកបានឲ្យសម្ភាសន៍ដល់ខ្ញុំខ្លះ ខ្ញុំយល់ថាគួរនាំយកមកចុះក្នុងទីនេះដែរ ។ សម្ភាសន៍របស់ព្រះតេជព្រះគុណព្រះឧបាលិវង្សនោះ ខ្ញុំចុះក្នុងវង់ក្រចកដោយខ្សែកដូចតទៅនេះ ៖

(មានពេលគ្រមួយជញ្ជាំងតៀប្រក់ស័ក្តិស្រទបចេកដំពូលាយល្វឹងល្វើយ ខាងក្នុងមានជើងក្រានរៀបជាជួរ ៗ សុទ្ធតែប្រើដោយកម្លាំងអគ្គិសនី មានម៉ាស៊ីនមួយផ្សេង សំរាប់បញ្ចេញចំហាយអគ្គិសនីមកជាជំនួយទៀត ។

មានចែកជាបន្ទប់សម្រាប់ដាក់គ្រឿងឧបភោគបរិភោគផ្សេង ៗ ជាច្រើនកន្លែង ។ ក្នុងកិច្ចចាត់ចែងភត្តាហារប្រ-គេនព្រះសង្ឃទាំងអស់នោះ គេចែកជាពីរគណៈកម្មការ គឺ ៖

វេលាម៉ោង ១៩ លោកជំទាវឯកឧត្តមនាយករដ្ឋមន្ត្រី ជាប្រធានគណៈកម្មការខាងការចិតបន្លែនិងខាងការដាំ-ស្ល បាននាំនារីជាសមាជិកចំនួនជាងពីររយនាក់មកចាត់ចែងចិតបន្លែផ្សំគ្រឿងគ្រៅទុករហូតដល់ម៉ោង ២៣ ឬម៉ោង ១០ យប់ ទើបនាំគ្នាបិទទ្វារចាក់សោទុក ហើយត្រឡប់ទៅផ្ទះវិញ ។

ពេលព្រឹករាង ម៉ោង ៦និង ៣០ នាទីគណៈកម្មការដដែលនេះ មកបន្តកិច្ចដាំស្លចំអិនទៀតហើយ ស្រេចទុកជូនគណៈកម្មការលៃលកជួសដោះ ដែលមានលោកជំទាវឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ជាប្រធានបាននាំនារីជាសមាជិកចំនួនជាង ២០០ នាក់មកចាត់ចែងជួសដោះដាក់ចាន ។ ម្ហូបអាហារទាំងអស់សុទ្ធសឹងជារបៀបភូមា ដែលប្រហែលគ្នានឹងម្ហូបអាហារជាតិខ្មែរយើងដែរ ប៉ុន្តែមានដាក់ម្ទេសនិងគ្រឿងហឹរច្រើនជាងយើងបន្តិច ។ រាល់ថ្ងៃក្នុងឱកាសធ្វើផ្សង្គាយនានោះ ភោជនាហារគ្រប់មុខសម្រាប់ប្រគេនភិក្ខុសង្ឃជាសង្គីតិការកៈចំនួន ២៥០០ អង្គនោះបរិបូណ៌ឥតដែលឃើញលើសលោះឬខ្វះខាតឡើយ ។

អាត្មាសូមបញ្ជាក់អំពីអំពើល្អខ្លះ ដែលរដ្ឋាភិបាលភូមាបានបញ្ញត្តហាមដល់សាធារណជនជាតិគេ ៖

១-រដ្ឋាភិបាលសហភាពភូមា បានបំបាត់ចោលពុំឲ្យមានសមាគមបិតស្រាក្នុងប្រទេសគេទេ ហើយបានដាក់ទណ្ឌកម្មជាទម្ងន់ ចំពោះសមាគមឬឯកជនដែលលបលាក់បិតស្រាទៀត ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលបានចាត់ការប្រុងប្រយ័ត្នយ៉ាងតឹងរ៉ឹតបំផុតមិនឲ្យមានស្រាដូចយ៉ាងវិស្គី-ប៊ីគី-ម៉ារតែលជាដើមពីប្រទេសក្រៅ មិនឲ្យចូលមកក្នុងប្រទេសគេទេ ។ ជនណាដែលសេពសុរាពីប្រទេសក្រៅក្ដី ស្រាបែបណាក្ដី នាយតម្រួតទូទៅក្នុងប្រទេស តែងតែចាប់ធ្វើទណ្ឌកម្មយ៉ាងធ្ងន់ចំពោះជននោះ ។ ឯកឧត្តមនាយករដ្ឋមន្ត្រីនិងឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ជាអាចារ្យខាងពុទ្ធសាសនាសម្រាប់ប្រទេស ដូចយ៉ាងក្នុងពេលសមាទានសីល លោកអាចអារាធនាសីលខ្លួនលោកក្នុងទីប្រ-ជុំធំ ៗ ។ គណៈរដ្ឋមន្ត្រីដែលមានលោកបណ្ឌិត អ៊ូ. ករ:អ៊ូ. ជាប្រធានាធិបតីសហភាពភូមានេះសុទ្ធសឹងជាអ្នករក្សាឧបោសថសីល និងនិច្ចសីលទាំងអស់ ។

២.– រដ្ឋាភិបាលបានបញ្ញត្តហាមមិនឲ្យសម្លាប់គោ-ក្របីសេះដាដាច់ខាត ព្រោះគេយល់ឃើញថាសត្វទាំងនេះមានឧបការៈច្រើនដល់មនុស្ស ព្រោះហេតុនោះសមាគមពិឃាតសត្វមានពិឃាតតែតែចៀមមាន់-ទា និងមច្ឆជាតិប៉ុណ្ណោះ ។

៣- មានបញ្ញត្តិហាមដល់ស្ត្រីមានគភ៌ឬដែលមានទារកនៅបៅទទឹង មិនឲ្យធ្វើដំណើរតាមរថយន្តឬយាន នានាទៅកាន់ទីឆ្ងាយពេក វៀរលែងតែមានការជាបន្ទាន់ដែលជាការចាំបាច់ទីងជៀសវាងពុំផុត ទើបអនុញ្ញាតឲ្យ ដើរបានខ្លះ ។

នៅប្រទេសភូមា ប្រជាជនមិននិយមប្រើសំពត់ខ្មៅជ្រលក់ម៉ាក់ក្លឿ ឬ សំបកឈើទីងរបៀបអ៊ុតសក់សោះ ទោះនៅទីប្រជុំធំៗក្តី នៅទីស្រែចម្ការក្តី ក៏ឥតមានឃើញស្ត្រីណាមួយអ៊ុតសក់ ឬស្លៀកសំពត់ខ្មៅព៌ណម៉ាក់ក្លឿ ដែរ គេប្រកាន់ប្រើសម្លៀកបំពាក់ព៌ណផ្សេងៗ ក្រៅពីព៌ណខ្មៅ តាមប្រពៃណីប្រទេសជាតិគេទាំងអស់ ។

បានឮថា កាលពីមុននេះ មានភរិយាចុងរបស់លោកអតីតនាយករដ្ឋមន្ត្រីម្នាក់ ប្រើសម្លៀកបំពាក់តាមរបៀប អឺរ៉ុប ហើយជិះរថយន្តផ្ទាល់ខ្លួនទៅផ្សារ គ្រាន់តែចុះពីរថយន្តភ្លាម គឺពួកអ្នកផ្សារជាតិភូមាដូចគ្នាស្ទុះមកចាប់ហែក សម្លៀកបំពាក់ទាំងនោះចេញអស់ ស្ទើរតែអាក្រាតនៅខ្លួនទទេ ទោះបីប៉ូលីសហាមឃាត់យ៉ាងណាក៏មិនឈ្នះៗ ព្រោះហេតុតែគេប្រកាន់ប្រពៃណីយ៉ាងនេះ ទើបស្រីជាតិភូមាមិនប្រើសម្លៀកបំពាក់ខុសពីគោលនៃប្រទេសជាតិ របស់គេឡើយ ទាំងជនជាតិភូមាប្រុសៗក៏ដូចគ្នាដែរ ។

នៅហាងធំៗ ក្នុងទីផ្សារឬទីប្រជុំជនក៏ច្រើនតែជនជាតិភូមា ជាមេហាង ជាម្ចាស់ហាង អ្នកលក់ដូរក៏ច្រើន តែជនជាតិគេ គេនិយមប្រើរបស់ដែលកើតក្នុងប្រទេសគេ តាំងពីបារីឡើងទៅ ក៏គេមិនសូវប្រើបារីជាតិដទៃដែរ បើទុកជាប្រើក៏ប្រើបន្តិចបន្តួចសម្រាប់ភ្ញៀវជាតិដទៃប៉ុណ្ណោះ; ជនជាតិភូមាចេះមូរបារីស្លឹកថ្នាំមិនចាញ់ប្រទេសដទៃ ប៉ុន្មានទេ ។

ជនជាតិភូមានិយមបំបួសកូនចៅណាស់ គឺកូនប្រុសអាយុតាំងពី៧ឆ្នាំឡើងទៅ គេតែងបំបួសសាមណេរ ហើយសាមណេរតូចៗនេះខំប្រឹងរៀនសូត្រណាស់ ដល់ពេលចេះអក្សរសាស្ត្រភូមាសមគួរហើយ ទើបឲ្យលាក សិក្ខាបទចូលទៅរៀនសាលា ។ មួយទៀត បើកូនប្រុសណាដែលចូលរៀនក្នុងសាលាហើយ, ដល់ពេល វិស្សមកាល គេឲ្យបួសសាមណេរត្រឹមកន្លះខែក៏មាន កូនប្រុសម្នាក់ៗច្រើនតែបានបួសពុំសូវខាន ។

ម្យ៉ាងទៀត បើកូនចៅនរណាពុំបានបួសទេ ដោយចេញទៅនៅប្រទេសក្រៅតាំងពីតូចមកនោះ ពេល ដែលចូលមកនៅក្នុងប្រទេសខ្លួនវិញ តែងតែរកពេលបំពេញផ្នួសអស់ចំនួន៣ខែយ៉ាងតិច ដើម្បីឲ្យចេះដឹង លទ្ធិព្រះពុទ្ធសាសនាខ្លះ ។ល។

ចប់សម្ភាសន៍ របស់ព្រះតេជព្រះគុណព្រះឧទាលិវង្ស ត្រឹមប៉ុណ្ណេះ ។ បន្ទាប់ពីនេះរៀងរហូត

ដល់ចប់សុទ្ធសឹងតែជាសម្ភាសន៍របស់ ព្រះតេជព្រះគុណព្រះគ្រូសង្ឃសត្ថា (ជម្ពាភមោ) ទាំងអស់ ។

នៅពេលម៉ោង ១៦ ថ្ងៃនោះព្រះសង្ឃទាំងអស់ក៏និមន្តចូល មហាបាសាណគុហា ម្តងទៀត ដើម្បីចំរើនព្រះបរិត្តពុទ្ធមន្តសម្ពោធទីនោះ ។ ចំណែកខាងពួកឧបាសក-ឧបាសិកានាំគ្នាហែជាក្បួន ប្រទក្សិណ ៣ជុំខាងក្រៅ ។

---

## ថ្ងៃចន្ទ ១ រោចខែវិសាខ (១៧ ខែឧសភា)

ថ្ងៃនេះនៅប្រទេសថៃនិងប្រទេសភូមា ជាថ្ងៃពេញបូណ៌មីនៃខែវិសាខ ព្រោះពួកហោរាបានលើកអធិកវារៈគឺបន្ថែមថ្ងៃមួយនៅខែជេស្ឋមុនយើងមួយឆ្នាំ យើងទើបតែលើកអធិកវារៈក្នុងឆ្នាំនេះ ដោយហេតុនោះចាប់តាំងពីថ្ងៃ១៤ រោច ខែជេស្ឋ ឆ្នាំមមីឆស័ក (៣០ មិថុនា ១៩៥៤) នេះទៀតទៅ ប្រទេសទាំងបីនឹងមានថ្ងៃខាងចន្ទគតិ ត្រូវគ្នាតែបែបមួយទៅវិញ ។

ថ្ងៃវិសាខបូជានេះហើយ ជាថ្ងៃផ្តើមប្រជុំធ្វើឆដ្ឋសង្គាយនា ។ វេលាម៉ោង ១១ ព្រះសង្ឃសំរេចភត្តកិច្ចរួចហើយ



ផ្ទិតពិសេសដែលចុះឈ្មោះវស្សានិងនាមឬសមណស័ក្តិ ព្រមទាំងលេខរៀង

ត្រូវទទួលយកផ្ទិតពិសេសដែលចុះឈ្មោះវស្សានិងនាម ឬ សមណស័ក្តិព្រមទាំងលេខរៀងជាគ្រឿងសំគាល់ ផ្ទិតនោះមានចំនួន២.៥០០គត់ ជាផ្ទិតសម្រាប់ឆដ្ឋសង្គីតិការកៈ(លោកអ្នកធ្វើសង្គីតិ) ចូលទៅកាន់មហាបាសាណគុហា តាមទ្វារមួយខាងជើង និងទ្វារខាងលិចទាំងពីរ ។ ចំណែកខាងឧបាសក-សិកា ដែលបានទទួលស្វាគមអញ្ជើញត្រូវចូលតាមទ្វារខាងត្បូង ។

ភ្ញៀវពិសេសរបស់ពុទ្ធសាសនសភាត្រូវចូលតាមទ្វារលេខ២ ទិសខាងកើត ។ លោកប្រធានាធិបតី, រដ្ឋមន្ត្រីគ្រប់តំណែង, ប្រតិភូរដ្ឋាភិបាលនានាប្រទេស, ភ្ញៀវបរទេស និងអ្នករាជការខាងអគ្គទូត ត្រូវចូលតាមទ្វារខាងកើតលេខ១ រួមទ្វារនៃ មហាបាសាណគុហា នេះទាំងអស់ត្រូវជា ៦ គឺ ខាងជើង១ ខាងត្បូង១ ខាងកើត២ ខាងលិច២ ។

ពេលៈនោះក៏បង្កើតមហាស្វារ្យបណ្ដាលឲ្យមហាមេឃសម្ដែងបុទ្ធិដ៏ធំតដុំទិសទីបង្អុរភ្លៀងជោគជាំមហាប្រិថពីសព្វទីកន្លែង ប៉ុន្តែទុកណាជាដូច្នោះ ពពួកមហាជនក៏នៅតែនាំគ្នាដើរហូរហែណែនណាន់តាន់តាប់ជុំវិញ មហាបា-សាណគូហាដោយឥតគិតដល់ការទទឹកសម្លៀកបំពាក់ឡើយ, អ្នកខ្លះមានតាំងយូក៏បាំងទៅ អ្នកខ្លះគ្មានក៏ដើរទទេគ្មានរវល់ឡើយ ។ ចំណែកខាងព្រះសង្ឃជាប្រតិភូជាតិយើង ដែលមានសម្ដេចជាប្រធាន សមាគមបានចាត់រថយន្តមកទទួលពីទីសំណាក់ទៅកាន់មហាបាសាណគូហាព្រមដោយរបស់ជាបរិក្ខារចំណូលបុណ្យទាំងអស់ ។

នៅក្នុង មហាបាសាណគូហា មានព្រះសង្ឃចំនួន ២.៥០០ អង្គ និងវរជន-ឧបាសក-ឧបាសិកាគប់ទាំងប្រតិភូតំណាងប្រទេសនានា រួមចូលផង មានចំនួន២.០០០នាក់ ។ មានព្រះសង្ឃនិងឧបាសក-ឧបាសិកាប្រហែលជាង ២០០.០០០ នាក់ ដែលសុខចិត្តត្រាំនៅហាលភ្លៀងផ្គរខ្លះ ដើម្បីចាំស្ដាប់សជ្ឈាយនាដែលព្រះសង្ឃសូត្រ ៗ ក្រៅពីនេះ, ដោយស្ថានទៅ, មានព្រះសង្ឃនិងគ្រហស្ថ រាប់លានអ្នកស្ដាប់វិទ្យុតាមវត្តនិងគេហស្ថាន ព្រោះគេបានបន្តសំឡេងបញ្ចូលទៅក្នុងវិទ្យុជាតិ ។



ទីខាងក្នុងមហាបាសាណគូហា

## អំពីអាសនៈ សម្រាប់ព្រះសង្ឃនិងគ្រហស្ថ គង់-អង្គុយ ក្នុងមហាបាសាណគូហាដូច្នេះ៖

ឧបាសក-ឧបាសិកា អង្គុយរាបនៅត្រង់ភាគកណ្ដាលគូហាជាពីរចំណែក គឺឧបាសកខាងស្ដាំ ឧបាសិកាខាងឆ្វេង ។ ចំណែកខាងព្រះសង្ឃគង់នៅលើថ្នាក់ៗ ជុំវិញចំនួន៨ថ្នាក់ ។ ឯ ព្រះមហាថេរ រដ្ឋគុរុ ព្រះមហាថេរប្រតិភូគ្រប់ប្រទេសនិងព្រះមហាថេរមកពីគណៈខេត្តនានា គង់លើមហាវេទិកាមួយ ដ៏ខ្ពស់ ។ ក្នុងទីប្រជុំនេះ មាន

ព្រះសង្ឃនិងឧបាសក-ឧបាសិកាជាប្រតិភូប្រទេសផ្សេងៗដូចតទៅនេះគឺៈ កម្ពុជា, ថៃ, លង្កា, នេប៉ាល, លាវ, ឥណ្ឌា, ប៉ាគិស្ថាន, បេង្គាល(វង្គៈ), វៀតណាម, ឥណ្ឌូនេស៊ី, ស៊ិក្កឹម, អង់គ្លេស, អល្លឺម៉ាញ ឆាលស្ទា, ម៉ាឡាយ៉ា, ជប៉ុន និងកោះរ្យូគ្យូ និងព្រះថេរៈជាតិ ភូមាខ្លះ ជាតិសីហឡៈ (អ្នកលង្កាទ្វីប) ខ្លះដែលនៅប្រចាំពុទ្ធស្ថានផ្សេងៗ នៅប្រទេសឥណ្ឌានិងប្រទេសនេប៉ាល ក៏បានមកកាន់ទីប្រជុំនេះដែរ ។

*
* *

ទី១/– លុះព្រះសង្ឃនិងឧបាសក-ឧបាសិកាមកជួបជុំអស់ហើយ, នៅម៉ោង១២និង១០នាទី ទើបលោកបណ្ឌិត អ៊ូ.គះ.អ៊ូ. ប្រធានាធិបតីនៃសហភាពប្រទេសភូមា អញ្ជើញមកដល់ ដោយមាននាយទាហានជាអង្គរក្ស ២ នាយ ជាអ្នកដើរនាំមុខ បានចូលមកក្រាបថ្វាយបង្គំបីដងចំពោះជំនុំសង្ឃ ហើយអង្គុយពាប់លើកម្រាលពូកតូចមួយ នៅក្នុងចំណោមរដ្ឋមន្ត្រី ។

ទី២/– ម៉ោង ១២ និង ១២ នាទី (ប្រទេសភូមា)ជាអភិលក្ខិតកាលសុភមង្គល ដែលហោរាសាស្ត្រជ្រើសរើសទៅឃើញថា ជាពេលប្រកបដោយឫក្សពារពេលល្អ ដើម្បីបើកសម័យសង្គាយនាទី ៦ ។ ស្នូរស័ព្ទ ស័ង្ខ, ប៉ូង, គាំគោះ, ពេជរោរ៍ ខាងក្នុងគុហា និងរគាំងធំៗ ចំនួន ១០៨ ជុំវិញខាងក្រៅគុហា ក៏លាន់ឮកងរំពងអឺងអ័ព្ទ ជាឯកប្រហារ ហាក់ដូចកក្រើកផ្លូវក្រឡុំមហាប្រឹថពី ។

ទី៣/–ព្រះញាណវំស មហាថេរ ជាលេខាធិការទីពីរនៃពុទ្ធសាសនសភា ប្រកាសសេចក្តីជាភាសាបាលីនិងភាសាភូមា បើកពេលប្រជុំឆដ្ឋសង្គាយនា ។ លុះចប់សេចក្តីប្រកាសហើយ ព្រះវិសុទ្ធមហាថេរ លេខាធិការទី១ សូត្រញត្តិជាភាសាបាលីផ្ទៀងសង្ឃតាំងព្រះ អភិធជ មហារដ្ឋគុរុ ភទន្ត រេវត ញ៉ោងយ៉ាន់សាយ៉ាឌរ ជាប្រធានសង្ឃក្នុងពិធីសង្គាយនា ។ ទើបព្រះមហាថេរអង្គនោះឡើងគង់លើថេរាសនៈជាប្រធានសង្ឃ ។

ទី៤/–បន្ទាប់មក អ៊ូ.បណ្ឌិតមហាថេរ សូត្រចុតិវេទល្ខគាថាជាភាសាបាលី ប្រែជាភូមា ថ្វាយអំណរចំពោះមហាសន្និបាតនៃឆដ្ឋសង្គាយនា ។ លុះចប់ហើយ ជំនុំសង្ឃទាំងអស់បន្ទរពាក្យថា សាធុ ៣ ដងព្រមៗគ្នាឮខ្ទាំងៗ ។

ទី៥/– ឧបាសក អ៊ូ.សេងវិន សូត្របូជនីយមង្គលាថោមនាគាថា ហើយឯកឧត្តម អ៊ូ.វិន រដ្ឋមន្ត្រីក្រសួងធម្មការ ថ្វាយសេចក្តីគោរពចំពោះមហាសន្និបាត ។

ទី៦/-ឯកឧត្តម អគ្គមហាសិរីសុធម្មបណ្ឌិត អ៊ូ.ភៈអ៊ូ ប្រធានាធិបតីនៃសហភាពប្រទេសភូមា ថ្លែងសេចក្តីគោរព ទទួលខ្លួនធ្វើជាអ្នកឧបត្ថម្ភកនៃឆដ្ឋសង្គាយនាក្នុងនាមរបស់ប្រទេសជាថេរវាទទាំងអស់ ។

ទី៧/-លោក សាធុសិរីសុធម្ម អ៊ូ.ធិន ប្រធាននៃពុទ្ធសាសនសភា ថ្លែងសេចក្តីទទួលបន្ទុកផ្គត់ផ្គង់ភិក្ខុសង្ឃដោយចតុប្បច្ច័យ ក្នុងនាមនៃរដ្ឋាភិបាលសហភាពប្រទេសភូមានិងពុទ្ធសាសនសភា ។



ឯកឧត្តម អគ្គមហាសិរីសុធម្មបណ្ឌិត អ៊ូ.ភៈអ៊ូ
ប្រធានាធិបតីនៃសហភាពប្រទេសភូមា

ទី៨/- ការអានសារលិខិត :

ក) របស់ សម្តេចព្រះសង្ឃរាជប្រទេសថៃ ដោយ ព្រះវិមលធម្ម ប្រធានគណៈប្រតិភូថៃ ។

ខ) របស់ ឧត្តរីតរសភា នៃលង្កាទ្វីប ដោយព្រះបណ្ឌិតធម្មវង្សថេរ ។

គ) របស់អមរបុរនិកាយ និងកល្យាណីវង្សនិកាយ (លង្កាទ្វីប) ដោយ ព្រះបណ្ឌិតធម្មកុសលត្ថេរ ។

ឃ) របស់រាមញ្ញនិកាយ (លង្កាទ្វីប) ដោយព្រះបណ្ឌិតសរណចាលិត្ថេរ ។

ង) របស់ឯកឧត្តមប្រធានាធិបតីនៃប្រទេសឥណ្ឌា ដោយឯកឧត្តម គា.គា.ចិត្តុរៈ ឯកអគ្គរាជទូត ប្រទេសឥណ្ឌា ប្រចាំប្រទេសភូមា ។

ច) របស់ ព្រះចៅប្រទេសនេប៉ាល ដោយនាង គញ្ញាវិមលាទេវី ។

ឆ) របស់ ព្រះចៅប្រទេសថៃ ដោយ ឧត្តមសេនីយខាបគុញ្ជរ ។

ទី៩/- សេចក្តីថ្លែង:

ក) របស់សម្តេចព្រះមហាសុមេធាធិបតី (ប្រទេសកម្ពុជា) ជាភាសាបាលីហៅថា ៖

វន្ទាមិ ភន្តេ មហាថេរ !

ឱកាសំ ទេថ មេ ភន្តេ !

មយំ កម្ពោជិកា ហោម ធសព្បមាណា បព្វជិតា, តយោ ឧបាសកា, បញ្ច ឧបាសិកាយោ (អដ្ឋារសជនា) ឯកតោ វិជាគតា ។ អយំ កម្ពុជរដ្ឋ ពុទ្ធសាសនិកានំ បជិត្វា ហោមិ រដ្ឋាភិបាលេន បេសិតោ សត្តរសន្នញ្ច បមុខោ ។ ធម្មាភយោ នាម



សម្តេចព្រះមហាសុមេធាធិបតី

ភិក្ខុ ច រដ្ឋាភិបាលេន បេសិតោ ហោតិ មម សហការី ។ សត្តញ្ច បន កម្ពោជិក-បព្វជិតា សាមាជិកា ហោន្តិ ឆដ្ឋសង្គាយនាកម្មេ បសន្នចិត្តា ឥធាគតា តថេវ អដ្ឋកម្ពោជិកគហដ្ឋា ។ ខេមាចារោ នាម ភិក្ខុបិ ឦទិសោយេវ ។

ឆដ្ឋសង្គាយនាកម្មេ ឧបការណត្ថាយ ឥមស្មិំ ទិវសេ ពុទ្ធសាសនសភាយ និយ្យាទិតានិ សារទារុមយពុទ្ធរូបាទីនិ វត្ថូនិ កម្ពុជរដ្ឋស្ស និមិត្តរូបំ ។

ឯត្តាវតា មម បកាសនកថា ។ ឥតោ បរំ វីរធម្មវរោ នាម កម្ពោជិកោ ថេរោ ឥង្គ្លិសភាសាយ ថោកំ វិត្ថារេន កថាបវត្តិំ កថេស្សតិ ។ សាធុ សាធវោ តស្ស ឱកាសំ ទេថ អាទរេន កថេតុំ ។

*កាលដែលសម្ដេចថ្លែង ឥតមានប្រែទេ, បាលីនេះបើប្រែជាភាសាខ្មែរថា៖*

*បពិត្រមហាថេរទាំងឡាយ, ខ្ញុំករុណាសូមថ្វាយបង្គំ!*

*សូមមហាថេរទាំងឡាយ, បើកឱកាសដល់ខ្ញុំករុណា!*

*យើងទាំងឡាយជាជាតិខ្មែរ មានបព្វជិត១០រូប, ឧបាសក៣នាក់ ឧបាសិកា៥នាក់ (រួមទាំងអស់១៨រូប) បានមកក្នុងមហាសន្និបាតនេះព្រមគ្នា ។ ខ្ញុំករុណាជាតំណាងនៃពុទ្ធសាសនិកជនក្នុងកម្ពុជរដ្ឋ ដោយរដ្ឋាភិបាលបាននិមន្តឲ្យមកជាប្រមុខនៃប្រតិភូទាំង១៧រូប ។ ទាំងភិក្ខុឈ្មោះ ខេមាចារ ក៏រដ្ឋាភិបាលបានចាត់ឲ្យនិមន្តមកដែរ ជាសហការីរបស់ខ្ញុំករុណា ។ បំណែកខាងបព្វជិតជាតិខ្មែរ៧រូបទៀតជាសមាជិក មានចិត្តជ្រះថ្លាក្នុងការធ្វើឆដ្ឋសង្គាយនា ក៏បានមកក្នុងទីនេះ, ទាំងគ្រហស្ថជាតិខ្មែរ៨នាក់ក៏ដូច្នោះដែរ ។ ទាំងភិក្ខុឈ្មោះខេមាចារៈ សោតក៏ដូចគ្នា ។*

*វត្ថុទាំងឡាយ មានព្រះពុទ្ធរូបឈើខ្លឹមជាដើម ដែលយើងបានលើកជូនហើយក្នុងថ្ងៃនេះ ដល់ពុទ្ធ-សាសនសភា ដើម្បីប្រយោជន៍ជាឧបករណ៍ក្នុងការធ្វើឆដ្ឋសង្គាយនា, ជានិមិត្តរូបនៃប្រទេសកម្ពុជា ។*

*បកាសនកថារបស់ខ្ញុំករុណា តែត្រឹមប៉ុណ្ណេះ ។ បន្ទាប់ពីនេះទៅ ព្រះថេរៈឈ្មោះ វីរៈធម្មវរៈ ជាជាតិខ្មែរ នឹងថ្លែងកថាប្រវត្តិជាភាសាអង់គ្លេស ដោយពិស្ដារបន្តិចទៅទៀត ។ សូមអស់លោកសប្បុរសទាំងឡាយ បើកឱកាសឲ្យលោកវីរៈធម្មវរៈ ថ្លែងដោយអាទរភាព ។*

*លុះសម្ដេចថ្លែងសេចក្ដីនេះចប់ហើយ ព្រះវីរៈធម្មវរៈមហាថេរ ក៏ថ្លែងសារលិខិតរបស់ព្រះរាជរដ្ឋាភិបាល*

ប្រទេសកម្ពុជា ជាភាសាអង់គ្លេស ដែលច្បាប់ដើមមានសេចក្តីដូចតទៅនេះ ៖



ព្រះវិរៈធម្មវិរៈមហាថេរនាមកំណើត "បៃល-ឡុង"

## សាររបស់ព្រះរាជរដ្ឋាភិបាល
## ប្រទេសកម្ពុជា

ព្រះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាលប្រទេសភូមា ដែលបានសុំអញ្ជើញប្រទេសរបស់ខ្លួនឲ្យចាត់អ្នកតំណាង២រូបមកប្រជុំក្នុងពិធីឆដ្ឋសង្គាយនាព្រះត្រៃបិដកក្នុងថ្ងៃនេះ ។ ការអញ្ជើញនេះ ជាបច្ច័យដ៏ឧត្តមដែលមានន័យស្របទៅតាមឆន្ទៈនៃព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា ដោយបានយល់ច្បាស់នូវឧត្តមប្រយោជន៍នៃការប្រោស្រ័យនេះយ៉ាងជាក់ស្តែង ទើបចាត់ដោយសោមនស្សចេតនាដ៏បរិសុទ្ធ នូវអ្នកតំណាងរបស់ខ្លួនដែលមានសម្តេចព្រះមហាសុមេធាធិបតី (ជ.ណា.ជោតញ្ញាណោ) សង្ឃនាយក ជាប្រធាន, ព្រះគ្រូសង្ឃសត្ថា (ប៉.ស. ធម្មាភោ) ជាសមាជិក ព្រមទាំងព្រះថេរៈឯទៀតនិងពុទ្ធបរិស័ទគ្រហស្ថ ឲ្យមកជាតំណាងប្រទេសកម្ពុជាដើម្បីរួមធ្វើពិធីឆដ្ឋសង្គាយនានេះ ។

ដោយយល់ច្បាស់នូវឧត្តមប្រយោជន៍នេះហើយ បានជាកាលពីពុទ្ធសករាជ ២៤៩៦ គ.ស. ១៩៥៣ ប្រទេសកម្ពុជាបាននិមន្តប្រតិភូពីររូប គឺសម្តេចព្រះមហាសុមេធាធិបតី (ជ.ណា.ជោតញ្ញាណោ) សង្ឃនាយកនិងលោក ព្រះគ្រូសង្ឃសត្ថា (ប៉.ស.ធម្មាភោ) ហើយដែលមានឧបាសក អ៊ឹង-គីមឆេង ជាវេយ្យាវច្ចករ ឲ្យមកជួយចាត់ចែងគ្រោងការនៃពិធីឆដ្ឋសង្គាយនា ។

ជាការបំពេញនូវបំណងដដែលនេះ ព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជាបានបរិច្ចាគដោយសេចក្តីសោមនស្ស នូវប្រាក់ចំនួន ៦០.០០០រៀល សម្រាប់ចាត់ការបម្លងព្រះត្រៃបិដកចំនួន ៦៥ភាគ ដែលមិនទាន់បោះពុម្ពនៅឡើយ ដើម្បីជូនប្រទេសភូមាក្នុងពិធីធ្វើឆដ្ឋសង្គាយនានៅថ្ងៃនេះ ។

ព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា មានសេចក្តីសង្ឃឹមទុកចិត្តយ៉ាងស្មោះស្ម័គ្រថា ការប្រោស្រ័យទាក់ទងខាងផ្លូវព្រះពុទ្ធសាសនា រវាងប្រទេសទាំងពីរនេះ នឹងមានដំណើរប្រព្រឹត្តទៅដោយជិតស្និទ្ធយ៉ាងប្រពៃបំផុត ។

នៅទីអវសាននេះ ប្រទេសកម្ពុជា សូមបួងសួងដល់គុណព្រះរតនត្រ័យនិងវត្ថុស័ក្តិសិទ្ធសូមឲ្យជួយអភិបាល

ក្នុងការធ្វើឆដ្ឋសង្គាយនានេះឲ្យបានប្រកបដោយសេចក្តីចំរើនជាលំដាប់ កុំបីមានឧបសគ្គអ្វីមកប៉ះពាល់ឡើយ !

ដោយកុសលកសិដ៏ឧត្តម ដែលកើតមកពីពិធីឆដ្ឋសង្គាយនានេះ សូមឲ្យពិភពលោកទាំងមូលតាំងនៅក្នុងសន្តិភាពគ្រប់ប្រទេសទាំងអស់ ហើយសូមឲ្យព្រះពុទ្ធសាសនា ឋិតនៅអស់កាល ៥០០០វស្សា !

ប្រទេសកម្ពុជា សូមទទួលអនុមោទនា ដោយចេតនាដ៏បរិសុទ្ធ ចំពោះប្រទេសភូមាដែលមានសេចក្តីយល់ត្រូវប្រកបដោយមហាកុសលជាញាណសម្បយុត្ត ក្នុងការប្រារព្ធបើកពិធីសង្គាយនានេះ ឈ្មោះថាស្ទួយព្រះពុទ្ធសាសនាឲ្យមានរស្មីរុងរឿងជាលំដាប់ ។

ភ្នំពេញ, នៅថ្ងៃទី១១ឧសភា គ.ស. ១៩៥៤

អ្នកឧកញ៉ាពិភក្តិសាសនៈ រដ្ឋមន្ត្រីក្រសួងធម្មការ

ហត្ថលេខា ៖ ឌួ-ព្រឿង

ខ) របស់ព្រះវិមលធម្ម ប្រធានគណៈប្រតិភូថៃ ជាភាសាថៃ

គ) របស់ព្រះ ព. បិយរតន ឆាយកត្ថេរ ចាងហ្វាងនៃវិទ្យាឧទយបរិវេណ (លង្កាទ្វីប)

ទី១០/- ព្រះឥន្ទាសភ មហាថេរ អគ្គមហាបណ្ឌិត ជាតិភូមា ថ្លែងតបបដិសណ្ឋារ ចំពោះសារលិខិតនិងសេចក្តីថ្លែងទាំងប៉ុន្មាន ដូចបានរៀបរាប់មកខាងលើ ។



ព្រះអភិធជមហារដ្ឋគុរុ ភទន្តរេវតញ៉ោងយ៉ាន់ សាយ៉ាឌរ ជាប្រធានសង្ឃក្នុងពិធីសង្គាយនា

ទី១១/- ព្រះអភិធជ មហារដ្ឋគុរុ ភទន្តរេវត ញ៉ោងយ៉ាន់ សាយ៉ាឌរ ឲ្យឱវាទចំពោះដំនុំសង្ឃទាំងអស់ជាភាសាបាលីនិងភូមា ។

ទី ១២/- ម៉ោង ១៤ និង ៣០ នាទី ព្រះឆាតរ៉ស មហាថេរ ប្រកាសសេចក្តីឈប់សម្រាក ១ម៉ោង ។

ស្គរស័ព្ទគងជាដើម ក៏បន្លឺឡើង ១០ អន្ទង ជាសញ្ញាលើកពេលប្រជុំ។ ក្នុងឱកាសនោះ ព្រះសង្ឃទាំងអស់ក៏ចេញទៅកាន់ទីសំណាក់ទទួលភេសជ្ជៈប៉ុស្ម្រាកតាមគាប់អធ្យាស្រ័យ ។ ចំណែកខាងឧបាសកឧបាសិកាត្រូវគេអញ្ជើញ ទៅទទួលភេសជ្ជៈ-នំ-ចំណីនៅទីជិតលោកសន្តិចេតិយដែលឋិតនៅមិនឆ្ងាយប៉ុន្មានពីទីប្រជុំ ។

ទី១៣)- ម៉ោង ១៤ និង ៣០ នាទី ស្គរគង, ជួង, ស័ង្ខ, កាំភ្លោះ ក៏គឹកកងរំពងបន្លឺឡើង លាន់ឮគ្រប់ទិសទី ជាសញ្ញាឲ្យដឹងថាដល់ម៉ោងចូលប្រជុំហើយ ក៏ចូលប្រជុំ ។

ពេលនោះព្រះញាណវិស-មហាថេរ ប្រកាសដល់មហាសន្និបាតឲ្យដឹងថា ត្រូវបើកពេលប្រជុំតទៅទៀត ។



ឧបាសក ឧបាសិកាត្រូវគេអញ្ជើញទៅទទួលភេសជ្ជៈ -នំ-ចំណី- នៅជិតលោកសន្តិចេតិយ៍ទង់រលក ដែលដោតនៅក្បែរលោកសន្តិចេតិយនេះគឺជាទង់ដែលសម្ដេចបាននាំពីប្រទេសកម្ពុជាយកទៅចូលបុណ្យ



ព្រះតិបិដកធរធម្មភណ្ឌាគារិក វិចិត្តសារាភិវំ-ស ជាវិស្សជ្ជក (អ្នកឆ្លើយ) ព្រះថេរៈអង្គនេះចាំព្រះត្រៃបិដកទាំងបីស្ទាត់មាត់ទទេបានសព្វគ្រប់

ទី ១៤)- ព្រះរេវតមហាថេរ ប្រធានសង្ឃបានសូត្រញត្តិផ្ដៀងសង្ឃ សុំតាំង ព្រះអគ្គមហាបណ្ឌិត ភទន្ត ជវន ជាបុច្ឆកៈ (អ្នកសួរ) និងព្រះតិបិដកធរធម្មភណ្ឌាគារិក ភទន្ត វិចិត្តសារាភិវំស ជាវិស្សជ្ជកៈ (អ្នកឆ្លើយ) នូវវិន័យបិដកបឋមបារាជិក ។

ទី១៥)- បុច្ឆកត្ថេរ និងវិស្សជ្ជកត្ថេរ ក៏ឡើងកាន់ថេរាសនៈរៀងរាល់អង្គៗ

ទី១៦)- បុច្ឆកត្ថេរ សូត្រផ្ដៀងសង្ឃសុំសង្ឃានុញ្ញាត ធ្វើជាអ្នកសួរ ហើយសួរបឋមបារាជិក ចំពោះវិស្សជ្ជកត្ថេរ ។

ទី១៧)- វិស្សជ្ជកត្ថេរសូត្រផ្ដៀងសង្ឃ សុំសង្ឃានុញ្ញាត ធ្វើជាអ្នកឆ្លើយ ហើយឆ្លើយនូវបញ្ហាដែលបុច្ឆកត្ថេរសួរហើយ ។

(ការសួរ-ឆ្លើយនេះ គឺសូត្រដោយមាត់ទទេ) ។

(នៅពេលបញ្ចប់ពាក្យសួរ ឆ្លើយនៃព្រះថេរទាំងពីរអង្គហើយ សង្គីតិការកសង្ឃ ២.៥០០ អង្គក៏បន្លឺសំពួសាធុការ ថា សាធុ សាធុ ព្រមគ្នាបីដងដំណាលនឹងស្គរស័ង្ខ-គង-ជួង និងរគាំងយ៉ាងទ្រហឹងអឹងអ័ព្ទ) ។

ទី១៨)-ការកសង្ឃក៏សូត្របារាជិកវេរញ្ជកណ្ឌ ចាប់តាំងពីបទបាលីថា តេន សមយេន....រហូតអស់មួយ

សង្កាត់សេចក្តី ៗ តមក ព្រះសង្ឃទាំងអស់បានសូត្របាលីបឋមបារាជិកសិក្ខាបទ ៣ បទព្រម ៗ គ្នា ។

នៅទីបំផុតមហាសន្និបាត បានបន្លឺនូវស័ព្ទសាធុការជាមួយនឹងសំឡេងគង-ឃ្មូង-ស័ង្ខ-រគាំង លាន់ឮកងរំពង ។

ទី ១៩-ព្រះនាគវិសមហាថេរ សូត្រលើកពេលប្រជុំ, សូរស័ព្ទគង-ឃ្មូង ១០ អន្ទង់យ៉ាងខ្លាំងជាសញ្ញាលើកពេលប្រជុំនៃថ្ងៃទី ១ ។

បន្ទាប់ពីពេលលើកពេលប្រជុំនោះមក គណៈប្រតិភូខ្មែរមានសម្តេចព្រះមហាសុមេធាធិបតីជាប្រធានបានប្រគល់ជូនរបស់ចូលបុណ្យ ចំពោះសង្ឃនឹងចំពោះឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ប្រទេសភូមា, របស់ទាំងនោះ គឺៈ

១-ព្រះពុទ្ធរូបនាគប្រក់ធ្វើដោយឈើខ្មឹម .................................... ១ព្រះអង្គ

២-ពិតានល្បើកនឹងហូល រចនាដោយរំកាយពណ៌ទង់សាសនាជុំវិញ .................... ៤ផ្ទាំង

៣-ហូលគ្មានរចនាដោយទង់សាសនា .................................... ២ផ្ទាំង

៤-ទង់រលកធំ ៗ .................................... ៦

៥-ទៀនក្រមួនស្ពុងយ៉ាងធំ ៗ .................................... ៧ដើម

៦-ក្លងផ្កា .................................... ៣

៧-កន្ទេលគោមនឹងកន្ទេលក្រហមលាតវែង-ខ្លី .................................... ៥៨វែង

(កន្ទេលយើងយកទៅជាង ១០០ វែង ប៉ុន្តែបានចែកប្រគេនព្រះថេរធំ ៗ ខ្លះ ដោយវិស្សាសមិត្តភាព) ។

វត្ថុទាំងនេះជាតិភូមាដញ្ញក់មាត់សរសើរមិនដាច់ ព្រោះនៅប្រទេសភូមាគេច្រើនប្រើតែកន្ទេលរុន ពុំដែលមានប្រើកន្ទេលគក់ជ្រលក់ព័ណ៌ដូចប្រទេសយើងឡើយ, ដែលគេសរសើរស្នាដៃខ្មែរយើងនោះ គឺព្រះពុទ្ធរូបនាគប្រក់នឹងកន្ទេលក្រហម ដរាបដល់រដ្ឋមន្ត្រីក្រសួងធម្មការទូលសម្តេចថា ដល់ពេលនិមន្តមកទៀត សុំឲ្យមេត្តាប្រទានព្រះពុទ្ធរូបបែបនោះ ទោះបីអង្គតូចក៏បាន ដើម្បីទុកជាបូជនីយវត្ថុផ្ទាល់ខ្លួនទាំងជាអនុស្សរណ៍វត្ថុចំពោះប្រទេសកម្ពុជាផង ។

# ពេលប្រជុំទី២

## ថ្ងៃអង្គារ ២ រោច ខែវិសាខ (១៨ ខែឧសភា)

១/ សម័យប្រជុំបើកនៅម៉ោង ១២ តត់ តាមសញ្ញាស្គរស័ព្ទគាំងជួនជាដើមដូចថ្ងៃទី ១ ។

(ព្រះធាតុវិស មហាថេរ ថ្លែងសេចក្តីជាភាសាបាលី ទឹងភាសាភូមាបើកពេលប្រជុំ)



ឯកឧត្តម អ៊ូ.នុ នាយករដ្ឋមន្ត្រីប្រទេសភូមា

២/- ឯកឧត្តម អ៊ូ. នុ នាយករដ្ឋមន្ត្រីប្រទេសភូមា ថ្លែងសេចក្តីគោរពការជឿកាន់ព្រះពុទ្ធសាសនា ទឹងការផ្សាយព្រះពុទ្ធសាសនាទូទៅក្នុងពិភពលោក ។

៣/- សារលិខិតៈ

ក) ឯកឧត្តម ដោន ទូតេឡាកាឡា នាយករដ្ឋមន្ត្រីនៃសិរីលង្កាទ្វីប អានដោយឯកឧត្តម ស.វ.អ. គាណត្តរ រដ្ឋមន្ត្រីលង្កាទ្វីប ។

ខ) ឯកឧត្តម ស្រីជវាហាល់លាល នេហ្រ៊ូ នាយករដ្ឋមន្ត្រីប្រទេសឥណ្ឌា អានដោយលោកដំតាវ វិជយលគាឌ្ឍបណ្ឌិត (ប្រធាននៃអង្គការសហប្រជាជាតិ)

គ) ឯកឧត្តម ស៊ីគេរុ យោស៊ីដា នាយករដ្ឋមន្ត្រីប្រទេសជប៉ុន អានដោយ ឯកឧត្តម យ. តាុណែគយ៉ា កុងស៊ុលធំនៃប្រទេសជប៉ុនប្រចាំប្រទេសភូមា ។

ឃ) ឯកឧត្តម ស្រីមប៉.ត្រាកាឡា នាយករដ្ឋមន្ត្រីប្រទេសនេប៉ាល អានដោយភិក្ខុអម្ឫតានន្ទ ។

ង) ឯកឧត្តម ស៊្ហីហ៊ា ហ៊ាត្តា នាយកនៃការបរិហាររដ្ឋាភិបាលកោះ ស្សៀ អានដោយ ត.ស៊្ហីតាតាហាភ ប្រធានពុទ្ធិកសមាគមកោះអូតិណា ។

ច) ចមពល ប៉.ពិបុលសង្គ្រាម នាយករដ្ឋមន្ត្រីប្រទេសថៃ អានដោយ ឧត្តមសេនីយ ចាបតាគុញ្ញ

ឆ) រដ្ឋាភិបាលប្រទេសអង់គ្លេស អានដោយ ឯកឧត្តមប៉.ហា.គោរេឲ្យ ឯកអគ្គរាជទូតប្រចាំប្រទេសភូមា ។

ទី៤/. ឯកឧត្តមសាធុសិរីសុធម្ម អ៊ូ.សេងហ៊ោង ចាងហ្វាងសាលាវិនិច្ឆ័យនៃសហភាពប្រទេសភូមា, តាំងជាប្រធានរងនៃពុទ្ធសាសនសភាផង ថ្លែងសេចក្តីគោរពស្ងើចសរសើរចំពោះកិច្ចការទឹងគោលបំណងនៃពុទ្ធ-សាសនសភា ដែលនាំឲ្យព្រះពុទ្ធសាសនាបានចំរើនរុងរឿងតទៅអនាគត ។

ទី៥)-សេចក្ដីថ្លែងរបស់ៈ

ក) ព្រះបណ្ឌិត អានន្ទមេត្តេយ្យ.មហាថេរ (លង្កាទ្វីប)

ខ) ព្រះអរិយមិត្ត មហាថេរ ប្រធានពុទ្ធិកសមាគមនៃត្រីបុររដ្ឋ (ប្រទេសឥណ្ឌា) ។

គ) ព្រះធីបង្ករ សិរីជន មហាថេរ ប្រធានពុទ្ធិកសមាគម ជិត្តាគង់ (ប្រទេសឥណ្ឌា) ។

ឃ) ព្រះ ជិនានន្ទភិក្ខុ សាស្ត្រាចារ្យ នៃពុទ្ធសាសនបណ្ឌិត្យ នៅនាលន្ទា (ប្រទេសឥណ្ឌា) ។

ង) ព្រះ ញាណាតិលោក មហាថេរ (ជាតិអល្លឺម៉ង់ ដែលបួសនៅលង្កាទ្វីប, និមន្តមកជាតំណាង ប្រទេសអល្លឺម៉ង់) ។

ច) ព្រះ ធាគត្ថេរ (ប្រទេសវៀតណាម) ។

ឆ) ព្រះគ.សិរីបញ្ញាសារ ឆាយគាត្ថេរ ចាងហ្វាងវិទ្យាលង្ការបរិវេណ ក្រុងកោឡម្បូ(លង្កាទ្វីប)។

ជ) ព្រះ បញ្ញានន្ទ មហាថេរ (ប្រទេសនេប៉ាល់) ។

ឈ) ព្រះ បណ្ឌិត ហ.សទ្ធាតិស្សត្ថេរ នៃមហាពោធិសមាគម (ប្រទេសឥណ្ឌា) ។

ញ) ព្រះ វត្តិស្សត្ថេរ ពុទ្ធិកសមាគម (ប្រទេសប៉ាគីស្ថាន) ។

ដ) ឯកឧត្តម ឌុដ្លី សេនានាយកេ ប្រធានគណៈប្រតិភូរដ្ឋាភិបាល (លង្កាទ្វីប) ។

ឋ) បណ្ឌិត ម៉ាក្នាតូណាកាយ ប្រធានគណៈប្រតិភូនៃរដ្ឋាភិបាល (ប្រទេសជប៉ុន) ។

ឌ) លោក ស្ហ៊ែរ ចាហាឌុរ ស្ហាហ៉ា ប្រធានគណៈប្រតិភូនៃរដ្ឋាភិបាល (ប្រទេសនេប៉ាល់) ។

ឍ) មហារាជកុមារ ណាមគ្យាល ប្រធានគណៈប្រតិភូនៃរដ្ឋាភិបាល (ប្រទេស ស៊ិក្កឹម) ។

ណ) ឧត្តមសេនីយ៍ ចាបតុព្ភូរ ប្រធានគណៈប្រតិភូគ្រហស្ថនៃរដ្ឋាភិបាល (ប្រទេសថៃ) ។

ទី៦)- ព្រះ ឥន្ទ្រាសភ មហាថេរ អគ្គមហាបណ្ឌិតជាតិភូមា ថ្លែងតបបដិសណ្ឋារៈ ចំពោះសារលិខិត និងសេចក្ដីថ្លែងទាំងប៉ុន្មាន ដូចបានរៀបរាប់មកហើយ ។

ទី៧)- ម៉ោង ១៤ និង ៣០ នាទី ព្រះ ជាគរ៉ីស មហាថេរ ប្រកាសសេចក្ដីឈប់សម្រាកមួយម៉ោង ។ ក្នុងឱកាសដែលលើកពេលប្រជុំសម្រាកមួយម៉ោងនោះ មានបន្ទីស្លូតគង់យ៉ាងខ្ទាំង ១ ដប់អន្ទង់ ។ ព្រះសង្ឃទាំងឡាយក៏ចេញទៅកាន់ទីសំណាក់ទទួលភេសជ្ជៈ ឬ សម្រាកតាមគាប់អធ្យាស្រ័យ ។

បំណែកខាងឧបាសក-ឧបាសិកា ត្រូវគេអញ្ជើញទៅទទួលភេសជ្ជៈនំ-ចំណី នៅទីធ្លាលោកសន្តិចេតិយ ដែលឋិតនៅមិនឆ្ងាយប៉ុន្មានពីទីប្រជុំ ។

ទី៨/- ម៉ោង១៥និង ៣១ នាទី សូរគងនិងជួងជាដើមដ៏គឹកកងរំពង ក៏បន្លឺឡើងលាន់ឮគ្រប់ទិសទី ជាសញ្ញាឲ្យដឹងថា ដល់ម៉ោងចូលប្រជុំហើយ ។

ពេលនោះព្រះធាកុំសមហាថេរ ប្រកាសបើកពេលប្រជុំតទៅទៀត ។



លោកសន្តិចេតិយ



ព្រះឧត្តមមហាបណ្ឌិត ភទន្តសោភណជាបុច្ឆក (អ្នកសួរ)

ទី៩/- ព្រះរេវតមហាថេរ (ញ៉ោងយ៉ាន់សា យ៉ាឧុវ) ប្រធានសង្ឃបានសូត្រញត្តិប្រកាសសង្ឃសុំតាំងព្រះឧត្តមមហាបណ្ឌិត ភទន្ត សោភណជាបុច្ឆកៈ និងព្រះតិបិដកធរ ធម្មភណ្ឌាគារិក ភទន្ត វិចិត្តសារាភិវំស ជាវិសជ្ជកៈ(អ្នកស្រាយឆ្លើយ) វិនយបិដកទុតិយបារាជិកា និងតតិយបារាជិកា ។

ទី១០/- បុច្ឆកត្ថេរ និងវិសជ្ជកត្ថេរ ក៏និមន្តឡើងគង់លើអាសនៈរៀងរាល់អង្គ ។

ទី១១/- បុច្ឆកត្ថេរ សូត្រថ្លែងសង្ឃសុំសង្ឃានុញ្ញាតធ្វើជាអ្នកសួរ ហើយសួរទុតិយបារាជិកា និង តតិយបារាជិកា ចំពោះវិសជ្ជកត្ថេរ ។

ទី១២/- វិសជ្ជនាត្រូវសូត្រផ្ទៀងសង្ឃ សុំសង្ឃានុញ្ញាតធ្វើជាអ្នកឆ្លើយ ទើបឆ្លើយនូវបញ្ហាដែលបុច្ឆកត្រូវសួរហើយ ។

លោកទាំងពីរអង្គនេះ បានសួរបានឆ្លើយ ដោយមាត់ទទេ តាមលំអានគម្ពីរបរិវារវិនយបិដក ដូចពីថ្ងៃមុន ។

(នៅពេលបញ្ចប់ពាក្យសួរពាក្យឆ្លើយនៃព្រះថេរទាំងពីរអង្គហើយ សង្គីតិការកសង្ឃទាំងពីរពាន់ប្រាំរយអង្គ ក៏បានបន្លឺស័ព្ទសាធុការថា សាធុសាធុព្រមៗគ្នាបីដង ដំណាលនឹងសូរស័ព្ទស័ង្ខ - គង - ប៉ូងរគាំងនឹងកាំភ្លោះយ៉ាងទ្រហឹងអឹងកង ។

ទី១៣/- ការកសង្ឃក៏សូត្រសិក្ខាបទទុតិយបារាជិកនឹងតតិយបារាជិក ព្រមៗគ្នា៣ចប់ៗ (សូត្ររឿលៗ) ។

នៅទីបំផុត មហាសន្និបាតក៏បន្លឺនូវស័ព្ទសាធុការជាមួយនឹងសំឡេងស័ង្ខ - គង-ប៉ូង-រគាំង លាន់ឮគងរំពង ។

ទី១៤/- ព្រះញាណវំសមហាថេរ សូត្រលើកពេលប្រជុំ សូរគង - ប៉ូង១០អន្ទង់ហ៊ើងគូទ់១ ខ្ទាំង១ ជាសញ្ញាលើកពេលប្រជុំនៃថ្ងៃទី ២ ។

---

## ពេលប្រជុំ ទី៣

### ថ្ងៃពុធ ៣ រោចខែពិសាខ (១៩ខែឧសភា)

ទី១/ សម័យប្រជុំបើកនៅម៉ោង១២គត់ តាមសញ្ញាសូរស័ព្ទរគាំង-ប៉ូងជាដើម ដូចថ្ងៃទី ២ ដែរ ។

(ព្រះញាណវំសមហាថេរ ថ្លែងសេចក្តីជាភាសាបាលី នឹងភាសាភូមាបើកពេលប្រជុំ)

ទី២/- ឯកឧត្តម អ៊ូ.វិន រដ្ឋមន្ត្រីក្រសួងធម្មការ ថ្លែងសេចក្តីគោរពហើយរៀបរាប់ អំពីការតង់វង្សទ្រនឹងការបំរើននៃព្រះពុទ្ធសាសនា ។

ទី៣/- សារលិខិត:

ក) ព្រះសង្ឃរាជប្រទេសលាវ អានដោយព្រះមហាប្រឌិតថេរ: លេខាធិការសមណប្រតិភូប្រទេសលាវ ។

ខ) សីលង្កា ស្វេដៀជនិកាយ អារក្ខគោសការ អានដោយព្រះពុទ្ធរក្ខិតត្ថេរ ។

គ) មហាពោធិសមាគមនៃប្រទេសឥណ្ឌា អានដោយលោកសេរី ឌ.ឌ.ឃោស្ណា អនុប្រធាននៃមហាពោធិសមាគមប្រទេសឥណ្ឌា ។

ឃ) ពុទ្ធិកសមាគមបេង្គាល (វ័ង្គ:) អានដោយលោកបណ្ឌិត អារាបិណ្ឌាចារ្យ ។

ង) ពុទ្ធិកសមាគមប្រទេសជប៉ុន អានដោយលោកនៃអូសាសតី ។

ច) ពុទ្ធិកសមាគមប្រទេសលាវ អានដោយលោក ទាំ ច័ន្ទប្រទិត ។

ឆ) សហភាពពុទ្ធិកសមាគមពិភពលោកនៃប្រទេសម៉ាឡាយ៉ា អានដោយលោក ឃូ ស៊ូ ផិង ។

ជ) ពុទ្ធសាសនសភាចិន ក្រុងប៉េគិង អានដោយលោក អ៊ូ ចា ស៊ី ។

ឈ) សមាគមឧបាសិកាប្រទេសថៃ អានដោយអ្នកស្រី ឃុន ហ្យិងរបៀប ។

ញ) ពុទ្ធិកសមាគមប្រទេសថៃ ក្រោមព្រះបរមរាជូបត្ថម្ភ អានដោយលោកបណ្ឌិតហ្លួងសុរិយពង្ស ។

ដ) យុវពុទ្ធិកសមាគមប្រទេសថៃ អានដោយអនុសេនីយឯក ប្រាសាណា ថដកត្តី ។

ឋ) មូលនិធិហ្វ៊ីជិ អានដោយលោកបណ្ឌិត ដៅ ឆស្វ៊ឹតអ៊ីវ័តុឆ ។

ឌ) ឯកឧត្តម អ.រ.ឆ.ដាយគ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលង្កាទ្វីប អានដោយឯកឧត្តមឌ.ព័ន្ធ រដ្ឋមន្ត្រីក្រសួងស័ក្យាធិការ ។

ឍ) អគ្គការនិងវរជនផ្សេងៗ ប្រកាសដោយលោក ឧ ចា ស៊ី ៖

១ - ព្រះអគ្គយតិស្សមហាថេរ នោយាជរ៍ ។

២ - មហិន្ទោសភា សមាគម ទីក្រុង ប៊ូលវវត្ត (លង្កាទ្វីប) ។

៣ - បុញ្ញវឌ្ឍនសមាគម, អម្ពលាំគោឌ, លង្កាទ្វីប ។ល។

ទី ៤/- សេចក្តីថ្លែងរបស់ ៖

ក - ព្រះអគ្គមហាបណ្ឌិត ពុទ្ធទត្ត មហាថេរ លង្កាទ្វីប ។

១ - ពុទ្ធិកសមាគមប្រទេសកម្ពុជា ព្រះវីរៈធម្មវរៈមហាថេរ ប្រែជាភាសាអង់គ្លេស ហើយថ្លែងការណ៍មានសេចក្តីក្នុងច្បាប់ដើមដូចខាងក្រោមនេះ ៖

## សេចក្តីថ្លែងការណ៍

របស់ពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគ

កម្ពុជរដ្ឋ

ក្នុងឱកាសឆដ្ឋសង្គាយនា នៅប្រទេសភូមា

---

សូមគោរពចំពោះគុណព្រះរតនត្រ័យ !

សូមជំរាបសាធុជនទាំងឡាយ ,

ភាពនេះជាលើកទី ៣ នៃការបើកពេលប្រជុំឆដ្ឋសង្គាយនា ក្នុងនាមពុទ្ធិកសមាគមមជ្ឈមណ្ឌលភូមិភាគកម្ពុជរដ្ឋ, ខ្ញុំសូមថ្លែងសេចក្ដីសរសើរដ៏ស្មោះអស់ពីដួងហឫទ័យចំពោះប្រទេសភូមា ដែលមានឧត្តមគតិដ៏ខ្ពង់ខ្ពស់បានផ្ដើមគំនិតរួបរួមពុទ្ធសាសនិកខាងថេរវាទនៅប្រទេសផ្សេង ៗ ធ្វើឆដ្ឋសង្គាយនានេះ ។ ប្រទេសកម្ពុជាមានសេចក្ដីរីករាយក្រៃលែងចំពោះកល្យាណកិច្ចនេះពន់ពេក ដោយនឹកឃើញថាប្រទេសយើងទាំងពីរមានមិត្តភាពខាងព្រះពុទ្ធសាសនាកាន់តែជិតស្និទ្ធឡើងហើយ ហើយយើងសង្ឃឹមថាមិនយូរប៉ុន្មានប្រទេសយើងនឹងមានការទាក់ទងគ្នាខាងផ្លូវនយោបាយនិងផ្លូវសេដ្ឋកិច្ចទៀត ។ គ្រាន់តែឃើញពិធីដ៏អធិកអធមមហិមានេះ យើងអាចយល់បានថាប្រទេសភូមាជារដ្ឋកាន់ព្រះពុទ្ធសាសនាដ៏មុតមាំពិតមែន នឹងមានការចងបាច់គ្នារវាងជាតិជាមួយយ៉ាងរឹងប៉ឹង ។

ក្នុងឱកាសនេះ យើងមិនបាច់រៀបរាប់អំពីសង្គាយនាក្នុងគ្រាផ្សេង ៗ ដែលមាន ៥ លើករួចទៅហើយនោះទេ ព្រោះសាធុជនដែលបានមកប្រជុំក្នុងមហាសន្និបាតនេះសឹងបានជ្រាបដែរហើយ ។ យើងគ្រាន់តែសូមបញ្ជាក់ថែមទៀតថា ហេតុអ្វីបានជាមានធ្វើសង្គាយនាក្នុងគ្រាផ្សេង ៗ រួចទៅហើយនោះ? គឺមកពីព្រះអរហន្តទាំងឡាយក្រោយដែលព្រះពុទ្ធបរមគ្រូទ្រង់បរិនិព្វានទៅ មានសេចក្ដីក្រែងបារម្ភតមកអនាគតព្រះពុទ្ធសាសនាមិនបានស្ថិតនៅគង់មាំថប់ក្រែងមានការអន្តរាយរលត់បាត់បង់ក្នុងពេលណាមួយ ; ទើបព្រះអរហន្តទាំងឡាយបានរួបរួមជាមួយឧបាសកឧបាសិកាដែលមានព្រះមហាក្សត្រជំនាន់នោះ ៗ ជាប្រមុខ ខ្វល់ខ្វាយរៀបចំធ្វើសង្គាយនា គឺផ្ទៀងផ្ទាត់តម្រឹមតម្រង់ធម៌វិន័យប្រតិស្ឋានព្រះពុទ្ធសាសនាត ៗ មករហូតដល់សព្វថ្ងៃនេះ ដូចសាធុជនបានឃើញស្រាប់ហើយ ។

អំពីអតីតកាលមកការដឹកនាំព្រះពុទ្ធសាសនាជាភារៈរបស់ព្រះអរហន្តនិងពុទ្ធបរិស័ទសម័យបុរាណទាំងឡាយ ។ ក្នុងសម័យបច្ចុប្បន្ននេះ ការដឹកនាំព្រះពុទ្ធសាសនាជាភារៈរបស់យើង ។ តទៅមុខយើងសង្ឃឹមលើពុទ្ធបរិស័ទជាន់ក្រោយ ៗ ទៅទៀត ។

ដូច្នេះការធ្វើឆដ្ឋសង្គាយនាក្នុងវាងពាក់កណ្ដាលសាសនានេះ ឈ្មោះថាយើងបានបំពេញករណីយកិច្ចជាកុលបុត្រក្នុងព្រះពុទ្ធសាសនាពេញទី, ឈ្មោះថាបានលើកតំកើងព្រះពុទ្ធសាសនា អាចរាប់បានថាជាការមួយវិសេសធំបំផុតក្នុងប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនា, គួរឲ្យយើងមានសេចក្ដីពេញចិត្តចំពោះកព្វាសនាដ៏ត្រូវកាលនេះណាស់ ។ ចំពោះការគោរពប្រតិបត្តិឲ្យត្រឹមត្រូវតាមព្រះបរមពុទ្ធោវាទ ដែលជាឧត្តមគតិធំបំផុតរបស់ពុទ្ធិក-

សមាគមពិភពលោក ធ្វើឲ្យមានឯកភាពខាងផ្លូវសាសនា ដើម្បីបំបាត់នូវការខ្វែងយោបល់រវាងអ្នកកាន់ព្រះពុទ្ធ-សាសនាជាមួយគ្នាតទៅទៀត ។

សាធុសប្បុរសទាំងឡាយ,

ដូចអស់លោកបានជ្រាបស្រាប់ហើយ, ក្នុងពិភពលោកនេះគ្មានសេចក្ដីសុខសោះ កំពុងជ្រួលច្របល់ខ្លាំងណាស់ គួរឲ្យមានសេចក្ដីតក់ស្លុតរន្ធត់ចិត្តពន់ពេក, ភ្លក់ភ្លើងមួយនេះឆាបឆួលសើរពេញលោក ហើយទើបនឹងរលត់ទៅមិនទាន់ទាំងបាត់ចំហាយផង លេចភ្លក់ភ្លើងមួយមកទៀត, តាំងនេះតើមកពីអ្វី? មកតែអំពីពិភពលោកមិនព្រមដើរតាមគន្លងព្រះពុទ្ធសាសនា ដែលជាសាសនាប្រដៅមិនឲ្យបៀតបៀនគ្នា ឲ្យចេះចែករំលែកសេចក្ដីសុខដល់គ្នាទៅវិញទៅមក ជាសាសនាមានសេចក្ដីសុខឬសន្តិភាពជាឧត្តមគតិ ។

ពិភពលោកសព្វថ្ងៃនេះ ដូចជាមនុស្សមានជម្ងឺស្រែកថ្ងូរជាឈឺ ប៉ុន្តែមិនព្រមទទួលឱសថដ៏ស័ក្ដិសិទ្ធិសោះ ម៉្លោះហើយ មានផ្លូវសះស្បើយពីណាមក!

យើងជឿជាក់ថា បើពិភពលោកនាំគ្នាដើរតាមគន្លងព្រះពុទ្ធសាសនា នោះប្រាកដជាមិនបានជ្រួលច្របល់ដូចសព្វថ្ងៃនេះទេ ។

ការលើកសង្គាយនាក្នុងគ្រានេះ ក៏ឈ្មោះថាការកសាងសន្តិភាពសម្រាប់ពិភពលោកដែរ ។

មុននឹងបញ្ចប់សេចក្ដីថ្លែងការណ៍នេះ, ដោយអានុភាពដ៏ស័ក្ដិសិទ្ធិរបស់ព្រះពុទ្ធសាសនា ដែលជាសាសនាសុខ, យើងសូមបួងសួងឲ្យពិភពលោកទាំងមូលស្ថិតនៅក្នុងសេចក្ដីសុខ កុំឲ្យមានការឃោឃាតព្យាបាទគ្នាឡើយ!

ទីបំផុតនេះ យើងសូមសំបូងសង្រួងឲ្យសត្ថុសាសនៈឋិតថេរចិរកាលដោយរុងរឿងគ្រប់៥.០០០ព្រះវស្សា!

ភ្នំពេញ, នៅថ្ងៃទី ១០ ខែឧសភា ព.ស. ២៤៩៧

ប្រធានពុទ្ធិកសមាគម កម្ពុជរដ្ឋ

ហត្ថលេខា៖ អ៊ុក-ជុប

គ) ព្រះ ជិនរក្ខិតត្ថេរ ប្រទេសឥណ្ឌូណេស៊ី ។

ឃ) លោក ហា.វ. អមរសុរិយ ប្រធានលង្កាធម្មសង្គាយនា ពាយកសង្ឃទៅលង្កាទ្វីប ។

ង) លោក ម៉ាដជិ អម្រុល់ម៉ា ប្រទេសឥណ្ឌូណេស៊ី ។

ច) លោកបណ្ឌិត អាកាបិណ្ឌាចារ្យ, ពុទ្ធិកសមាគមបេង្គាល ។

ឆ) លោក អ៊ុនចៀនបៀវ ប្រទេសឥណ្ឌូណេស៊ី ។

ជ) លោក ស៊ើរ ឌ.ច. ឃោស្ហា, មហាពោធិសមាគមប្រទេសឥណ្ឌា ។

ឈ) លោកបណ្ឌិត គ.ប. ម៉ៈ ល៉ៈ ល៉ៈ សេកោរៈ ប្រធានពុទ្ធិកសមាគមពិភពលោក ។

ញ) អ្នកស្រី យុឌហ្សិនបៀប ។

សារលិខិតនិងសេចក្ដីថ្លែងការណ៍នៃនានាប្រទេស ដែលកាន់ព្រះពុទ្ធសាសនាក្នុងពិភពលោក ដែលបានបញ្ចេញសេចក្ដីអបអរសាទរចំពោះឆដ្ឋសង្គាយនា បានបញ្ចប់ត្រឹមថ្ងៃទី ៣ នៃពេលប្រជុំធំនេះ ។

ទី ៥/- ព្រះឥន្ទាសភមហាថេរ អគ្គមហាបណ្ឌិតជាតិភូមា ថ្លែងតបបដិសណ្ឋារៈចំពោះសារលិខិតនិងសេចក្ដីថ្លែងការណ៍ទាំងប៉ុន្មាន ដូចបានរៀបរាប់មកហើយ ។

ទី ៦/- ម៉ោង ១៤ និង ៣០ នាទី ព្រះញាណវំសមហាថេរ ប្រកាសសេចក្ដី លើកពេលប្រជុំសម្រាកមួយម៉ោង ។

ពេលនោះសូរស័ព្ទគងនិងចួងជាដើម ក៏បន្លឺយ៉ាងខ្លាំង ៗ ១០ អន្លើជាសញ្ញានៃការឈប់សម្រាក ។

ព្រះសង្ឃទាំងឡាយក៏ចេញទៅកាន់ទីសំណាក់ទទួលភេសជ្ជៈ សម្រាកតាមគាប់អធ្យាស្រ័យ ។ ចំណែកខាងឧបាសកឧបាសិកាត្រូវគេអញ្ជើញទៅទទួលភេសជ្ជៈ នំ-ចំណី នាទីជិតលោកាសន្តិចេតិយ ដែលឋិតនៅមិនឆ្ងាយពីទីប្រជុំនោះ (ដូចថ្ងៃទី ១ ទី ២ ដែរ) ។

*
* *

ទី ៧/- ម៉ោង ១៥ . ៣០ នាទី សូរស័ព្ទ-គង-ចួង ក៏គឹកកងបន្លឺឡើងលាន់ឮគ្រប់ទិសទី ជាសញ្ញាឲ្យដឹងថាដល់ពេលចូលប្រជុំហើយ ។

ព្រះញាណវំសមហាថេរ ប្រកាសបើកពេលប្រជុំតទៅទៀត ។

ទី ៨/- ព្រះរេវតមហាថេរ ប្រធានសង្ឃ បានសូត្រញត្តិជៀនសង្ឃ ប្រកាសសុំតាំង ព្រះអគ្គមហាបណ្ឌិត ភទន្ត សោភណ ជាបុច្ឆកៈ និង ព្រះតិបិដកធរធម្មភណ្ឌាគារិក ភទន្តវិចិត្តសារាភិវំស ជាវិស្សជ្ជកៈ សួរឆ្លើយនូវចតុត្ថបារាជិកវិនយបិដក ។

ទី ៩/- បុច្ឆកត្ថេរ និង វិស្សជ្ជកត្ថេរ ក៏និមន្តឡើងកាន់ថេរាសនៈរៀងរាល់អង្គ ។

ទី ១០/- បុច្ឆកត្ថេរ សូត្រផ្ទៀងសង្ឃ សុំសង្ឃានុញ្ញាតធ្វើជាអ្នកសួរ ហើយសួរវិនយបិដកចតុត្ថបារាជិកចំពោះវិសជ្ជកត្ថេរ ។

ទី ១១/- វិសជ្ជកត្ថេរ សូត្រផ្ទៀងសង្ឃ សុំសង្ឃានុញ្ញាតធ្វើជាអ្នកឆ្លើយ ទើបឆ្លើយនូវបញ្ហាដែលបុច្ឆកត្ថេរ សួរហើយ ។

( នៅពេលបញ្ចប់ពាក្យសួរឆ្លើយនៃព្រះថេរៈទាំងពីរអង្គនេះហើយ សង្គីតិការកសង្ឃ ទាំង ២.៥០០អង្គ ក៏បានបន្លឺនូវសព្ទសាធុការថា សាធុ ៣ ដងព្រម ១ គ្នា តំណាលនឹងសំឡេងស័ង្ខ-គង-ប៉ូង-រគាំងយ៉ាងគ្រហឹងអឹងកង ។

ទី ១២/- ការកសង្ឃក៏សូត្រសង្គាយនចតុត្ថបារាជិក និងនិគមព្រម ១ គ្នា ។

នៅពេលបញ្ចប់ មហាសន្និបាតក៏បន្លឺសព្ទសាធុការ ជាមួយនឹងសំឡេងស័ង្ខ-រគាំងលាន់ឮកងរំពង ។

ទី ១៣/- ព្រះវិសុទ្ធមហាថេរ លេខាធិការកិត្តិយស អគ្គការបរិយាយនៃឧត្តមសភាសង្ឃ ប្រកាសសេចក្ដីសុំបែងចែកការកសង្ឃទាំងពីរពាន់ប្រាំរយអង្គ ជា ៥ ចំណែក ដើម្បីជួយបំពេញកិច្ចការនៃឆដ្ឋសង្គាយនាជា ៥ សម័យប្រជុំ ( សម័យប្រជុំនីមួយ ៗ ឲ្យបានការកសង្ឃប្រាំរយអង្គជាសមាជិក ) ។

លុះព្រះមហាថេរអង្គនេះ បញ្ចប់កថារបស់លោកហើយ មហាសន្និបាតក៏បន្លឺសព្ទសាធុការថា សាធុ សាធុ ព្រមៗ គ្នាជាមួយនឹងសំឡេងស័ង្ខ-គង-រគាំង កងរំពង ។

ទី ១៤/- លោក សាធុ មហាសិរី សិទ្ធុ អ៊ូ. ធ័នថុន អគ្គលេខាធិការកិត្តិយសនៃពុទ្ធសាសនសភា ថ្លែងសេចក្ដីគោរពនឹងកតញ្ញុតា ព្រមទាំងពរសព្ទសាធុការ ចំពោះលទ្ធផលដ៏ល្អនៃពិធីបើកសម័យប្រជុំទាំង៣ ថ្ងៃ ។

ទី ១៥/- ព្រះឧត្តរជ្ជមហាថេរ សូត្រជយមង្គលគាថា ហើយប្រកាសការបញ្ចប់ពិធីបើកសម័យប្រជុំ ។

ស្គរគង ១០ អន្ទង់យ៉ាងធ្ងន់ ៗ ខ្ទាំងៗ ជាសញ្ញាបញ្ចប់ពិធីបើកសម័យប្រជុំ ។

---

ប៊ីង-ហារ៉ា:- សារលិខិតនឹងសេចក្ដីថ្លែងរបស់អ្នកប្រទេសភូមានឹងអ្នកតំណាងប្រទេសដទៃ ១ មានចំនួនច្រើនណាស់ ខ្ញុំព្រះករុណាចង់បានចុះទុកក្នុងសម្ភាសន៍នេះខ្លះផង ព្រោះឃើញថាមានប្រយោជន៍ដល់លោកអ្នកអានច្រើន ។ សូមព្រះតេជព្រះគុណមេត្តាជ្រើសរើស ប្រែខ្លះឲ្យបាន ។

ព្រះគ្រូសង្ឃសត្ថា:- សារលិខិតនឹងសេចក្ដីថ្លែងជាភាសាអង់គ្លេសមានច្រើន ហើយសុទ្ធសឹងតែមានសារសំខាន់ គួរលោកអ្នកអានបានជ្រាបក៏ពិតមែន ប៉ុន្តែដូចលោកជ្រាបស្រាប់ហើយ, អាត្មាចេះដឹងភាសានេះ ទន់ខ្សោយ

នៅស្មើរណាស់ ប្រើបានចំពោះតែការបន្ទាប់បន្សំបន្តិចបន្តួចប៉ុណ្ណោះ មិនសមបើអាចហ៊ាន នឹងប្រែសារលិខិតឬសេចក្ដីថ្លែងរបស់រដ្ឋបុរសទាំងនោះទេ ក្រែងលោយសេចក្ដីពុំបានល្អិតល្អ នឹងនាំឲ្យខូចតម្លៃពាក្យពេចន៍របស់គេ, មួយយ៉ាងទៀត ក្រែងនាំឲ្យសម្ដាសន៍យើងវែងហួសហេតុ នាំឲ្យលោកអ្នកអាន មានសេចក្ដីធុញទ្រាន់ផង ៗ ប៉ុន្តែដើម្បីតម្រូវបំណងរបស់លោក អាត្មាសុំប្រែសម្រួលសេចក្ដីថ្លែងរបស់ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ នឹងក្រសួងផែនការជាតិ នៃប្រទេសភូមា ជូនលោកអ្នកអានតែមួយចុះ, អាត្មាបានប្រៀបធៀបមើលទៅ ឃើញថាមានតម្លៃមិនអន់ថយជាងសេចក្ដីរបស់អ្នកដទៃ ៗ ប៉ុន្មាន ហើយមិនគួររំលងចោលផង ៗ បើលោកបានជ្រាបសេចក្ដីនេះហើយ លោកអាចហៅសេចក្ដីស្មានទៅរកនិវេទនកថាទាំងពួងផងបាន ថែមទាំងបានជ្រាបការណ៍ក្នុងរឿងសង្គាយនាដោយសព្វគ្រប់ផងទៀត ព្រោះឯកឧត្តមនេះ ជារដ្ឋមន្ត្រីឧបាសក ហាក់ដូចជាអាចារ្យធំបង្អង់ ជាអ្នកចាត់ចែងក្នុងការរៀបចំធ្វើឆដ្ឋសង្គាយនា តំណាងឥស្សរជនក្នុងប្រទេសភូមាទាំងមូល មានលោកប្រធានាធិបតីនឹងលោកនាយករដ្ឋមន្ត្រីជាដើម ៗ លោកប្រធានាធិបតីនឹងលោកនាយករដ្ឋមន្ត្រីគ្រាន់តែថ្លែងបង្គ្រប់ការ ពុំបានអស់អាថ៌ដូចលោករដ្ឋមន្ត្រីក្រសួងធម្មការនេះទេ ៗ ប៉ុន្តែអាត្មាសូមបញ្ជាក់ថា អាត្មាពុំបានប្រែផ្ដិតទេ គឺប្រែសម្រួលយកតែសេចក្ដី ហើយទុកណាជាដូច្នោះ ក៏អាត្មាមិនហ៊ានរំលងការសូមអភ័យចំពោះលោកអ្នកអានដែរ ក្រែងលោមានបើក្លាំងក្លាត់ខុសចាកសេចក្ដីច្បាប់ដើមខ្លះនោះ សូមមេត្តាកុំរិះគន់ ព្រោះពុំមែនជាអំនួតអួតអាងទេ គឺជាការខំប្រឹងទាំងទើសទាល់ដោយពិត ៖



ឯកឧត្តម អ៊ូ-វិន រដ្ឋមន្ត្រីក្រសួងធម្មការ
នឹងក្រសួងផែនការជាតិ

## សេចក្ដីថ្លែងរបស់ ឯកឧត្តម អ៊ូ-វិន រដ្ឋមន្ត្រីក្រសួងធម្មការ នឹងក្រសួងផែនការជាតិ

បំពោះ

ព្រះមហាថេរ ជាប្រមុខសង្ឃ

នឹង

ព្រះសង្គីតិការកមហាថេរទាំងអស់ ៗ

បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ

" មុននឹងថ្លែងអ្វីពីអ្វី ៗ ផងទៃ, ខ្ញុំព្រះករុណាសូមប្រកាសដោយសេចក្ដីរីករាយដ៏ត្រកាល នឹងសេចក្ដីគោរពដ៏ជ្រាលជ្រៅថា ពេលនេះ

រាប់ថាជាសម័យប្រកបដោយសេចក្ដីសុខនិងជោគជ័យចុះព្រោះពេលល្អ ដែលគួរចារិកទុកថាជាអនុស្សរណកាលដ៏ប្រសើរមួយក្នុងប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនា ហើយបើតាមដោយពិតនោះ គឺក្នុងប្រវត្តិសាស្ត្រនៃពិភពលោកតែម្ដង ។

“បពិត្រ ព្រះករុណាដ៏ចំរើនទាំងឡាយ, ពិធីប្រជុំធ្វើសង្គាយនាទីមួយ ៗ ជាការៈមួយដ៏កម្រ ពាំនដ៏ពិក្រៃលែងផង, ដែលនឹងអាចសម្រេចបាន លុះត្រាតែយើងអាចហ៊ានពុះពារឈ្នះឧបសគ្គនិងសេចក្ដីទុក្ខលំបាកគ្រប់យ៉ាង ។ កាលដែលយើងខ្ញុំព្រះករុណាបានផ្ដើមគិតនឹងធ្វើឆដ្ឋសង្គាយនានេះ, យើងខ្ញុំព្រះករុណានៅមានសេចក្ដីព្រួយបារម្ភក្រែងលោមិនបានសម្រេចសមដូចបំណងផង ក្រែងលោមិនអាចរកសង្គីតិការកភិក្ខុសូម្បីតែមួយពាន់អង្គបានផង ។ ស្រាប់តែមកដល់ឥឡូវនេះ, ដែលជាពេលផ្ដើមធ្វើពុទ្ធសាសនមហាសន្និបាតសម័យបច្ចុប្បន្ន នោះខ្ញុំព្រះករុណាក៏មានចិត្តពោរពេញដោយបីតិសោមនស្ស ព្រោះបានឃើញថាមានភិក្ខុពាំនពាន់ ៗ អង្គជាអ្នកបានរៀនសូត្រចេះចាំព្រះត្រៃបិដក ហើយសុទ្ធតែជាអ្នកអាចនឹងចូលមករួមប្រជុំធ្វើពិធីឆដ្ឋសង្គាយនាបានទាំងអស់ ។ បណ្ដាភិក្ខុរាប់ពាន់អង្គទាំងនេះ យើងបានសុំជ្រើសរើសយកតែត្រឹម ២.៥០០ អង្គ ធ្វើជាសង្គីតិការកៈ, ចំនួននេះ ជាការរលឹកដល់ព្រះពុទ្ធសករាជទី ២.៥០០វស្សា រាប់តាំងពីពេលដែលព្រះបរមសម្ពុទ្ធទ្រង់រលត់ខន្ធ ចូលកាន់មហាបរិនិព្វានមក ។ ក្រៃលែងជាងនេះទៅទៀតនោះ គឺក្នុងពេលដែលខ្ញុំព្រះករុណាបានឃើញព្រះតេជព្រះគុណគ្រប់ព្រះអង្គក្នុងថ្ងៃនេះ មានការស្លៀកដណ្ដប់សម្ពត់អម្ពត់ពណ៌លឿងប្រាល ហើយគង់តាមលំដាប់លំដោយមានអាការកិរិយារៀបរយថ្លៃថ្នូរ ប្រាកដដូចជាព្រះអរហន្តអំពីសម័យបុរាណដែលជាសិស្សសាវកផ្ទាល់នៃព្រះសព្វញ្ញុពុទ្ធ នាំឲ្យខ្ញុំព្រះករុណានឹកគិតខ្លួនឯងថា ក្នុងពេលសង្គាយនាអំពីមុនៗ, ព្រះអរហន្តទាំងឡាយ សុទ្ធសឹងតែបានប្រព្រឹត្តអាការកិរិយាមានរបៀបរៀបរយហើយសមរម្យថ្លៃថ្នូរបែបដូច្នេះដែរ, ហើយខ្ញុំព្រះករុណាសូមលំអុតលំអោនគោរពយ៉ាងជ្រាលជ្រៅចំពោះព្រះតេជព្រះគុណគ្រប់ព្រះអង្គ ដោយសេចក្ដីរីករាយចិត្តសោមនស្សពន់ប្រមាណ - ក្នុងមួយជីវិតរបស់ខ្ញុំព្រះករុណានេះ, ពីមុន ៗ មកមិនដែលបានជួបប្រទះនឹងសេចក្ដីរីករាយចិត្តសោមនស្សបែបនេះទេ ។

“ពុទ្ធសាសនមហាសន្និបាតសម័យបច្ចុប្បន្ន ដែលព្រះករុណាគ្រប់ព្រះអង្គបាននិមន្តមករួមប្រជុំនេះ ជាសង្គាយនាមួយគំរប់ប្រាំមួយលើក រាប់តាំងពីពេលដែលព្រះសម្ពុទ្ធមកុដគតត្រៃ ចូលកាន់មហាបរិនិព្វានមក ។ ខ្ញុំព្រះករុណាជឿជាក់ថា ព្រះមហាក្សត្រព្រមដោយនាម៉ឺនមុខមន្ត្រីសេនាមាត្យ នឹងអាណាប្រជានុរាស្ត្រ ដែលជារាជូបត្ថម្ភ៍, ជាអ្នកឧបត្ថម្ភ៍ក្នុងពេលសង្គាយនាពីមុន ៗ នោះ សុទ្ធសឹងតែមានចិត្តពោរពេញដោយសេចក្ដីរីករាយ

សប្បាយដីក្រៃលែង ប្រាកដដូចយើងខ្ញុំព្រះករុណាក្នុងសម័យនេះដែរ ។

“បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ, ព្រះបរមគ្រូទ្រង់បរិនិព្វានទៅបាន ៣ ខែ ៤ ថ្ងៃ, (១) ព្រោះហេតុតែពាក្យបម្រួលបម្រះនៃសុភទ្ទភិក្ខុដែលចូលមកបួសឯចាស់ នោះព្រះអរហន្តចំនួនប្រាំរយព្រះអង្គមានព្រះមហាកស្សបត្ថេរជាប្រមុខ បានប្រជុំធ្វើបឋមសង្គាយនាក្នុងវិហារមួយដែល ព្រះចៅអជាតសត្រូវ ទ្រង់កសាងមិនជាទីស្ថិតស្ថេរយូរប៉ុន្មាន ក្នុងសត្តបណ្ណិគុហា នាជើងភ្នំវេភារៈក្នុងក្រុងរាជគ្រឹះ (សម័យបច្ចុប្បន្នហៅថា រ៉ាជ៉ិគីរ៍ ) ។ សង្គាយនានោះ ធ្វើអស់រយៈកាល ៧ ខែ ។ យើងខ្ញុំព្រះករុណាសូមរំលឹកគុណព្រះអរហន្តក្នុងអតីតកាលដែលមានអានុភាពនិងគុណធម៌ បានប្រជុំធ្វើសង្គាយនាក្នុងពេលមុន ៗ ដើម្បីផ្ទៀងផ្ទាត់បង្ក្រងព្រះពុទ្ធវចនៈទាំងអស់ឲ្យមានរបៀបរៀបរយទុកមក ។ បើកុំតែបានទស្សនាហានភាពនៃព្រះអរហន្តទាំងនោះព្រះពុទ្ធសាសនាប្រហែលជាវិនាសសាបសូន្យបាត់អស់ទៅហើយ, ឬបើទុកជាមិនដល់ដូច្នោះ ក៏ព្រះពុទ្ធសាសនាគង់ស្ថិតនៅក្នុងភាពៈដែលមិនមានរបៀបរៀបរយដែរ ។ ប្រសិនបើព្រះសង្គីតិការកអរហន្តពីបូរាណ កាលពុំបានបង្ក្រងរៀបចំព្រះពុទ្ធវចនៈ នោះទេសមព្រះពុទ្ធសាសនាទៅជាពាក្យច្រឡំបល់អស់សន្ធឹម, ព្រះធម៌នឹងច្របូកច្របល់ជាមួយនឹងព្រះវិន័យ ហើយព្រះពុទ្ធវចនៈទាំងប៉ុន្មានក៏នឹងទៅជាពាក្យធ្វូកធ្វាស់ពីលើពីក្រោមឥតរបៀប នាំឲ្យមនុស្សលោកទៅជាអ្នកមិច្ឆាទិដ្ឋិក៍ធ្លាក់ចុះក្នុងទីដ៏ថោកទាបក្រៃលែងព្រោះដំណើរនោះពុំខាន ។ ដោយហេតុដូចខ្ញុំព្រះករុណាបានថ្លែងមកនេះ ការប្រជុំធ្វើសង្គាយនាគ្រប់គ្រា ដូចជាក្នុងសម័យបច្ចុប្បន្ននេះ អាចឲ្យឈ្មោះបានថាជា “ព្រលឹង” នៃព្រះពុទ្ធសាសនា ទាំងជាការស្រោចស្រង់សត្វលោកឲ្យរួចផុតចាកកំណើតក្នុងពិភពលោកដ៏ថោកទាបផង ។

“គ្រាទីពីរ, មួយរយវស្សាក្រោយព្រះពុទ្ធមហាបរិនិព្វាន, ពួកវជ្ជីបុត្តកភិក្ខុជាតិអ្នកក្រុងវេសាលី បានលើកឡើងនូវវត្ថុ ១០ ប្រការក្រៅចាកព្រះវិនយបញ្ញត្តិ ដែលជាហេតុនាំឲ្យកើតទុតិយសង្គាយនាឡើង ។ សង្គាយនាគ្រាទី ២ នេះ ជាការប្រជុំនៃព្រះអរហន្ត ៧០០ ព្រះអង្គមានព្រះយសមហាថេរជាប្រធាន ប្រជុំធ្វើនៅវាលុការាមក្នុងក្រុងវេសាលី អស់រយៈកាលចំនួន ៨ ខែ ដោយមាន ព្រះចៅឧកាលាសោក ជាព្រះបរមរាជូបត្ថម្ភ ។

“ក្នុងពុទ្ធសករាជ ២៣៥ វស្សា, ព្រោះហេតុតែមានពួកនិគ្រន្ថអន្យតិរ្ថិយអ្នកក្រុងបាតលីបុត្រ (សព្វថ្ងៃហៅថា បត្នៈ) ចំនួនប្រាំមួយម៉ឺនរូប ចូលមកបន្លំបួសបួមក្នុងព្រះពុទ្ធសាសនា ក៏កើតមានតតិយសង្គាយនាឡើង ។

(១) យើងធ្លាប់បានដឹងមកថា ត្រឹមតែ ៣ ខែគត់ ដ្បិតបឋមសង្គាយនានោះលោកចាប់ផ្ដើមធ្វើនៅថ្ងៃ ១ រោច ខែស្រាពណ៍ ឆ្នាំម្សាញ់, ចប់ស្រេចនៅថ្ងៃ ១៥ កើត ខែផល្គុន ឆ្នាំដដែល (រួមរយៈកាល ៧ ខែ) ។

សង្គាយនាទី ៣ នេះ ជាការប្រជុំនៃព្រះអរហន្តមួយពាន់ព្រះអង្គ មានព្រះមហាមោគ្គលីបុត្តតិស្សត្ថេរជាប្រធាន នៅក្រុងបាតលីបុត្រអស់រយៈកាលចំនួន ៩ ខែ ដោយមានព្រះចៅធម្មចក្រពត្រាធិរាជព្រះនាមអសោក ជាព្រះបរមឧបត្ថម្ភ ។ មុននឹងផ្ដើមធ្វើសង្គាយនានេះ ព្រះមោគ្គលីបុត្តតិស្សត្ថេរបាននិពន្ធសេចក្ដីអធិប្បាយក្នុងកថាវត្ថុ (រឿងរ៉ាវទាក់ទងដោះស្រាយ ១០០០ សូត្រ) យ៉ាងពិស្ដារក្នុងកណ្ដាលទីមហាសន្និបាតជាច្រើនគ្រា ដើម្បីនឹងបំបាត់ការយល់ឃើញនៃពួកមិច្ឆាទិដ្ឋិ ។ តាំងពីពេលនោះមក គម្ពីរកថាវត្ថុដែលជាបករណ៍វិសេសមួយ បណ្ដាព្រះអភិធម្មទាំង៧គម្ពីរ ក៏ប្រាកដដល់យើងរាល់គ្នាឡើង ។

“បួនរយហាសិបវស្សា ក្រោយព្រះពុទ្ធមហាបរិនិព្វាន ព្រះមហាថេរអ្នកប្រតិពលឈ្លាសវៃជាច្រើនព្រះអង្គ មានព្រះធម្មរក្ខិតមហាថេរ និង សិទ្ធិវិហារិក-អន្តេវាសិក របស់លោកជាដើម បានជ្រាបជាក់ថាពុទ្ធសាសនិកជនក្នុងអនាគតកាល មុខជានឹងយល់ល្អៀងល្អៀងឃ្លាតចាកព្រះធម្មវិន័យទន់ខ្សោយខាងការចេះចាំពុំខាន, ទើបលោកបានប្រជុំគ្នានៅទីអាលោកគុហា (សម័យបច្ចុប្បន្ន ហៅថាអាលុវិហារ) ក្នុងភូមិឈ្មោះ មាលយៈ, លង្កាទ្វីប ក្នុងរជ្ជសម័យនៃ ព្រះចៅវដ្ដគាមិនី, ហើយលោកបានចារឹកទុកជាគម្ពីរស្លឹករឹតប្រយោជន៍ឲ្យព្រះពុទ្ធវចនៈទាំងអស់បានស្ថិតស្ថេរដរាបមក ។ គម្ពីរសារត្ថទីបនី ត្រង់តិកបរិវារៈ បានបញ្ជាក់ឲ្យយើងយល់ច្បាស់ថា គម្ពីរពុទ្ធវចនៈទាំប៉ុន្មាន សុទ្ធសឹងតែជាលទ្ធផលនៃសង្គាយនាគ្រាទី ៤ នេះទាំងអស់ ។ ព្រោះហេតុតែគម្ពីរទាំងអស់នេះជាព្រលឹងនៃព្រះពុទ្ធសាសនាយ៉ាងនេះហើយ បានជាដរាបមកដល់សព្វថ្ងៃនេះយើងឃើញសេចក្ដីចម្លងនៃព្រះពុទ្ធវចនៈក្នុងគម្ពីរស្លឹករឹត-ក្នុងផ្ទាំងថ្មកែវ នឹងសៀវភៅបោះពុម្ពនៅគ្រប់ប្រទេសពុទ្ធសាសនិកថេរ-វាទី គឺថៃ, លង្កា, ភូមា, កម្ពុជា នឹងលាវ ។ ព្រោះតែមានលំអាននៃសង្គាយនាគ្រាទី៤នៅលង្កាទ្វីបដែលជាគ្រឹះនៃការផ្សាយព្រះពុទ្ធសាសនាបែបនោះហើយ បានជាពេលនេះយើងអាចប្រជុំធ្វើពិធីឆដ្ឋសង្គាយនាក្នុងមហាបាសាណគុហា ដែលប្រទេសពុទ្ធសាសនិកថេរវាទី គ្រប់ទាំងអស់ (ក្នុងពិភពលោក) គឺថៃ, លង្កា, ភូមា, កម្ពុជា នឹងលាវជាដើម បានមកជួបជុំរួមដៃគ្នាពិនិត្យពិចារណាធ្វើសហប្រតិបត្តិការចាប់បន្តការងារនោះ ។

“ក្រោយព្រះពុទ្ធមហាបរិនិព្វានបានចំនួន ២.៤១៥វស្សា, សង្គាយនាទី៥ក៏កើតមានឡើង នៅក្នុងព្រះបរម-រាជវាំងព្រះចៅ មិនដុង រាជធានី មណ្ឌលេ (ប្រទេសភូមា) ។ បញ្ចមសង្គាយនានេះ មានភិក្ខុសង្ឃចំនួន ២.៤០០អង្គ បានប្រជុំធ្វើក្រោមអធិបតីភាពនៃព្រះសុធម្មមហាថេរ៨ ព្រះអង្គ អស់រយៈកាល ៦ខែ ។ បើទុកណាជាយើងពុំមានប្រវត្តិការណ៍អ្វីមួយចង្អុលប្រាប់ហេតុឲ្យដឹងបានថា ហេតុម្ដេចបានជាមានការប្រជុំធ្វើបញ្ចមសង្គាយនា

នោះ? គឺគន់យើងមានវិចារណញ្ញាណសព្វគ្រប់ល្មមជឿបានថា សង្គាយនានេះ បានកើតមានឡើងដើម្បីកំចាត់ព្រមទាំងបំបាត់ពួកអធម្មវាទី និងពួកពាហិរសាសនិក ហើយផ្ទៀងពិនិត្យបាលីព្រះពុទ្ធវចនៈប៉ុណ្ណោះឯង ។

“ចំពោះការកំចាត់បង់ពួកអ្នកមិនមានសីលធម៌ (អ្នកមានសន្តានចិត្តបាប) និងពួកពាហិរសាសនិកនេះ យើងឃើញជាក់ក្នុងព្រះរាជសាសន៍ជាផ្លូវការ ដែលព្រះចៅ មិនដុង ទ្រង់បានថ្លែងប្រកាស ក្នុងថ្ងៃ ១០ កើត ខែមាឃ ចុល្លសករាជ ១.២១៧ មានសេចក្តីថា “ មនុស្សពុំមានសីលធម៌, ជាអ្នកមានសន្តានចិត្តបាបតែម្នាក់ គឺអាចបង្កបង្កើតឲ្យមានមនុស្សមានសភាពដូចគ្នានេះ ចំនួនមួយពាន់នាក់ ហើយបំផ្លាញព្រះពុទ្ធសាសនាបាន ” ។

“ព្រះរាជសាសន៍នេះ ត្រូវត្រង់នឹងបទបាលីក្នុងអដ្ឋកថាបារាជិកថា: “ ឯកោ អលជ្ជី អលជ្ជីសតម្បិ ករោតិ ” ដែលជាទុកចិត្តនាំយើងឲ្យយល់ច្បាស់ថា គួរតែរម្ងាប់បង្រាបបង្រាមបំបាត់មនុស្សពុំមានសីលធម៌ និងពួកពាហិរសាសនិកចេញ ដើម្បីនឹងស្តួនគ្រងរក្សាព្រះពុទ្ធសាសនាឲ្យនៅគង់វង្សល្អតទៅបាន ។

“ពេលនេះ, ចំពោះការរើពិនិត្យបាលីព្រះពុទ្ធវចនៈ, យើងបានឃើញតាមការរបស់ព្រះមហាថេរដែលបានពិនិត្យផ្ទៀងផ្ទាត់ព្រះបាលីពុទ្ធវចនៈហើយ, ចំពោះឆដ្ឋសង្គាយនានេះយើងមានចំណុចសំខាន់បីប្រការគឺ៖

(១) ការបោះពុម្ពផ្សាយ, ការបោះពុម្ពផ្សាយនិងការពិនិត្យផ្ទៀងផ្ទាត់យ៉ាងហ្មត់ចត់ នូវបាលីព្រះពុទ្ធវចនៈ;

(២) ការផ្សាយនូវព្រះត្រៃបិដក ដែលបានរើពិនិត្យបោះពុម្ពជាថ្មីហើយ ទូទៅពេញពិភពលោក;

(៣) បំណងយ៉ាងមាំនៃប្រជាជននៅសហភាពប្រទេសភូមា និងប្រទេសពុទ្ធសាសនិកទាំងអស់ ចំពោះការស្តួនគ្រងនូវព្រះពុទ្ធសាសនា ។

“ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ ការរើពិនិត្យផ្ទៀងផ្ទាត់បាលីព្រះពុទ្ធវចនៈ មានប្រយោជន៍សំខាន់យ៉ាងណានោះ មិនមែនជាកិច្ចការរបស់យើងខ្ញុំព្រះករុណាជាគ្រហស្ថទេ ប៉ុន្តែខ្ញុំព្រះករុណាក៏មិនមានបំណងនឹងប្រគល់ភារៈទាំងមូលប្រគេនព្រះតេជព្រះគុណគ្រប់ព្រះអង្គដែរ ។ មួយយ៉ាងទៀត បំណងដ៏ខ្ពង់ខ្ពស់របស់យើង គឺការផ្សាយព្រះពុទ្ធសាសនាទូទៅពេញពិភពលោកនោះ យើងខ្ញុំព្រះករុណានឹងលើកទម្លាក់ទៅលើតែព្រះតេជព្រះគុណគ្រប់អង្គទាំងអស់ក៏ទេដែរ ។ ចំពោះចំណុច ៣ ខ្ញុំព្រះករុណាសូមសង្ឃានុញ្ញាតពោលថា ខ្ញុំព្រះករុណាយល់ថាពាក្យដែលថា “ ស្តួនគ្រងរក្សា ” និងពាក្យថា “ ឧបត្ថម្ភ ” មានអត្ថាធិប្បាយផ្សេងគ្នាស្រឡះ ។

“បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ ដូចជាយើងចង់បណ្តុះដាំកូនឈើមួយដើម បើយើងគ្រាន់តែស្រោចទឹកចាក់ដីរាប់ប៉ុណ្ណោះនោះនៅមិនទាន់ល្មមគ្រប់គ្រាននៅឡើយទេ; ត្រូវតែយើងរក្សាការពារចំពោះគ្រោះថ្នាក់

ជិតៗគ្រប់បែបគ្រប់យ៉ាងដូចជាអាកាសធាតុដ៏ក្លាខ្លាំងនឹងការបៀតបៀនសត្វចតុប្បាទជាដើមថែមទៀតផង ។ ពាក្យថា "ឧបត្ថម្ភ" បានសេចក្ដីថាជំនួយទាំងផ្លូវកាយ ទាំងផ្លូវចិត្ត បើពោលឲ្យច្បាស់ក៏គឺស្នងគ្រងរក្សាព្រះពុទ្ធសាសនា ហើយត្រូវតែកំចាត់ពន្លិចបង្កប់ពួកពាហិរសាសនិក នឹងពួកអធម្មវាទីពុំមានសីលធម៌ ដែលប្រៀបដូចជាបញ្ញើ-វក្ខុក្ខដង្កូវនៃព្រះពុទ្ធសាសនាឲ្យវិនាសអស់ចេញ ។ ខ្ញុំព្រះករុណាធ្លាប់បានរៀនសូត្របេះដឹងមកថា "ត្រូវគោរពបុគ្គលដែលគួរដល់ការគោរព ប៉ុន្តែត្រូវនិន្ទាគ្រះតិះដៀលចំពោះបុគ្គលដែលគួរដល់ការនិន្ទាគ្រះតិះដៀលដែរ"; នេះជាកំពូលកត្តាក្នុងការស្នងគ្រងរក្សាព្រះពុទ្ធសាសនា ។

"បពិត្រ ព្រះករុណាដ៏ចំរើនទាំងឡាយ, ក្នុងប្រវត្តិសាស្ត្រ មានរឿងរ៉ាវដំណាលថា ព្រះចៅអនុរុទ្ធនៅពុកាមធានីថាំក្រាង ទ្រង់បានចាត់វិធានការយ៉ាងតឹងរ៉ឹងតទល់នឹងអរីក្នុងរជ្ជសម័យរបស់ព្រះអង្គ ដើម្បីស្នងគ្រងរក្សាព្រះសាសនា ។ ព្រះចៅ មិញ្ជុងគ្យិ នៅពុកាមធានីអាក៉ាំង ក៏ដូចគ្នា ទ្រង់បានដាក់វិធានការយ៉ាងខ្លាំងតទល់នឹងប្រជាជនដែលជាអធម្មវាទីពុំមានសីលធម៌ នឹងពួកពាហិរសាសនិកដែរ ។ ក្នុងរជ្ជសម័យនៃព្រះចៅ ម្វុវ៉បយៈ ក៏ដែរ, ពួកព្រះសុធម្មមហាថេរ បានចាត់ការតទល់នឹងព្រះអតុល យសសាយ៉ា ឲ្យនឹងសិស្សគណរបស់លោក ព្រោះហេតុតែសេចក្ដីប្រតិបត្តិក្រៅចាកធម្មវិន័យ ។

"ចំពោះពួកសាសនទាយក (សាសនូបត្ថម្ភក៍) ដែលខ្ញុំព្រះករុណាបានរៀបរាប់មកខាងលើនេះ គឺសុទ្ធតែជាអ្នកគ្រប់គ្រងប្រទេសប្រើអំណាចផ្ដាច់ការ ជាអ្នកអាចដាក់វិធានការយ៉ាងតឹងរ៉ឹង ហើយដាក់ទោសទណ្ឌកម្មដ៏គេរពផង ។ ឥឡូវប្រទេសយើង បានត្រឡប់ជាប្រទេសប្រជាធិបតេយ្យមួយទៅហើយ យើងមិនអាចចាត់វិធានការដូចអ្នកគ្រប់គ្រងប្រទេសប្រើអំណាចផ្ដាច់ការទាំងនោះបានទេ ។ តាមដោយពិត ការកិច្ចនៃការស្នងគ្រងរក្សាព្រះពុទ្ធសាសនាមិនពេញជាមុខងារនាទីគួរទៅដល់គ្រហស្ថទេ ។ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ ប្រសិនបើព្រះសង្ឃយកព្រះទ័យទុកដាក់ក្នុងរឿងរ៉ាវនេះ ហើយបំពេញករណីយកិច្ចរបស់ខ្លួនឲ្យសព្វគ្រប់នោះ ក៏ជាការល្មមគ្រប់គ្រាន់ទៅហើយ ខ្ញុំព្រះករុណា បានឮថាបណ្ឌិតបូរាណតែងបានពោលជូនពរបីផងថា "លជ្ជី រក្ខិ សប្បតិ" ពាក្យនេះនាំឲ្យយើងយល់ច្បាស់ថា អ្នកប្រាជ្ញត្រូវរក្សាថែជួនព្រះពុទ្ធសាសនា ។ ព្រោះហេតុនោះ ខ្ញុំព្រះករុណាយល់ថា ប្រសិនបើព្រះសង្គីតិការកមហាថេរទាំងអស់ ដែលបាននិមន្តមករួបរួមប្រជុំក្នុងពិធីសង្គាយនាដ៏សមប្រកបនឹងកាលសម័យយ៉ាងក្រៃលែងនេះ ពួតដៃធ្វើសហការបំពេញភារកិច្ចតទល់ចំពោះពួកអ្នកពុំមានសីលធម៌នឹងពួកពាហិរសាសនិកបំបិទមាត់អ្នកទាំងនោះ ដោយការប្រកាសអាណត្តិដ៏សមគួរទៅ ប៉ុណ្ណោះក៏សមល្មមនឹងគោល

បំណងយើងហើយ ។ យើងខ្ញុំព្រះករុណាជឿជាក់ថា ប្រសិនបើព្រះតេជព្រះគុណគ្រប់ព្រះអង្គនឹងបញ្ចេញទបន័យហើយ យើងខ្ញុំព្រះករុណាអាចជ្រោមជ្រែងប្រើវិធានការប្រកបដោយអំណាច ជួយជាកំឡាំងដល់ព្រះមហាថេរជានាយកបានយ៉ាងស្រួល ។

“ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ, ក្នុងរជ្ជសម័យនៃព្រះចៅធម្មចេតិយ នៅរាជធានី ប៉េគូ, ព្រះមហាថេរក្នុងសម័យនោះ ចុះនរួបរួមគ្នា កំចាត់ពួកមិច្ឆាទិដ្ឋិកៈឲ្យវិនាសសមដូចព្រះរាជបំណងបាន ។ រឿងរ៉ាវនេះមានចែងទុកនៅនាកល្យាណីសិលាចារឹកជាភស្តុតាង ។

“ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ, ក្នុងពេលដែលប្រទេសភូមាស្ថិតនៅក្រោមការត្រួតត្រានៃជនបរទេសអស់រយៈកាលជាច្រើនឆ្នាំមកនេះ, ព្រះពុទ្ធសាសនាក៏អាប់ឱនស្មើដូចជាព្រះអាទិត្យឬព្រះចន្ទ្រ ត្រូវរាហូ-អសុរិន្ទចូលមកបៀតបៀនដែរ ។ ក្នុងពេលដែលសាសនូបត្ថម្ភកបុគ្គលណាមួយមិនហ៊ានចេញមុខមកនេះ ព្រះពុទ្ធសាសនាក៏ធ្លាក់ចុះក្នុងលក្ខណ៍ណាមិនមានរបៀបដែរ, ឥឡូវនេះ គឺជាពេលដែលព្រះតេជព្រះគុណគ្រប់ព្រះអង្គត្រូវជួយស្រង់ព្រះពុទ្ធសាសនាឲ្យផុតអំពីភក់ជ្រាំនោះហើយ ។ ព្រោះហេតុនោះ ខ្ញុំព្រះករុណាសូមអង្វរករយ៉ាងសុំសុភាពព្រមទាំងដោយគោរព, សូមព្រះតេជព្រះគុណមេត្តាអភ័យទោស, ខ្ញុំព្រះករុណាសូមណែនាំ, សូមព្រះតេជព្រះគុណប្រតិបត្តិការឲ្យយ៉ាងខ្លាំង ហើយឲ្យយ៉ាងសំខាន់បំផុតចំពោះពួកដង្កូវនៃព្រះពុទ្ធសាសនា ។ ខ្ញុំព្រះករុណាអាចបញ្ជាក់ថា ព្រះតេជព្រះគុណអាចធ្វើដោយទទួលខុសត្រូវគ្រប់យ៉ាងក្នុងការប្រើវិធានការបែបនេះបាន ដោយសមធម៌, យុត្តិធម៌និងសម្បជញ្ញៈដ៏ល្អក្នុងព្រះបរមនាមនៃព្រះសម្ពុទ្ធ ។ ព្រះតេជព្រះគុណ, ប្រសិនបើព្រះតេជព្រះគុណផ្គងនឹងយកទបន័យនេះហើយ, ខ្ញុំព្រះករុណាក្នុងឋានៈជារដ្ឋមន្ត្រីក្រសួងធម្មការ, សូមសន្យាថា ចំណែកខាងយើងខ្ញុំព្រះករុណា ក៏នឹងប្រគេនជំនួយយ៉ាងមាំបំផុតដែរ ។

“ តាមលំអានប្រវត្តិនៃសង្គាយនាពីមុនៗ ទាំង ៥ គ្រា យើងឃើញច្បាស់ថា លើកលែងតែសង្គាយនាគ្រាទី ៤ ចេញ សង្គាយនាក្រៅពីនេះ សុទ្ធសឹងតែបានកើតឡើងដើម្បីសង្កត់ពន្ធិចន្ទូរប្រជាជនដែលមិនមានសីលធម៌និងពួកពាហិរសាសនិកឲ្យវិនាសចេញទាំងអស់ ។ សហភាពប្រទេសភូមា មានឈ្មោះសំឡេងថាជាប្រទេសមួយដែលមានព្រះពុទ្ធសាសនារុងរោចន៍ចំរើនចំណាច ប៉ុន្តែនៅទីណាមានរបស់បរិសុទ្ធ នៅទីនោះគេនឹងឃើញរបស់ក្លែងក្លាយផងដែរ នេះស្មើរតែជាទំនៀមធម្មតាដ៏ទៀងទាត់ ។ ព្រះតេជព្រះគុណជ្រាបស្រាប់ហើយចំពោះរឿងនេះថា សូម្បីតែក្នុងសម័យនៃព្រះអរហន្តវិណាស្រពអំពីបូកណានៅប្រទេស ឥណ្ឌា និង លង្កាទ្វីប ក៏

មានពួកមិច្ឆាទិដ្ឋិកច្រើនដែរ ។ ខ្ញុំព្រះករុណាសង្ឃឹមយ៉ាងជាក់ច្បាស់ថា ព្រះតេជព្រះគុណគ្រប់ព្រះអង្គ នឹងចាត់ការបំបាត់មាត់ពួកមិច្ឆាទិដ្ឋិកក្នុងបច្ចុប្បន្នកាលសម័យយើងនេះ ដើម្បីនឹងស្ងួនគ្រងរក្សានូវព្រះពុទ្ធសាសនាពុំខាន; នេះជាចំណុចទី ៣ ដែលខ្ញុំព្រះករុណាបានដៅទុកខាងលើ ។

"បពិត្រព្រះករុណាដ៏ប្រសើរទាំងឡាយ, ខ្ញុំព្រះករុណា សូមបួងសួងថាសូមឲ្យព្រះពុទ្ធសាសនារុងរឿងយ៉ាងភ្លឺស្វាងត្រចះក្រៃលែងជាងអតីតកាល ដោយការប្រជុំធ្វើធម្មសង្គាយនានេះ ។ សូមព្រះតេជព្រះគុណមេត្តាប្រោស, យើងខ្ញុំព្រះករុណាជា ឧបាសក ទាយក សូមបញ្ចេញនូវបំណងដ៏មោះមុតដែលស្ថិតនៅជាប់ក្នុងហទយវត្ថុរបស់យើង គឺយើងខ្ញុំព្រះករុណាសូមបង្អោនសេចក្តីគោរព ដែលជាគារវភាពដ៏ជ្រាលជ្រៅបំផុត ចំពោះភិក្ខុទាំងឡាយ ដែលអាចហោះធ្យានតាមអាកាសវេហាស៍ដោយអំណាចចិត្តវិជ្ជារបស់លោក ដូចជាព្រះអរហន្តខីណាស្រពនៅប្រទេសឥណ្ឌៀ នឹងលង្កាទ្វីបពីបូរាណកាល ។ ទោះបីពេលនេះ កាលៈទេសៈ មិនបើកឱកាសឲ្យប្រតិបត្តិដល់ថ្នាក់នេះបាន ក៏យើងខ្ញុំព្រះករុណា សូមបង្អោនសេចក្តីគោរពដ៏ជ្រាលជ្រៅដូចគ្នាចំពោះភិក្ខុទាំងឡាយដែលបានបន្ទន់អស្មិមានះបំពេញអភិនេស្រ្កមណ៍ ទ្រទ្រង់ត្រៃចីវរនឹងបាត្រ ត្រាច់ចរពីទីមួយទៅកាន់ទីមួយ ប្រតិបត្តិធម្មវិន័យនៅទីកន្លែងតាមតែបាន (មិនរើស) ទោះជាគុហារូងភ្នំក្តី, វត្តអារាមក្តី, ព្រៃព្រហាវ័នក្តី ឬទីបព៌តក្តី ។ ផ្លូវប្រតិបត្តិទាំងពីរប្រការនេះ នៅប្រទេសភូមា ទាំងគ្រហស្ថទាំងបព្វជិតអាចប្រព្រឹត្តបានយ៉ាងងាយ ព្រោះបើទុកណាជាផ្លូវនៃការត្រាស់ដឹងអាចសម្រេចបានអាស្រ័យកុសលដ៏ច្រើន ដែលខ្លួនបានកសាងសន្សំទុកមកអំពីអតីតជាតិក៏ដោយ គង់ការប្រព្រឹត្តតាមលំអាននៃអភិនេស្រ្កមណ៍ ដែលមានធីរភាពដ៏ត្រឹមត្រូវនោះ ជាការអាចយ៉ាងប្រាកដព្រោះអាស្រ័យតែសទ្ធានឹងវីរិយៈរបស់ខ្លួនប៉ុណ្ណោះ ហើយភិក្ខុទាំងឡាយតែងបានឱកាសនឹងបំពេញវីរិយភាពបានប្រសើរក្រៃលែងជាងគ្រហស្ថទាំងឡាយផង ។ —

"បពិត្រព្រះករុណាដ៏ប្រសើរទាំងឡាយ. គ្រង់គ្នានឹងពាក្យថា "គ្មានរបស់អ្វីមួយដែលហួសវិស័យនៃអ្នកមានវីរិយភាពទេ" ខ្ញុំព្រះករុណាជឿយ៉ាងមាំថា កាលបើព្រះតេជព្រះគុណគ្រប់ព្រះអង្គប្រតិបត្តិនូវអប្បមាទធម៌បានពេញបរិបូណ៌ហើយ ព្រះពុទ្ធសាសនានេះក៏នឹងប្រាកដឡើងជាអបរិក្ខយសាសនាដ៏ឆាប់រហ័ស ជាសាសនាប្រកបដោយអង្គ៨ប្រការ ដែលភិក្ខុទាំងឡាយអាចយកជាទីពឹងបានយ៉ាងពិតប្រាកដ ។

"ព្រះពុទ្ធបំណងថា "អ្នកដែលពុំមានសទ្ធាជ្រះថ្លា គប្បីឲ្យមានសទ្ធាជ្រះថ្លាឡើង, អ្នកដែលមានសទ្ធាស្រាប់ហើយ គប្បីឲ្យរឹងរឹតតែមានសទ្ធាជ្រះថ្លាប្រសើរកើនឡើងទៀត" នោះនឹងបានសម្រេចសមដូចប្រាថ្នាដោយ

ការប្រតិបត្តិបែបនេះពុំខាន ៗ ពាំងគុណធម៌របស់ភិក្ខុសង្ឃ ដូចអប្បិច្ឆតា "សេចក្តីប្រាថ្នាតិច" , សន្តោស "សេចក្តីត្រេកអរពេញចិត្តតាមមានតាមបាន" និងអប្បកិច្ច "កិច្ចការខ្វល់ខ្វាយតិច" ដែលមានត្រាទុកក្នុងវិន័យបញ្ញត្តិ ក៏នឹងបានលូតលាស់ចម្រើនឡើងដោយពិត ៗ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ , ខ្ញុំព្រះករុណាសូមសង្ឃឹមដោយសេចក្តីគោរពថា ព្រះតេជព្រះគុណគ្រប់ព្រះអង្គមុខជានឹងខំបំពេញពិព្យាយាមយ៉ាងម៉ឺងម៉ាត់ ដើម្បីធ្វើព្រះពុទ្ធសាសនានេះឲ្យបានពេញបរិបូណ៌ថា "សត្ថុសាសនៈប្រកបដោយអង្គប្រាំបីប្រការ" ក្នុងសម័យនៃឆដ្ឋ-សង្គាយនានេះពុំខាន ៗ

"ក្រោយពេលធ្វើសង្គាយនាទីមួយ ១ ទាំងប្រាំគ្រាដែលកន្លងទៅហើយ តែងមានសារប្រយោជន៍ឬគុណប្រយោជន៍ពិតនៅដរាបមក ៗ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ, កាលដែលខ្ញុំព្រះករុណាបានរំពឹងពិចារណាមើលថា ឆដ្ឋសង្គាយនារបស់យើងដែលព្រះតេជព្រះគុណគ្រប់ព្រះអង្គបាននិមន្តមកជួបជុំក្នុងពេលនេះ នឹងអាចបានគុណប្រយោជន៍បែបណាទៅអនាគតនោះ ខ្ញុំព្រះករុណាបានឃើញច្បាស់នូវចំណុចដ៏មានតម្លៃក្រៃលែងប្រាំមួយប្រការគឺៈ

(១) ទុកណាជាការហោះឈ្យានតាមអាកាសដោយអំណាច "ចិត្តវិជ្ជា" ពុំមាន,ប៉ុន្តែពេលនេះយើងអាចទៅមកកាន់គ្នាពីប្រទេសពុទ្ធសាសនិកមួយទៅមួយបានយ៉ាងស្រួល នាំឲ្យយើងមានឱកាសស្រាវជ្រាវរកគម្ពីរព្រះត្រៃបិដកគ្រប់បែបគ្រប់យ៉ាងយកមកប្រកបប្រៀបធៀបគ្នា ដើម្បីពិនិត្យបាលីព្រះពុទ្ធវចនៈបានយ៉ាងងាយ ៗ នេះជាចំណុចសំខាន់បំផុតមួយដែលខ្ញុំព្រះករុណាសុំឲ្យឈ្មោះថាជា ទុល្លភៈ (ការកម្រ) ៗ

(២) កាលបើប្រទេសពុទ្ធសាសនិកថេរវាទ គឺ ថៃ, កម្ពុជា, លង្កា, ភូមា និង លាវ, រួបរួមធ្វើសហការយ៉ាងពេញសមត្ថភាព បានពិនិត្យផ្ទៀងផ្ទាត់ហើយបោះពុម្ព ព្រមទាំងរើបោះពុម្ពនូវបាលីព្រះពុទ្ធវចនៈទាំងអស់ហើយ សង្គាយនានេះនឹងទៅជាសង្គាយនាអន្តរជាតិមួយ ៗ

(៣) ការប្រែព្រះត្រៃបិដកទៅជាភាសាភូមានឹងទៅជាការប្រែមានតម្លៃដែលព្រះមហាថេរានុត្ថេរៈបានយល់ព្រមផង ហើយការប្រែជាភាសាភូមានេះ នឹងជាលាភដ៏ប្រសើររបស់យើងមួយ ដែលជាផលកើតអំពីសង្គាយនានេះ ហើយនឹងបានស្ថិតនៅអស់កាលជាអង្វែងតទៅ ៗ ខ្ញុំព្រះករុណាសូមឲ្យព្រះត្រៃបិដកប្រែជាភាសាភូមាបានស្ថិតនៅបន្ទាប់អំពីពិធីសង្គាយនានេះអស់រយៈកាលយូរដូចជាគម្ពីរកថាវត្ថុ ដែលបានស្ថិតនៅអស់កាលយូរ បន្ទាប់អំពីការប្រជុំធ្វើតតិយសង្គាយនាដូច្នោះដែរ ៗ

(៤) ចំណុចទី៤ គឺគម្ពីរពុទ្ធវំស (គម្ពីរពុទ្ធប្រវត្តិ) ដែលបានចារឹកយ៉ាងពិស្តារជាភាសាភូមាហើយនោះ ក៏សូមឲ្យបានប្រែផ្សាយចេញដោយបានអនុញ្ញាតអំពីព្រះមហាថេរានុត្ថេរៈផង ។ គម្ពីរនេះក៏គួរពោលថាជាគុណប្រយោជន៍មួយដែលកើតអំពីសង្គាយនានេះ ហើយសូមឲ្យបានគង់វង្សអស់កាលយូរតទៅផង ។

(៥) ខ្ញុំព្រះករុណាមិនអាចនឹងរំលងចោលខានពោលអំពីគោលបំណងដ៏សំខាន់នេះបានឡើយ ។ ការប្រជុំធ្វើឆដ្ឋសង្គាយនានេះ ជាការជម្រះសំអាតព្រះបាលីពុទ្ធវចនៈឲ្យបានត្រឹមត្រូវដូចព្រះពុទ្ធដីកានៃព្រះបរមគ្រូ ។ សូមព្រះតេជព្រះគុណគ្រប់ព្រះអង្គមេត្តាប្រោស ខ្ញុំព្រះករុណា សូមថ្លែងថាការកិច្ចដ៏មានគុណានុភាពនេះ សូមឲ្យបានជាមហាកិច្ចដ៏មានគុណានុភាពមួយ៖ ប្រជាជនទូទៅក្នុងប្រទេសភូមាទាំងមូលព្រមទទួលស្គាល់ព្រមទាំងយល់ឃើញជាមានគុណប្រយោជន៍ផង ។

(៦) ចំណុចទី៦ ដែលជាចំណុចចុងក្រោយបំផុតក៏គឺការកសាងសង់មហាបាសាណគុហា ជាគ្រឹះស្ថានមួយដ៏ស្ថាពរមិនមែនជាមន្ទីរបណ្តោះអាសន្នដូចក្នុងកាលធ្វើសង្គាយនាមុនៗនោះទេ ។ ខ្ញុំព្រះករុណា សូមអធិដ្ឋានឲ្យសំណង់ដ៏សម្បើមនេះបានស្ថិតនៅជាអនុស្សាវរីយ៍មួយក្នុងប្រវត្តិសាស្ត្រនៃពិភពលោក ដូចក្នុងប្រវត្តិសាស្ត្រនៃព្រះពុទ្ធសាសនាដែរ ។


លោក សាធុសិរីសុធម្ម អ៊ូ ធិន ប្រធាននៃពុទ្ធសាសនសភា

“ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ, ក្នុងឋានៈដែលខ្ញុំព្រះករុណាជារដ្ឋមន្ត្រីក្រសួងធម្មការនិងក្រសួងផែនការជាតិ, ខ្ញុំព្រះករុណាបានឱកាសនឹងបំពេញកិច្ចការ ព្រមទាំងទទួលភារៈខុសត្រូវក្នុងការរៀបចំធ្វើឆដ្ឋសង្គាយនានេះផង ខ្ញុំព្រះករុណាបានពេញចិត្តខ្លួនឯងថា “អាត្មាអញគួររីករាយសប្បាយដែលបានកើតមកពេញជាមនុស្សដោយហេតុជាអ្នកអាចប្រព្រឹត្តតាមទំនងនៃព្រះបរមគ្រូមួយរូបនឹងគេដែរ ។

“ បពិត្រព្រះករុណាដ៏ចំរើនទាំងឡាយ, ចំណែកខាងរដ្ឋាភិបាលនៃសហភាពប្រទេសភូមា ក៏សូមផ្ទេរការទទួលខុសត្រូវពេញបន្ទុកជូនចំពោះពុទ្ធសាសនសភា ដើម្បីរៀបចំព្រមទាំងចាត់ចែងការ

ប្រជុំធ្វើធម្មសាកច្ឆាយនាឲ្យបានសម្រេចផលល្អសមដូចបំណង ។

“បពិត្រព្រះករុណាដ៏បំរើនទាំងឡាយ, នៅទីបញ្ចប់នៃសេចក្ដីថ្លែងការណ៍នេះ ខ្ញុំព្រះករុណាសូមបញ្ជាក់ឲ្យបានជ្រាបថារដ្ឋាភិបាលនៃសហភាពប្រទេសភូមា បានទទួលនាទីជា “អ្នកឧបត្ថម្ភ” ដើម្បីឲ្យសម្រេចព្រះនិព្វាន, ប្រជាជននៃសហភាពប្រទេសភូមា ក៏បានព្រមព្រៀងគ្នាទាំងអស់មករួបរួមបំពេញកិច្ចការដោយកុសលចេតនា ទាំងនានាប្រទេសក៏បានរួមចិត្តមួយធ្វើមមួយមកជួយបំពេញកិច្ចការយើងផងដែរ, ក្នុងនាមនៃគណៈប្រជានុកូលស្រ្តីទាំងអស់ ខ្ញុំព្រះករុណាសូមថ្លែងអំណរចំពោះអស់លោកអ្នកទាំងនោះដ៏ក្រៃលែង ។

*

* *

ពិធីបើកសម័យប្រជុំឈ្មោះថាចប់ត្រឹមថ្ងៃទី៣ ដូចរៀបរាប់មកហើយ ។ ក្នុងថ្ងៃជាលំដាប់តទៅ ប្រទេសនីមួយៗ ត្រូវចាត់ភិក្ខុសង្ឃ ជាតំណាងធ្វើជាសង្គីតិការកៈ ក្នុងមហាធាសាណាគូហាជានិច្ចកាលរាល់ថ្ងៃ, ពេលព្រឹកចាប់តាំងពីម៉ោង ៨ ទៅដល់ម៉ោង ១០, ពេលរសៀលចាប់តាំងពីម៉ោង ១៣ ដល់ម៉ោង ១៧, បំពេញកិច្ចការតាមគម្រោងដែលបានធ្វើមកហើយក្នុងថ្ងៃទាំង ៣ ដរាបដល់អស់រយៈកាល ៤៥ ថ្ងៃ ។

ក្នុងពេលប្រជុំតទៅនោះ ភិក្ខុសង្ឃក្រៅពីសង្គីតិការកសង្ឃក្ដី ឧបាសក-ឧបាសិកាជាសាធារណជនទាំងឡាយក្ដី អាចចូលទៅគោរព-ស្ដាប់បានតាមសទ្ធាឥតមានកំរិតចំនួន ដូចកាលមហាសន្និបាតទាំង ៣ ថ្ងៃនោះទេ ។ ចំណែកខាងប្រទេសខ្មែរយើង, សម្ដេចព្រះមហាសុមេធាធិបតី បានចាត់ភិក្ខុ៥រូបឲ្យធ្វើជាសង្គីតិការកៈគឺ ព្រះវិន័យធរ អនុគណ ឃ.ញ.ធម្មស្សរោ,



សមណៈប្រតិភូប្រទេសកម្ពុជានឹងប្រទេសជប៉ុន

ព្រះវីរធម្មវរមហាថេរ, ព្រះមហាប៉.ម.ឥន្ទបញ្ញោ, ព្រះមហាកា.ស.ធម្មធីរោ និងព្រះមហា ប.ឌ.វិសុទ្ធិជោតោ ។

ពួកប្រតិភូនានាប្រទេស នឹងត្រូវនិមន្តអញ្ជើញទៅទស្សនាក្រុងមណ្ឌលេ សះតែង និងប៉ាកាន ដែលនឹងរៀបរាប់ទៅខាងមុខ ។

---

## ថ្ងៃព្រហស្បតិ៍ ៤ រោចខែវិសាខ (២០ឧសភា)

ពេលព្រឹកម៉ោង ៨ ព្រះសង្ឃទាំងអស់ឆាន់យាគូនៅភត្តសាលាដូចថ្ងៃមុន ដល់ពេលថ្ងៃត្រង់ព្រះសង្ឃ ៣.០០០អង្គត្រូវទទួលនិមន្តទៅឆាន់នៅសណ្ឋាគារ លោកប្រធានាធិបតី ។

វេលាម៉ោង ៨ កន្លះ រថយន្តតូច-ធំ ចំនួនប្រហែល ២០០ មកដឹកនាំព្រះភិក្ខុសង្ឃ ចំនួនបីពាន់អង្គនោះទៅកាន់សណ្ឋាគារលោកប្រធានាធិបតី ។ ព្រះមហាថេរជាប្រធាននៃគណៈប្រតិភូជាដើម គង់រថយន្តពិសេសតូចៗ ព្រះសង្ឃក្រៅពីនោះគង់រថយន្តធំៗ ។ នៅមុខមហាសណ្ឋាគារនោះ គេបានតាក់តែងប៉ារ៉ាំមួយ យ៉ាងធំទូលំទូលាយ វែងល្វឹងល្វើយ ពិតានពាសសំពត់ព្រែសម្បុរត្រួយ បើកមើលទៅក្នុងរោងមានក្រើងមានផ្លិតអគ្គិសនីនៅដេរដាសព្វទាំងលើ ។ ពពួកឧបាសក ឧបាសិកាជាសហការីលោកប្រធានាធិបតី បានចាត់ចែងភត្តាហាររៀបដាក់តុជាជួរៗល្មមឆាន់មួយតុពីរអង្គៗ គ្រប់ទាំង ៣.០០០ អង្គ គួរឲ្យអស្ចារ្យណាស់ ។

ម៉ោង១៣ឯកឧត្តមអ៊ូ.វិន រដ្ឋមន្ត្រីក្រសួងធម្មការបានចូលមកក្រាបថ្វាយបង្គំគាល់សម្តេច ព្រះមហាសុមេធាធិបតី នៅទីសំណាក់នៃសម្តេចហើយបានសុំនិមន្តព្រះសង្ឃខ្មែរទាំងអស់ ទៅទទួលភត្តាហារនៅសណ្ឋាគារឯកឧត្តមនាយករដ្ឋមន្ត្រីនៅវេលាថ្ងៃស្អែក ព្រមទាំងនៅសណ្ឋាគារផ្ទាល់ខ្លួនលោកនាថ្ងៃខានស្អែកផង ។

ម៉ោង១៦ ឯកឧត្តមនាយករដ្ឋមន្ត្រី បានចូលមកថ្វាយបង្គំគាល់សម្តេច, ឯមហាគុហាជាទីសំណាក់, ជាមួយនឹងឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការម្តងទៀត ។ ពេលនោះសម្តេចបានប្រាស្រ័យការផ្តុកផ្តាក់ផ្តាំផ្ញើភិក្ខុជាតិខ្មែរ៥រូប នឹងសីលវតី៣រូប ដែលបានមកនៅរៀនសូត្រក្នុងមកមួយឆ្នាំហើយ ព្រមទាំងព្រះមហាតិម-សុខ ធម្មធីរោ (ជាតិខ្មែរ) ដែលបានទៅជាមួយក្នុងគ្រានេះ ហើយដែលត្រូវសិក្សាខាងវិបស្សនាធុរៈក្នុងពេលផុតសម័យនៃមហាសន្និបាតសង្គីតិកម្មលើកទី៦នេះ ។ ឯកឧត្តមនាយករដ្ឋមន្ត្រី នឹងឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការក៏បានទទួលព៉រដោយសោមនស្សរីករាយ ។

ម៉ោង១៨ រថយន្តពិសេសរបស់ពុទ្ធសាសនសភា បាននាំយើងទាំងអស់គ្នាទៅគោរពបូជនីយស្ថានផ្សេងៗ មាន សិង្គុត្តរមហាចេតិយ ជាដើមដរាបដល់ម៉ោង២០នឹង ៣០ នាទី ។

---

## ថ្ងៃសុក្រ ៥ រោច ខែពិសាខ (២១ ឧសភា)

ពេលព្រឹកដែលព្រះសង្ឃឆាន់នៅភត្តសាលារួចហើយ នៅវេលាម៉ោង ៨ សង្គីតិការកសង្ឃទាំងឡាយបាន និមន្តទៅប្រជុំនៅមហាបាសាណគូហា ហើយបានតាំងបុច្ឆកត្ថេរ នឹងវិស្សជ្ជកត្ថេរ រួចហើយព្រះសង្ឃទាំងអស់ក៏ សូត្រ វិនយបិដក គួរវេរញ្ជកណ្ឌ ។ ត្រង់កន្លែងខ្លះមានសូត្រគម្រឹមគ្នាបីដង ។ លោកខ្លះសូត្រមាត់ទទេ លោក ខ្លះកាន់សៀវភៅដរាបដល់ម៉ោង ១០ ទើបឈប់ ។ សម្តេចនិងព្រះសង្ឃខ្មែរទាំងអស់ក៏ចូលទៅប្រជុំសូត្រគួរ វេលានេះដែរ ។

ម៉ោង១០ នឹង ២៥ នាទី ឯកឧត្តមនាយករដ្ឋមន្ត្រី បានចាត់បំរើឲ្យមកទទួលព្រះសង្ឃគណៈប្រតិភូ ខ្មែរ-ថៃ-លាវ-ទៅទទួលភត្តាហារនៅសណ្ឋាគាររបស់លោក ។

សម្តេចព្រះមហាសុមេធាធិបតី ប្រធានគណៈប្រតិភូ ខ្មែរ គង់តែមួយព្រះអង្គឯងលើរថយន្តពិសេស របស់ឯកឧត្តមនាយករដ្ឋមន្ត្រី ដែលមាននាយប៉ូលិសជិះតោចក្រយានយន្តយោងមុខពីរគ្រឿង ហែអមពីរគ្រឿង, បន្ទាប់មករថយន្តពិសេសមួយទៀតសំរាប់ព្រះវិមលធម្មប្រធានគណៈប្រតិភូថៃ ។ ចំណែកខាង ព្រះសង្ឃ ខ្មែរ-ថៃ-លាវ ក្រៅពីនេះគង់រថយន្ត តូច-ជិតាមពីក្រោយ ។



ក្បួនរថយន្តរបស់ពុទ្ធសាសនសភា មកទទួលយកសមណប្រតិភូពីមហាគុហា សម្តេចគង់លើរថយន្តពិសេសរបស់ឯកឧត្តមនាយករដ្ឋមន្ត្រី

ឯកឧត្តមនាយករដ្ឋមន្ត្រីនិងឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ បានរង់ចាំទទួលសម្តេចនៅប្របទ្វារ ចូលទៅកាន់សណ្ឋាគារ ។ ក្រោយដែលបានធ្វើ គារវកិច្ចតាមទំនៀមហើយ ឯកឧត្តមនាយករដ្ឋមន្ត្រី បាននិមន្តសម្តេចនិងព្រះសង្ឃទាំងឡាយឡើងទៅលើសណ្ឋាគារ ។

មុននឹងប្រគេនចង្ហាន់ ឯកឧត្តមទាំងពីរបានប្រាស្រ័យការដោយកក់តាក់យ៉ាងច្រើន ។ អាត្មាសុំថ្លែងតែត្រង់ខសំខាន់ពីរយ៉ាងគឺ ៖

១– បើសម្តេចត្រូវការ, ប្រទេស ភូមា អាចនឹងរ៉ាប់រងទទួលផ្គត់ផ្គង់អាហារូបករណ៍ដល់អ្នកសិក្សាព្រះពុទ្ធ-សាសនាជាតិ ខ្មែរ ១០ រូប គឺខាងបរិយត្តិធម៌ (ចំពោះព្រះអភិធម្ម) ៥ រូប ខាងបតិបត្តិធម៌ (វិបស្សនាធុរៈ) ៥ រូប ទោះជាភិក្ខុក្តី ឧបាសក ឬឧបាសិកាក្តី ជាស័លវត្តីក្តី រៀងរាល់ឆ្នាំតទៅ ។

២-ឯកឧត្តមនាយករដ្ឋមន្ត្រី បានទូលស្នើសុំសេចក្តីយល់ព្រមអំពីសម្តេចព្រះមហាសុមេធាធិបតីដោយរដ្ឋាភិបាលនៃសហភាពប្រទេសភូមាមានសេចក្តីពេញចិត្តដោយក្រៃលែងចំពោះគុណសម្បត្តិ, ចរិយាសម្បត្តិនិងសមត្ថភាពរបស់សម្តេច សុំលើកតម្កើងសម្តេចជា "អគ្គមហាបណ្ឌិត" ដែលជាសមណស័ក្តិខ្ពង់ខ្ពស់បំផុតក្នុងប្រទេសភូមា ពិធីនោះនឹងត្រូវធ្វើក្នុងថ្ងៃស្អែក ។

– ដោយសម្តេចបានត្រិះរិះពិចារណាមើលទៅយល់ឃើញថាមិនជាការណ៍ខុសអ្វីទេ ប៉ុន្តែតាមដំណើរផ្លូវការ គួរតែរដ្ឋាភិបាលប្រទេសភូមាជូនព័ត៌មាននេះដល់រាជរដ្ឋាភិបាលប្រទេសកម្ពុជាសិន តែឥឡូវរយៈពេលខ្លីពេក ដ្បិតសមណស័ក្តិអគ្គមហាបណ្ឌិតនោះនឹងត្រូវតែងតាំងនៅថ្ងៃទី ២២ ស្អែកទៅហើយ ដោយហេតុនេះ សម្តេចក៏បានព្រមទទួលតាមដំណើរការណ៍ដែលរដ្ឋាភិបាលភូមាបានប្រារព្ធហើយនោះ ព្រោះយល់ឃើញថា ពុំគួរប្រកែក ។

ពេលនោះ ឯកឧត្តមទាំងពីរ បានសំដែងសោមនស្សរីករាយចំពោះសេចក្តីយល់ព្រមរបស់សម្តេច ហើយបានក្រាបថ្វាយបង្គំទូលសម្តេចថានឹងរៀបពិធីតែងតាំងជាឧឡារិកនៅសណ្ឋាគារលោកប្រធានាធិបតីក្នុងថ្ងៃស្អែក គឺថ្ងៃទី ២២ ឧសភា សូមនិមន្តព្រះសង្ឃជាតិខ្មែរទាំងអស់ទៅរួមប្រជុំក្នុងទីនោះជាមួយនឹងព្រះសង្ឃគ្រប់ជាតិផងៗ

លុះសម្រេចភត្តកិច្ចហើយ សម្តេចបានប្រទានសីល ហើយផ្តើមភត្តានុមោទនា ជូនកុសលដល់គ្រួសារនៃឯកឧត្តមនាយករដ្ឋមន្ត្រី (តាមទំនៀមប្រទេសភូមាដែលតែងតែនិមន្តព្រះសង្ឃឆាន់រួចស្រេចទើបសូមសីលរួចធ្វើភត្តានុមោទនា ឬចំរើនព្រះបរិត្តសង្ខេប) ។

## ថ្ងៃសៅរ៍ ៦ រោច ខែវិសាខ (២២ ឧសភា)

ក្រោយធ្វើបាតកសកិច្ចនៅភត្តសាលារួច វេលាម៉ោង៨គត់មានរថយន្តជាច្រើន មកនិមន្តព្រះសង្ឃជាគណៈប្រតិភូគ្រប់ប្រទេសទៅកាន់ធម្មសភានៃសិង្គុត្តរមហាចេតិយ ។ លុះបានទៅដល់ទីនោះ យើងកំពុងសង្គាបាន



សិង្គុត្តរព្រះចេតិយ

ពួកព្រះសង្ឃជាតិភូមាកំពុងចំរើនព្រះបរិត្ត ពុទ្ធមន្ត ។

ម៉ោង ៨ និង ៣០ នាទី គណៈកម្មការសង្គីតមហាចេតិយ និមន្តព្រះសង្ឃខ្មែរទាំងអស់ចំរើនព្រះបរិត្តតាមសំនៀងបាលីបែបខ្មែរ ដោយមានទទេស្សាសនស័ព្ទបំពងសំឡេងផង ។

– សម្តេចព្រះមហាសុមេធាធិបតី ផ្តើមសូត្រ នមោ... សម្ពុទ្ធេ... ឯវម្មេ សុតំ ។ ... មង្គលសូត្រ ... យានីធ ភូតានិ ។ល។ ធម្មស្សាម សុវត្ថិ ហោតុ... យន្ទុន្និមិត្តំ ... ឧក្កាបាតា ... តេ អត្ថលទ្ធា ... អស់រយៈកាល ១៥ នាទី ។

បន្ទាប់មកព្រះសង្ឃជាតិថៃ សូត្រប្រកាសព្រះបរិត្ត ...សគ្គេ... មង្គលសូត្រ ... ឥតិបិ សោ... ស្វាក្ខាតោ ... សុប្បដិបន្នោ ... សក្កត្វា ... នត្ថិ មេ សរណំ ... យន្ទុន្និមិត្តំ... សូត្រសរភញ្ញ ពាហុំ ៥ សរណំ យន្ទិ... ហើយសូត្របញ្ចប់ដោយ សព្វពុទ្ធា... ជាសំនៀងបាលីបែបថៃ ។

បន្ទាប់ពីនោះមកទៀត ព្រះសង្ឃជាតិលង្កាទ្វីប-នេប៉ាល-វៀតណាម(ខាងថេរវាទ)-លាវ សូត្រពុទ្ធមន្តចំនួន១៥នាទី ៗ តាមសំនៀងបាលីជាតិរៀងៗខ្លួន ។

ម៉ោង៩និង៣០នាទី យើងទាំងអស់គ្នាផ្ទេរត្រឡប់មកកាន់ទីសំណាក់វិញ លុះដល់ពេលដែលរថយន្តមកទទួលដង្ហែ សម្តេចព្រះមហាសុមេធាធិបតី និងព្រះសង្ឃខ្មែរ-ថៃ-លាវ មានចំនួនរួមទាំងអស់ ៣៧ រូប ជាក្បួនដង្ហែដូចកាលពីថ្ងៃម្សិលទៅទទួលភត្តាហារនៅសណ្ឋាគារឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ។

លុះសម្រេចភត្តកិច្ចហើយ សម្តេចព្រះមហាសុមេធាធិបតី ជាប្រធានសង្ឃក៏បានប្រគេនសីល ផ្តើមសូត្រព្រះបរិត្តពុទ្ធមន្តសង្ខេបនិងភត្តានុមោទនា ។

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការនិងលោកជំទាវ បានប្រគេនត្រៃចីវរ គឺស្បង់-ចីពរ-សង្ឃាដី-ស្បែកជើងមួយគូៗ និងតាំងយូមួយប្រដាប់ៗ គ្រប់ៗអង្គទាំងអស់ ។ បន្ទាប់មកឯកឧត្តមរដ្ឋមន្ត្រីនិមន្តព្រះសង្ឃទាំងអស់ទៅគោរពបូជនីយវត្ថុក្នុងបន្ទប់មួយដែលតាំងនៅក្នុងសណ្ឋាគារផ្ទាល់ខ្លួនលោក, ដែលជាបន្ទប់យ៉ាងស្អាត មានព្រះពុទ្ធរូបដ៏មានតម្លៃគ្រប់បែបគ្រប់យ៉ាងព្រមទាំងរូបភាពបូជនីយស្ថានៈផ្សេងៗ គ្រឿងសក្ការបូជាដ៏ឧត្តមព្រមទាំងផ្កាស្រស់គ្រប់ពណ៌ដែលផ្លាស់រាល់ថ្ងៃ ។ កន្លែងនេះហើយដែលក្រុមគ្រួសារនៃឯកឧត្តមគោរពនមស្ការរាល់ព្រឹកល្ងាច ។

អាត្មាទឹកស្ញើចសរសើរជនជាតិភូមាណាស់ ដែលបានរៀបចំហោព្រះពុទ្ធរូបបែបនេះ ពុំមែនមានត្រឹមតែ

ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការប៉ុណ្ណោះឡើយ គឺមានគ្រប់គេហស្ថាននៃវរជនជាតិភូមាទាំងអស់ ។ នៅគេហស្ថានមួយៗដែលគេអួតលំអគ្នា គឺត្រង់កន្លែងហោព្រះពុទ្ធរូបនេះឯង ។

ម៉ោង ១៤ ព្រះសង្ឃប្រតិភូគ្រប់ប្រទេសចេញពីមហាកុដិទាំង ៤ ដោយរថយន្តទៅកាន់មហាសណ្ឋាគារលោកប្រធានាធិបតី ។ លុះទៅដល់ជិតកំពែងមហាសណ្ឋាគារ គេបាននិមន្តសម្តេចព្រះមហាសុមេធាធិបតីនិងព្រះមហាថេរ ដែលត្រូវតែងតាំងជាអគ្គមហាបណ្ឌិតទាំងប៉ុន្មានឲ្យនិមន្តទៅសម្រាកក្នុងបន្ទប់មួយដោយឡែក ហាក់ដូចជាយកទៅលាក់បំពួនទុកមួយស្របក់សិន ។ ចំណែកព្រះសង្ឃក្រៅពីនោះនៅសម្រាកឆាន់កេសជ្ជៈរង់ចាំពេលនៅក្នុងការិយាល័យលោកប្រធានាធិបតី ។

-បន្ទាប់ពីនោះមក ទើបគេនិមន្តព្រះសង្ឃទាំងអស់ឲ្យចូលតាមទ្វារខាងក្រោយ ទៅកាន់បាហុនដ្ឋានដ៏ធំទូលំទូលាយ (ដែលពីឆ្នាំមុនសម្តេចនិងអាត្មាកាលទៅប្រទេសភូមាក៏បានទៅទទួលភត្តក្នុងទីនោះម្តងដែរ) ។ ពុទ្ធបរិស័ទជាប្រតិភូគ្រប់ប្រទេសក៏បានទៅជួបជុំត្រៀបត្រាជាមហាសន្និបាតក្នុងទីនោះ ហើយអង្គុយជាលំដាប់ គឺ ព្រះសង្ឃទាំងអស់គង់កៅអី ចំណែកឧបាសកឧបាសិកាអង្គុយផ្ទាល់លើកម្រាលកន្ទេលរុំវៃបបលេខ ១ (ព្រោះនៅប្រទេសភូមាកាលបើមានប្រជុំធំៗយ៉ាងនេះ គេមិនប្រើព្រំជាកម្រាលទេ គេប្រើកន្ទេលរុំជារបស់ជាតិគេ) ។ នៅមុខអាសនៈព្រះសង្ឃ មានបល្ល័ង្កប្រាំបី ប្រកបដោយក្លស់បើកបាំងពីខាងលើ ដែលពុំទាន់មានព្រះសង្ឃគង់នៅឡើយ ។

នៅវេលាម៉ោង ១៥ ខ្វះ ១០ នាទី ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការកាន់ផ្តិលប្រាក់មួយធំដាក់បាច់ផ្កានិងត្រួយព្រីង (ដែលជនជាតិភូមាសន្មតថាជាមង្គលព្រឹក្ស) នាំមុខ ហើយមានពួកសហការីជាអ្នកកាន់ទង់ប៉ាក់ខ្ទិនប្រាក់-មាស អបអមនាំគ្នាដង្ហែព្រះរេវតមហាថេរមហារដ្ឋគុរុ ញ៉ោង យ៉ាំង សាយ៉ា ឌូវ ដែលជាអគ្គមហាបណ្ឌិតតាំងពីព្រេងព្រឹទ្ធមក ហើយក្នុងវេលានេះជាប្រមុខនៃសង្ឃផង ។ លុះក្បួននេះចូលមកដល់កណ្តាលទីមហាសន្និបាតហើយ ភ្លេងអគ្គិសនីដែលមានពាក្យស្រទំអម្បាញ់មិញក៏បញ្ចេញសូរចិញ្ចាចឡើង ភ្លេងមួយវង់ដែលនៅជ្រុងខាងស្តាំក៏ប្រគំគងវង់ទទួលព្រះមហាថេរអង្គនោះ ។ ព្រះរេវតមហាថេរ ក៏និមន្តឡើងគង់លើបល្ល័ង្កចំកណ្តាល ដែលមានស្វេតច្ឆត្រប្រាំជាន់បើកបាំងពីលើ ។

-បន្ទាប់មក ទើបក្បួនដង្ហែសម្តេចព្រះមហាសុមេធាធិបតីនិងព្រះមហាថេរ៧អង្គដទៃទៀតចូលមកដល់ ដោយមានភ្លេងប្រគំដូចមុន ។ ព្រះមហាថេរទាំងនេះ ឡើងគង់លើបល្ល័ង្កអមសងខាង ព្រះរេវតមហាថេរ ។

សម្តេចព្រះមហាសុមេធាធិបតី គង់លើបល្ល័ង្កខាងស្តាំលំដាប់អំពី ព្រះវេទមហាថេរ ។

— បន្ទាប់មកទៀត នាយទាហានពីរនាក់ (ជាអង្គរក្ស) បានដង្ហែរយានមុខលោកប្រធានាធិបតី ដែលស្លៀកសំពត់ផាមួងបែតងសម្លុយបែបសារុង ពាក់អាវពណ៌ម៉ែង ពាក់ខ្សែរក្រែពណ៌ផ្ទៃមេឃស្រទំ ពាក់ឈ្នួតសំពត់ពណ៌សគាវមានផ្កាខៀវល្អិតៗ ពាក់វ៉ែនតា ចូលមកដោយអាការស្រគត់ស្រគំហើយក្រាបថ្វាយបង្គំដំកុំសង្ឃរួចទើបអង្គុយកបលើអាសនៈពិសេសមួយ ។ (ការស្លៀកពាក់បែបនេះជនជាតិភូមាទាំងអស់ប្រកាន់ប្រើដូចគ្នា តាំងពីជនសាមញ្ញរហូតដល់វរជនជាន់ខ្ពស់បំផុត ដែលប្លែកគ្នាតែពណ៌និងវត្ថុថ្លៃថោកប៉ុណ្ណោះ) ។

គង់ពេលនោះ បរិយាកាសទាំងមូលស្ងប់ស្ងាត់ឈឹងគ្មានឮសូរអ្វីសោះ ។ មួយនាទីក្រោយមក ទើបមានឥស្សរជនជាតិភូមាមួយនាក់ថ្លែងសេចក្តីប្រកាសជាភាសាភូមា ដោយមានខ្មោក្លួសនសព្ទជាគ្រឿងបំពងសំឡេងបើកពិធីតែងតាំង អគ្គមហាបណ្ឌិត ។

— មានឥស្សរជនជាតិភូមាម្នាក់ទៀត សូត្របទសរញ្ញ ចុតិគថា ជាភាសាភូមាយ៉ាងស្រងេះស្រងោចលន្ទង់លន្ទោច អស់ពេលពីរបីនាទី ។

— ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ថ្លែងសុន្ទរកថា ។

— ពួកនារីភូមា សូត្រពណ៌នាកិត្តិគុណ អគ្គមហាបណ្ឌិត ជាបទសរញ្ញយ៉ាងពីរោះ ។

— មន្ត្រីម្នាក់ទៀតថ្លែងសេចក្តីជាភាសាបាលីផង ជាភាសាភូមាផង ។

— ឧបាសក ឧបាសិកា មានលោកប្រធានាធិបតីជាប្រមុខ សុំបញ្ចសីល ។

— ព្រះវេទមហាថេរ ញ៉ោងយ៉ាំងសាយ៉ាដូ ជាអ្នកឲ្យសីល ។

— ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ ថ្លែងសេចក្តីប្រកាសតាំងព្រះមហាថេរ ៨ អង្គជា អគ្គមហាបណ្ឌិត គឺៈ

១- សម្តេចព្រះមហាសុមេធាធិបតី (ជ.ណា. ជោតញ្ញាណោ) សង្ឃនាយកគណៈមហានិកាយ នៃប្រទេសកម្ពុជា ព្រះជន្មាយុ ៧១ ឆ្នាំ វស្សា ៥២ ។

២- ព្រះវិមលធម្ម អាសភត្ថេរ ជន្មាយុ ៥១ ឆ្នាំ វស្សា ៣២ (ប្រទេសថៃ) ។

៣- ព្រះបុញ្ញាភិជជ មហាថេរ ជន្មាយុ ៨៥ ឆ្នាំ វស្សា ៦៥ (ភូមា) ។

៤- ព្រះសុវណ្ណ មហាថេរ ជន្មាយុ ៧២ ឆ្នាំ វស្សា ៥៣ (ភូមា) ។

៥- ព្រះសុរិយ មហាថេរ ជន្មាយុ ៧១ ឆ្នាំ វស្សា ៥១ (ភូមា) ។

៦- ព្រះពុទ្ធទត្ត មហាថេរ ជន្មាយុ ៦៧ ឆ្នាំ វស្សា ៤៧ (លង្កាទ្វីប) ។

៧- ព្រះសោភណ មហាថេរ ជន្មាយុ ៦០ ឆ្នាំ វស្សា ៤១ (ភូមា) ។

៨- ព្រះកោសល្ល មហាថេរ ជន្មាយុ ៦០ ឆ្នាំ វស្សា ៤០ (ភូមា) ។

-បន្ទាប់មកមន្ត្រីក្រសួងធម្មការជាច្រើន បានថ្លែងប្រវត្តិព្រះមហាថេរទាំង ៨ អង្គជាភាសាអង់គ្លេសផង ជាភាសាភូមាផង តាមលំដាប់លំដោយគ្នា ។ល។

ម៉ោង ១៦ នឹង ១០ នាទី លោកប្រធានាធិបតីបាននាំសញ្ញាប័ត្រដែលមានគ្រឿងទ្រវិចិត្រចនាធ្វើដោយឈើខ្មឹម នឹងស្រោមគ្រឿងស្លាប់ទឹបមាស បង្អោនចូលមកប្រគេន សម្តេចព្រះមហាសុមេធាធិបតីជាមុនបង្អស់ ហើយទើបប្រគេនព្រះមហាថេរ ទាំង ៧ អង្គជាលំដាប់ ។ លុះប្រគេនរួចហើយ លោកប្រធានាធិបតីថ្លែងសេចក្តីគោរពអរសាទរអស់រយៈពេលពីរបីនាទី ហើយក្រាបថ្វាយបង្គំចំពោះព្រះសង្ឃបីដងរួចអង្គុយចុះ ។


សញ្ញាប័ត្រ ដែលមានគ្រឿងទ្រវិចិត្រចនា ធ្វើដោយឈើខ្មឹមនឹងស្រោមគ្រឿងស្លាប់ទឹបមាស ។

-ព្រះ រេវតមហាថេរ ញ៉ោងយ៉ាន់សាយ៉ាឌូ ថ្លែងសេចក្តីតបព្រមទាំងពរសាធុការ អនុមោទនាចំពោះមហាសន្និបាត មានលោកប្រធានាធិបតីជាប្រមុខ ។

-លោកប្រធានាធិបតី ស្រួចទឹកឧទ្ទិសចំណែកកុសល ។

-មហាសន្និបាតបន្លឺសំឡេងសាធុការ ៣ ដងថា សាធុ សាធុ ព្ធទាំង ១ ព្រម ១ គ្នា ។

ម៉ោង ១៦ នឹង ៣០ នាទី ព្រះរេវតៈ(គណ្ឋ រេវតាភិធជ មហារដ្ឋគុរុ ញ៉ោងយ៉ាន់សាយ៉ាឌូ) អគ្គមហាបណ្ឌិតជាប្រមុខសង្ឃទឹងព្រះមហាថេរអគ្គមហាបណ្ឌិតថ្មីៗទាំង ៨ អង្គ មានសម្តេចព្រះមហាសុមេធាធិបតីជាដើម និមន្តជាក្បួនដង្ហែត្រឡប់វិញ ដោយមានប្រគំភ្លេងដង្ហែដំណើរជាកិត្តិយស ។ មហាសន្និបាតក៏បែកចេញទៅកាន់ទីរៀងៗខ្លួន ។



សញ្ញាប័ត្រអគ្គមហាបណ្ឌិត



ត្រាសម្រាប់អគ្គមហាបណ្ឌិតដែលរដ្ឋាភិបាលភូមា ប្រគេនសម្តេចព្រះមហាសុមេធាធិបតី

ព្រះនាមអគ្គមហាបណ្ឌិត

ប្រទេសកម្ពុជា

គ្រាដ៏ក្រុងពេញ វត្តឧណ្ណាលោម

មហាសង្ឃនាយក សម្តេចព្រះមហា-សុមេធាធិបតី ។

សូមថ្វាយសញ្ញាប័ត្រព្រះនាម "អគ្គមហាបណ្ឌិត" ដោយសេចក្តីគោរពចំពោះបញ្ញាគុណដ៏ខ្ពង់ខ្ពស់ មួយអន្លើដោយសីលគុណ សមាធិគុណរបស់សម្តេច ។

ហត្ថលេខា: អ៊ូ ករ:អ៊ូ

ប្រធានាធិបតី

សហភាពប្រទេសភូមា

ពុទ្ធសករាជ ២៤៩៨

កោជាសករាជ ១៣១៦, ៥ កេចថៃពិសាខ ។

សេចក្តីប្រែពីសញ្ញាប័ត្រអគ្គមហាបណ្ឌិត

សមណស័ក្តិអគ្គមហាបណ្ឌិតនេះ ពុំមែនរដ្ឋាភិបាលសហភាពភូមាចេះតែប្រគេនចំពោះព្រះមហាថេរទាំងឡាយដោយងាយ ៗ ឡើយ គឺមុននឹងប្រគេនចំពោះព្រះមហាថេរអង្គណាមួយ គណៈរដ្ឋមន្ត្រីត្រូវពិនិត្យពិចារណាច្រើនលើកច្រើនគ្រា ពិនិត្យពិច័យចំណេះវិជ្ជា ព្រះពុទ្ធសាសនា, សាសនាសាកល, ផ្លូវលោក, ផ្លូវធម៌, គុណសម្បត្តិសមគួរគាពទីនិងចរិយាសម្បត្តិគ្រប់បែបគ្រប់យ៉ាង ហើយលុះតែជាព្រះមហាថេរៈចាស់វស្សា មានព្រះជន្មាយុគ្រប់គ្រាន់ល្មមផង ទើបតែងតាំងព្រះមហាថេរនោះជា "អគ្គមហាបណ្ឌិត" បាន ព្រះមហាថេរដែលជាអគ្គមហាបណ្ឌិតនៅក្នុងប្រទេសភូមាមានចំនួនតិចណាស់ ។ តាមដោយអាត្មាបានឮគេនិយាយប្រាប់ស្ងាត់ៗថាព្រះអគ្គមហាបណ្ឌិតមួយអង្គ១ត្រូវបានទិញភត្តចំនួន ៧៥០ រូពី(រូពិយ)បើគិតជាប្រាក់យើងក្នុងសម័យនេះឃើញចំនួន ៥.៦៥៧រ៉ុ២៥ ក្នុងមួយឆ្នាំ (ពិតឬទេ ព្រោះឬពុំពិត ពុំអាចដឹងជាក់នៅឡើយ)។

ការតែងតាំងអគ្គមហាបណ្ឌិត ដោយពិធីដ៏ឧឡារិក មានកម្រិតបប់ត្រឹមវេលាម៉ោង ១៦ និង ៣០ នាទី ។



ព្រះ - ព្រមទាំងប្រអប់សម្រាប់ដាក់ព្រះ - គ្រឿងទេស្រោម កញ្ចប់រំបមាសសម្រាប់ដាក់សញ្ញាប័ត្រអគ្គមហាបណ្ឌិត

## ថ្ងៃអាទិត្យ ៧ រោច ខែវិសាខ
## (២៣ ឧសភា)

ថ្ងៃនេះរដ្ឋាភិបាលប្រទេសភូមា បានបម្រុងអាកាសយានចំនួន ៧ គ្រឿង ដើម្បីជូនប្រតិភូគ្រប់ប្រទេសទៅទស្សនាបូជនីយស្ថានផ្សេងៗ មានក្រុងមណ្ឌលេ ដែលនៅចម្ងាយ ៥៦០ ម៉ាយល៍ឡើងត្រើយពីក្រុងរង្គូនជាដើម ។

-ម៉ោង ៤ និង ៣០ នាទី (ទៀបភ្លឺ) យើងទាំងអស់គ្នា រៀបចំដំណើរចេញពីពុទ្ធវិទេហមហាគុជទៅកាន់ស្ថានីយអាកាសយានដែលមានចំណុះ ២៨ នាក់មួយគ្រឿងៗ ដោយមេឃពុះអ័ព្ទខ្លាំងមើលឆ្ងាយពុំឃើញត្រូវរង់ចាំដរាបដល់ម៉ោង ៧ និង ៤៥ នាទី ទើបអាកាសយានហោះឡើងចេញពីស្ថានីយសំដៅទៅក្រុងមណ្ឌលេ ។ ម៉ោង ៩ អ្នកបំរើយន្តហោះ បាននាំយកនំប៉័ង-កាហ្វេនិងផ្លែឈើខ្ចះបង្អែមចូលមកប្រគេនភិក្ខុសង្ឃឆាន់លើយន្តហោះ ។ ម៉ោង ៩ និង ៣០ នាទី អាកាសយានបន្ទាបខ្លួនឲ្យអ្នកដំណើរដោយ ហារ មើលក្រុងប៉ាកាន(ភូកាម) ដែលល្អមនឹងទស្សនាពីលើអាកាសឃើញច្បាស់ ។ ក្រុងនេះថ្ងៃក្រោយគេនឹងនាំទៅមើលឲ្យបានដល់ទីកន្លែង ។

ម៉ោង ១០ និង ១៥ នាទី អាកាសយាន បាននាំដំណើរយើងទៅដល់ស្ថានីយអាកាសយានក្រុង មណ្ឌលេ ។ នៅទីនោះមានអ្នកពជការព្រមដោយឧបាសកឧបាសិកា មករង់ចាំទទួល ហើយបាននិមន្ត-អញ្ជើញប្រតិភូទាំងអស់ឡើងរថយន្តដាក្បួនហែទៅកាន់គ្រឹះស្ថានមហាវិទ្យាល័យមួយដែលគេទើបនឹងកសាងឡើងនៅថ្មីៗសន្ទាន មានជាន់បីមានបន្ទប់១៦០ សំរាប់ប្រតិភូនៅអាស្រ័យមួយបន្ទប់ម្នាក់ៗ ។ នៅត្រង់ជ្រុងបណ្ដោយទាំង៣ជាន់ មានបន្ទប់ទឹក-បង្គន់ៗនៅបរិវេណខាងមុខទាំង៣ជាន់ មានកន្លែងសម្រាប់ភិក្ខុសង្ឃឆាន់ និងទីកន្លែងសម្រាប់ឧបាសក ឧបាសិកាបរិភោគអាហារ ។

ម៉ោង១១ព្រះសង្ឃទាំងអស់ឆាន់នៅលើទីបរិវេណខាងលើ ឧបាសក-ឧបាសិកាបរិភោគអាហារនៅទីបរិវេណខាងក្រោម ។

ម៉ោង១៣ប្រតិភូទាំងអស់ចេញដំណើរដោយរថយន្តសំដៅទៅចេតិយឈ្មោះមហាមុនិ ដើម្បីគោរពនមស្ការ ។

ចាប់តាំងពីក្លោងទ្វារទាំង ៤ ចូលទៅកាន់ព្រះចេតិយមហាមុនិនោះ មានចម្ងាយប្រហែល៥០០ម៉ែត្រ, សងខាងមាគ៌ាមានផ្សារលក់ដូរបូជនីយវត្ថុ មានផ្កាភ្ញីធូបគ្រឿងបរិក្ខារគ្រប់បែបគ្រប់យ៉ាង មានមនុស្សចូលទៅគោរពបូជាណែនណាន់តាន់តាប់គ្រប់ពេល នៅខាងក្នុងមហាមុនិចេតិយ មានព្រះពុទ្ធរូបស្ពាន់ទិបមាសមួយព្រះអង្គយ៉ាងធំប៉ុនគ្នានឹងព្រះជ័រខ្ទុះ ដែលស្ថិតនៅក្នុងវិហារប្រទេសយើងដែរ ។ ព្រះពុទ្ធរូបអង្គនេះគេនាំយកពីអាណាខេត្តអរកាន់ ឬ(យ៉ះខៃ)មកយូរហើយ, មានអ្នកជ្រះថ្លាបាននាំយកសង្ហារ-មកុដមាស-អលង្ការមាសដាំត្បូងមកបំពាក់ពេញព្រះវរកាយ, មានក្លស់-ចាមរ-បៃមនបើកបាំងពីខាងលើ ។ នៅបំពោះព្រះភក្ត្រ មានត្រួយព្រីងនឹងផ្កាស្រស់ៗផ្សេងៗ ដែលគេបូជាគ្រប់វេលា, មិនតែប៉ុណ្ណោះមាន ឧបាសកពីនាក់ឈរបក់ថ្វាយព្រះពុទ្ធរូបអង្គនោះយ៉ាងថ្នាក់ថ្នម តាំងពីព្រះសិរហូតដល់ព្រះបាទគ្រប់វេលាពុំស្ងប់ដែលខាន ។



ព្រះពុទ្ធរូបទិបមាស មួយព្រះអង្គធំ
ដែលស្ថិតនៅខាងក្នុងមហាមុនិចេតិយ

ម៉ោង ១៤ យើងទាំងអស់គ្នា ចេញពីព្រះមហាមុនិចេតិយទៅកាន់ព្រះចេតិយមួយធំរបស់ព្រះចៅមិនដុង ដែលមានព្រះចេតិយតូចៗ ព័ទ្ធជុំវិញចំនួន ៧២៩ តំកល់ផ្ទាំងថ្ម៧២៩ផ្ទាំង ចារឹកបាលីព្រះត្រៃបិដកមួយចប់ ក្នុងគ្រាចាត់ចែងធ្វើបញ្ចូមសង្គាយនានាក្រុងមណ្ឌលេ ដែលមានព្រះចៅមិនដុងជាព្រះបរមរាជូបត្ថម្ភ ។ យើងទាំងអស់គ្នាក៏បានទៅកាន់ភ្នំមណ្ឌលេ ដ៏ប្រដាប់ដោយព្រះចេតិយជាបូជនីយស្ថាន ចាប់តាំងពីជើងភ្នំរហូតដល់កំពូលភ្នំ ។ គណៈប្រតិភូទាំងអស់បានទៅសម្រាកទទួលភេសជ្ជៈដែលគេចាត់ចែងប្រគេន-ជូនក្នុងមហាកុដិមួយដ៏ធំរបស់ គាបសមួយរូប



ព្រះចេតិយព្រះជាមិនឌុង ដែលមានព្រះចេតិយតូចៗព័ទ្ធជុំវិញចំនួន ៧២៩ ដំកល់ផ្ទាំងថ្ម ៧២៩ ផ្ទាំងចារឹកបាលីព្រះត្រៃបិដកមួយចប់



មហាកុដិរបស់តាបសមួយរូបឈ្មោះ អ៊ូ.ខណ្ឌី

ឈ្មោះ អ៊ូ.ខណ្ឌី នៅនាជើងភ្នំនោះ ។ មហាកុដិនោះធំធេងល្វឹងល្វើយ មានជាន់ពីរ ។

ម៉ោង ១៨ បានត្រឡប់ពីទីគោរពផ្សេងៗ មកកាន់គ្រឹះស្ថានមហាវិទ្យាល័យ ជាកន្លែងសំណាក់វិញ ។

## ថ្ងៃចន្ទ ៨រោច ខែវិសាខ (២៤ ឧសភា)

ពេលអរុណរះ ប្រតិភូទាំងអស់ធ្វើបាតព្រឹសកិច្ច នៅនាគ្រឹះស្ថានមហាវិទ្យាល័យ ។ វេលាម៉ោង ៦ យើងទាំងអស់គ្នាចេញដំណើរដោយរថយន្តទៅកាន់កំពង់ផែទន្លេឥរាវតី នាំគ្នាចុះទៅក្នុងមហានាវា (កប៉ាល់) មួយឈ្មោះ ប៉.ដោគា ហើយចេញដំណើរឡើងច្រាស

ទឹកទៅទិសខាងជើង ។ នៅម៉ោង ៨ និង ៣០ នាទី បានទៅដល់ភូមិម៉ង់គុណា ហើយបានឡើងទៅ



សម្ដេចព្រះមហាសុមេធាធិបតីនឹងព្រះញាណបោណភិកមហាថេរ (ជាតិអាល្លឺម៉ង់) គង់ជាមួយគ្នានៅលើផែកប៉ាល់ (បះជើក) នាកំពង់តភរតី

មើលព្រះចេតិយ ព្រះចៅម៉ង់គុណា និងជួងមួយដ៏ធំបណ្ដាច់ក្នុងពិភពលោក ទម្ងន់ ៥៥.៥៥៥ នាឡិ ។ បន្ទាប់ពីនោះមក បានទៅទស្សនាព្រះចេតិយឈ្មោះ ម្យ:ស៊ុំផាំង ដែលធ្វើទៀបដោយក្ដី ព្រះបុមេប្រកបដោយកំសត្តបរិភណ្ឌ ពន្ធ ជុំវិញជាស្នាដៃនៃជនជាតិមន ។

ម៉ោង ១០ ប្រតិភូទាំងអស់បានទៅ ទទួលភត្តាហារដែលគេបាត់ចែងនៅមន្ទីរ សមាគមបំពាំមមនុស្សដកពិការ ។

ម៉ោង ១១ និង ៣០ នាទី យើងទាំងអស់គ្នាឡើងមហានាវាដដែលត្រឡប់បណ្ដោយទឹកមកកាន់ទិសខាងត្បូងវិញបង្ហួសក្រុងមន្ដលេរ ទៅកាន់ក្រុងសៈកែង ហើយឡើងរថយន្តទៅគោរពមហាចេតិយឈ្មោះ កាដម-ណាំឆូឡាដែលជាព្រះនាមព្រះមហាក្សត្រមួយព្រះអង្គបានកសាង ព្រះចេតិយនេះ កុងជំនាន់បន្ទាប់ជួសម័យនៃព្រះបាទធម្មាសោកជាព្រះចេតិយបុរាណ ហើយធំក្រៃលែង ។ ពុទ្ធបរិស័ទជាតិភូមាបានរៀបទទួលគេសជ្ជៈដល់ប្រតិភូទាំងអស់នៅទីនោះ ។ បន្ទាប់ពីនោះមក យើងទាំងអស់គ្នាបានទៅគោរពព្រះចេតិយឈ្មោះង៉ាដាជី (ចេតិយ៥ជាន់) មានព្រះពុទ្ធរូបទ្រង់សមាធិ មួយព្រះអង្គយ៉ាងធំប្រតិស្ឋានក្នុងទីនោះ ។ ក្រោយដែលបានគោរពនមស្ការរួច យើងទាំងអស់គ្នាក៏បានត្រឡប់មកកាន់ទន្លេ ឆ្លងសាឡាងមកត្រើយម្ខាង ហើយបន្តដំណើរតាមរថយន្តតាមផ្លូវមកកាន់ក្រុងមន្ដលេរវិញ ។

(ក្រុងមន្ដលេ និងសៈកែងនេះ សម្ដេចនឹងគណៈគ្នាបានឃើញម្ដងរួចទៅហើយ កាលពីឆ្នាំទៅមិញ) ។ លុះមកដល់ពាក់កណ្ដាលផ្លូវនៅវេលាម៉ោង ១៦ និង ៣០ នាទី ក្រុមជាងតម្បាញបានស្កាត់ទិមន្ត-អញ្ជើញប្រតិភូទាំងអស់ឲ្យឈប់សម្រាក ហើយប្រគេនគេសជ្ជៈដល់ព្រះសង្ឃ, ជូននំ-កាហ្វេ-ចំណីដល់ឧបាសកឧបាសិកា ។ល។ ពួកជាង

តម្បាញបាននាំប្រតិភូឲ្យមើលវិធីតម្បាញដោយដៃតាមរបៀបបូរាណ និងតម្បាញដោយម៉ាស៊ីនតាមទំនើប ព្រមទាំងមើលកម្មករដែលគិតថ្មីនូវរាក់សរបោះពុម្ពផ្សាយរូបភាពនៅលើសំពត់ ច្រើនបែបច្រើនយ៉ាង ។ល។ អ្នកធ្វើការទាំងនេះជាយុវជន ទាំងស្រី ទាំងប្រុស សុទ្ធតែជាជាតិភូមាទាំងអស់ ។

ម៉ោង ១៧ យើងទាំងអស់គ្នាបានត្រឡប់មកកាន់ទីសំណាក់នៅក្រុងមន្តលេវិញ ។

## ថ្ងៃអង្គារ ៩ រោច ខែវិសាខ ( ២៥ ឧសភា)

វេលាម៉ោង ៤ ទៀបភ្លឺ យើងទាំងអស់គ្នារៀបចំប្រដាប់ប្រដាចេញពីគេហស្ថានមហាវិទ្យាល័យក្រុងមន្តលេ ទៅកាន់កំពង់ទន្លេឥរាវតី ហើយឡើងមហានាវា ប៉ះដោគ ពីថ្ងៃម្សិល ឆ្ពោះទៅក្រុងប៉ាគាន (ភូគាម) តាមផ្លូវទឹក ។ នាវាចេញដំណើរបណ្ដោយទឹកទៅទិសខាងត្បូង ។ ពួកប្រតិភូទាំងអស់បានធ្វើបាតកាសកិច្ចនិងភត្តកិច្ចនៅលើមហានាវានោះ ។ យើងធ្វើដំណើរអស់មួយថ្ងៃពាល់ល្ងាច រហូតដល់ម៉ោង ១៧ ទើបបានដល់ទៅភូមិមួយឈ្មោះ ប៉ះកុក្កុ នាវាគ្រាន់តែឈប់បន្តិច ក៏បន្តដំណើរទៅទៀតដរាបដល់ពេលព្រលប់ម៉ោង ១៩ បានទៅដល់តម្បន់មួយឈ្មោះ ញ៉ោងអ៊ូ ទើបចតឈប់សំណាក់នៅទីនោះ ។ ទីនេះហើយ ដែលជាខែត្រប៉ាគាន (ភូគាម) ជាកដតាទីបូរាណមួយរបស់ប្រទេសភូមា សឹងមានរឿងរ៉ាវទាក់ទងជាមួយនឹងប្រទេសកម្ពុជាយើងតាំងពីសម័យបូរាណ(ដែលមាននិយាយពីព្រះបាទអនុរុទ្ធព្រះចៅក្រុង អរិធ្ធមៈ គឺក្រុងប៉ាគានឬភូគាមនេះ បានចងស្ពានមេត្រីជាមួយនឹងប្រទេសកម្ពុជា) អ្នកប្រវត្តិសាស្ត្រ គង់ជ្រាបរឿងនេះយ៉ាងពិស្ដារដែរហើយ ។

នៅទីនេះពួកមន្ត្រីស្រុក និងតំណាងរាស្ត្រ បាននាំគ្នាមកថ្វាយបង្គំសម្ដេចព្រះមហាសុមេធាធិបតី និងព្រះថេរអង្គដទៃ ៗ មានព្រះវិមលធម្មជាដើម ។ ក្នុងបណ្ដាព្រះសង្ឃទាំងអស់ មានព្រះសង្ឃអង្គខ្លះក៏និមន្តឡើងទៅគង់នៅវត្តក្នុងស្រុកនោះ, ព្រះសង្ឃខ្លះនៅគង់លើនាវា(ប៉ះដោគ), ចំណែកឧបាសក-ឧបាសិកា នៅសំណាក់លើនាវាទាំងអស់គ្នា ។ ពួកមន្ត្រីក្នុងស្រុក បានចាត់កងរក្សាខត្រូវឲ្យមកយាមល្បាតប្រចាំការ ដើម្បីការពារសន្តិសុខនៅជុំវិញមហានាវាដរាបដល់ភ្លឺ ។

## ថ្ងៃពុធ ១០ រោច ខែវិសាខ (២៦ ឧសភា)

វេលាព្រឹក ប្រតិភូទាំងអស់ធ្វើបាតកាសកិច្ចនៅលើមហានាវាដូចថ្ងៃមុន ។ ម៉ោង ៧ មានរថយន្តតូច-ធំមកទទួលប្រតិភូទៅទស្សនាបូជនីយស្ថានផ្សេង ៗ ដែលនៅឆ្ងាយពីកន្លែងចំនួនបី-បួនគីឡូម៉ែត្រ ។



សព្វញ្ញុចេតិយ

-យើងទាំងអស់គ្នាទៅគោរពសព្វញ្ញុ-ចេតិយ ។ ចេតិយនេះ ព្រះចៅអលោងសិទ្ធុ បានកសាងក្នុងគ.ស. ១.១៤៤ (៨១០ ឆ្នាំកន្លងទៅហើយ) មានកំពស់ ៦១ ម៉ែត្រ ខ្ពស់ជាងចេតិយនានាក្នុងទីនោះ, មានជាន់ ៥ ជាន់ទី ១ និងទី ២ សម្រាប់ជាលំនៅនៃភិក្ខុសង្ឃ, ជាន់ទី ៣ ជាទីតម្កល់ព្រះពុទ្ធរូប, ជាន់ទី ៤ ជាបណ្ណាល័យ, ឯជាន់ទី ៥ គេប្រាប់ថាមានតម្កល់ព្រះបរមសារីរិកធាតុ ព្រោះហេតុនោះចេតិយនេះជាវត្ថុផង ជាបូជនីយស្ថានផង ។ ព្រះពុទ្ធរូបក្នុងព្រះចេតិយនេះ, តាមការកត់សង្កេត, មានទ្រង់ទ្រាយហាក់ដូចជាព្រះពុទ្ធរូបនៅប្រទេសខ្មែរយើងសុទ្ធសាធ ជាវត្ថុស័ក្តិសិទ្ធិ ព្រោះហេតុនោះបានជាមានភ្ញៀវអត្ថិសនី ដែលគេបន្តពីទីយ៉ាងឆ្ងាយមកអុជបំភ្លឺពលក្រើ ។

-បន្ទាប់មក បានទៅគោរព ព្រះចេតិយអនន្ទ (គឺជាការវិសេសកែនៃពាក្យអនន្តប្បញ្ញា "មានប្រាជ្ញាឥតទីបំផុត" ដែលជាព្រះបរមនាមនៃព្រះសម្ពុទ្ធបរមគ្រូ ដូចពាក្យថាសព្វញ្ញុចេតិយមុននោះដែរ ។ នៅខាងក្នុងព្រះចេតិយនេះ មានព្រះពុទ្ធរូបអង្គធំបួនព្រះអង្គទ្រង់ប្រតិស្ឋាន(ឈរ) មានព្រះហស្តជាធម្មចក្រមុទ្រ: បែរព្រះភ័ក្ត្រទៅកាន់ទិសទាំង ៤ ។

នៅតាមជញ្ជាំងពេងទងជុំវិញ ខាងស្តាំ-ខាងឆ្វេង ខាងលើ-ខាងក្រោម មានរូបចម្លាក់ជាដំណាលរឿងរ៉ាវពុទ្ធជាតកនិងពុទ្ធប្រវត្តិដោយសព្វគ្រប់, ចេតិយនេះមានកំពស់ជិត ៦០ ម៉ែត្រ ដែលជាបូជនីយស្ថានរបស់ព្រះចៅចន្ទជិត ទ្រង់កសាងក្នុង គ.ស.១.០៩១, មុនសព្វញ្ញុចេតិយបន្តិច ។ ព្រះចៅអលោងសិទ្ធុ ជាព្រះរាជនត្តារបស់ព្រះចៅ ចន្ទជិតនេះឯង ។ ព្រះរាជាទាំងនេះ សុទ្ធសឹងតែជាជាតិមង ។ បន្ទាប់មក បានទៅមើលឧបាលិសីមាជាវិហារមួយតូចល្មមភិក្ខុប្រហែល ១០០ រូបគង់បាន ។ នាពិតាន មានរូបគំនូរចាំពណ៌ដែលគង់វង្សនៅល្អជាច្រើនកន្លែង ។ វិហារនេះគេកសាងឡើងក្នុងសតវត្សទី ១៣ នៃគ.ស. ។

ជាកំដាប់មក យើងទាំងអស់គ្នា បានទៅគោរពជយភូមិចេតិយដែលព្រះចៅអនុរុទ្ធបានបញ្ចុះសំណាកព្រះចង្កូមនៅលង្កាទ្វីប ។ ព្រះចេតិយនេះ ពុំមែនត្រឹមតែព្រះចៅ អនុរុទ្ធ កសាងតែមួយព្រះអង្គ ហើយបោះបង់ចោលទេ, គង់កាលខាងក្រោយមក ព្រះមហាក្សត្រច្រើនព្រះអង្គមានព្រះបាទ ត្រីភុវនអាទិត្យជាដើមបានកសាងបន្ថែមលំអតៗមកទៀតដែរ ។ ព្រះចេតិយនេះ មានជើងកោស ៣ជាន់ជានិមិត្តរូបនៃព្រះរត្នត្រ័យ ។ នៅតាមជើងកោសទាំង ៣ ជាន់នេះ មានរូបចម្លាក់តំណាលជាតកទាំង ៥០០, មានព្រះពុទ្ធរូបថ្មកែវច្រើនព្រះអង្គ; មានទ្វារខ្លះធ្វើដោយឈើម៉ៃសាក់ ដែលគង់វង្សល្អរាប់ ៣០០ ឆ្នាំកន្លងទៅហើយ ។ល។


ជយភូមិចេតិយ ដែលព្រះចៅអនុរុទ្ធបញ្ចុះសំណាកព្រះចង្កូមនៅលង្កាទ្វីប

ម៉ោង ១០ ប្រតិភូទាំងអស់បានត្រឡប់មកទទួលភោជនាហារ នៅឯនាវាវិញ ។

-នៅវេលារសៀល មគ្គុទ្ទេសក៍ បាននាំប្រតិភូទៅគោរពចេតិយនិងបូជនីយស្ថានដទៃទៀតជាច្រើនកន្លែង ដែលអាត្មាមិនអាចនឹងនាំមកពណ៌នាឲ្យសព្វគ្រប់គង់ទីនេះបាន ព្រោះក្រុងប៉ាគាននេះជាចេតិយគ្រាម សម្បូរដោយព្រះចេតិយនឹងគណនាពុំអស់ ។ ទោះទាំងទស្សនាវដ្ដីអាមេរិកក៏បានឲ្យឈ្មោះថា ប៉ាគានជាក្រុងមានលំអដោយព្រះចេតិយបួនលាន (PACAN The city of four million Pagodas) ។

ប៉ាគានជារាជធានីនៃប្រទេសភូមាក្នុងសតវត្សទី ១១ នៃ គ.ស., ព្រះចៅ អនុរុទ្ធ បានប្រមូលដែនតូចៗជាច្រើនរួមបញ្ចូលជាព្រះរាជអាណាចក្រតែមួយ ហើយកសាងរាជធានីនៅត្រង់ទីនេះឡើង ។

ព្រះចៅ អនុរុទ្ធ និងព្រះចៅដែលសោយរាជ្យជាតំណខាងក្រោយមក បានកសាងព្រះចេតិយជាលំដាប់លំ-ដោយគ្នា រហូតដល់មានចំនួនច្រើន (រាប់លាន) យ៉ាងនេះ ។ ដោយហេតុនេះ ក្រុងប៉ាគានជាឃ្លាំងនៃការរចនាដ៏រុងរឿងរហូតដល់ គ. ស. ១.២៨៧ ពេលដែលជាតិម៉ុងហ្គោលចូលមកលុកលុយ ។

ដោយហេតុក្រុងប៉ាគាន ជាបុរាណរាជធានី ដ៏ដេរដាសដោយចេតិយកប់លានស៊េរតែគេទុំនេរធ្វើ ស្រេចម្ការពុំបានយ៉ាងនេះហើយ បានជាអ្នកស្រុកនោះទៅជាអ្នកឈ្លាសវៃខាងវិចិត្រសិល្បកម្មតាំងស្រ៊ីតាំងបុរស បេះត្បាញបន្ទោះឫស្សីតូច ៗ ខ្ចក់ម្រ័ក្សណ៍បញ្ចុះថ្នាំបុទ្ធមាសជារូបគំនូរផ្សេង ៗ ធ្វើជាប្រអប់ស្លា, ផ្តិលទឹកជាដើម ដ៏ល្អត្រកាលគួរឲ្យចាប់ចិត្ត ។ ពួកប្រតិភូឃើញហើយនាំគ្នាប្រញាប់ជណ្ដើមទិញ, ខ្វះបានបានស្រាក់, ខ្វះប្រអប់ស្លា, ផ្តិល, ចាន. ចាស, ឬផ្កាជាដើម សុទ្ធសឹងតែគ្រឿងខ្ចក់ស្នាដៃអ្នកប៉ាគាន ដើម្បីយកមកទុកជាអនុស្សរណវត្ថុ ចែកញាតិមិត្តមើល ។

ព្រះរាជធានី ប៉ាគាន ស្ថិតនៅនាត្រើយខាងកើតទន្លេឥរាវតី ចម្ងាយ ៦៤០ គ.ម. ទៅខាងជើងក្រុងរ៉ង្គូន. ប្រហែល ២០០ គ.ម. ទៅខាងត្បូងក្រុងមណ្ឌលេ ។ល។

ម៉ោង ១៩ ឥស្សរជនស្រុក ញ៉ោងអ៊ូ បាននិមន្ត អញ្ជើញប្រតិភូទាំងអស់ទៅកាន់ទីព្រះចេតិយឈ្មោះ ស៊ុវេស៊ីគុន ដែលស្ថិតនៅក្នុងទីប្រជុំជនស្រុកនោះ, មានឧបាសកឧបាសិកាអង្គុយត្រៀបត្រាណែនណាន់តាន់តាប់ ក្រោមពន្លឺភ្លើងអគ្គិសនី ជាមហាសន្និបាតមួយ ។

( នៅប្រទេសភូមា ដោយហេតុផលិតផលមានអណ្ដូងប្រេងសាំងកើតនៅក្នុងប្រទេសគេ នាំឲ្យសម្បូរអាចប្រើម៉ាស៊ីនភ្លើងអគ្គិសនីគ្រប់ទីជនបទ ទោះតំបន់តូចតាចយ៉ាងណាក៏មានភ្លើងអគ្គិសនីប្រើដែរ ) ។

ក្នុងពេលដែលប្រតិភូទាំងអស់ បានអង្គុយតាមអាសនៈរៀងខ្លួនហើយ មានឥស្សរជននៅស្រុកញ៉ោងអ៊ូ ម្នាក់ថ្លែងសេចក្ដីប្រកាសអំពីសោមនស្សជាភាសាភូមា រៀបរាប់អំពីឱកាសដ៏ល្អដែលបានជួបបានឃើញព្រះសង្ឃ ព្រមទាំងឧបាសក-ឧបាសិកា ជាប្រតិភូគ្រប់ប្រទេស គ្រប់ជាតិ គឺ កម្ពុជា, ថៃ, លាវ, ប៉ាគីស្ថាន, លង្កា, ឥណ្ឌា, នេប៉ាល់, វៀតណាម ជាដើម ដោយការនិមន្តការអញ្ជើញមកធ្វើឆដ្ឋសង្គាយនា ។ល។

បន្ទាប់មក ឧបាសក-ឧបាសិកា បានអារាធនាសុំសីលប្រាំ ។ ព្រះចន្ទមុនី មហាថេរ ជាតិភូមា (ដែលនិមន្តទៅគង់នៅកុសិនារាប្រទេស ឥណ្ឌា អស់កាលយូរ) ជាអ្នកឲ្យសីល ។

មានតំណាងមហាសន្និបាតមួយនាក់ អារាធនាសម្ដេចព្រះមហាសុមេធាធិបតី ប្រធានប្រតិភូខ្មែរជាដើម សុំឲ្យធ្វើបាឋកថា ។ សម្ដេចក៏បានផ្ដើមថ្លែងសេចក្ដីជាភាសាខ្មែរ ដោយព្រះវរធម្មវរមហាថេរ បានបកប្រែជាភាសាអង់គ្លេសថា ៖

សូមអស់លោក-អ្នកពុទ្ធបរិស័ទទាំងឡាយជ្រាប !

ខ្ញុំព្រះករុណា-អាត្មា ដែលបានមកកាន់ទីប្រជុំនេះ អាស្រ័យពុទ្ធបរិស័ទប្រទេសភូមា មានរដ្ឋាភិបាលជាប្រមុខ បាននិមន្តពីគ្រប់ប្រទេសមកធ្វើធម្មសង្គាយនា ។ និយាយចំពោះតែប្រទេសខ្មែរមានប្រតិភូបព្វជិត ចំនួន ១០ រូប ឧបាសក-ឧបាសិកាចំនួន ៨ នាក់ ដែលព្រះករុណាជាម្ចាស់ជីវិត ព្រះបាទសម្តេចព្រះនរោត្តមសីហានុវរ្ម័ន នឹងព្រះរាជរដ្ឋាភិបាលបានចាត់បញ្ជូនឲ្យមករួមកិច្ចការធ្វើធម្មសង្គាយនាជួយលើកតម្កើងព្រះពុទ្ធសាសនា ដើម្បីនឹងបានចំរើនរុងរឿងផ្សាយសេចក្តីសុខ ឲ្យកើតមានទូទៅក្នុងពិភពលោក ដោយមានប្រទេសភូមាជាអ្នកផ្តើមគំនិត រួបរួមគ្នាធ្វើធម្មសង្គាយនា ។

ព្រោះហេតុនោះហើយ បានជាប្រទេសខ្មែរព្រមព្រៀងដោយស្មោះស្ម័គ្រ បានបញ្ជូនព្រះត្រៃបិដកមករួបរួមជាមួយ ទោះបីបោះពុម្ពមិនទាន់ចប់ ក៏ខំប្រឹងឲ្យសរសេរចម្លងដោយដៃ ហើយដេរជាសៀវភៅផ្ញើមកជូន...។ល។

នៅទីបញ្ចប់សម្តេចបានសូត្រគាថាដែលចេញអំពីយោបល់របស់សម្តេច ប្រទានសាធុការពរថា៖

បរម្មាភសី សុខិតា ច និព្ភយា
ពុទ្ធស្ស ធម្មេ ឋិតការា ច ហោន្តុ តេ
យំ យញ្ញ ឥច្ឆន្តិ យថិច្ឆិតំ សទា
តំ តញ្ញ តេសំ តុរិតំ សមិជ្ឈតុ !

ព្រះបាលីគាថានេះបើប្រែជាខ្មែរថា "សូមឲ្យអស់លោកអ្នកទាំងឡាយដែលនៅក្នុងប្រទេសភូមា មានសេចក្តីសុខ ឃ្លាតចាកភ័យ សូមឲ្យឋិតនៅក្នុងពុទ្ធធម៌, បើអស់លោកអ្នកប្រាថ្នានូវវត្ថុណាស្ង ៗ ឲ្យវត្ថុនោះៗបានសម្រេចយ៉ាងរួសរាន់ទាន់ចិត្ត តាមសមគួរដល់សេចក្តីប្រាថ្នា !"

លុះចប់បាឋកថាសម្តេចហើយ មហាសន្និបាតបានបន្លឺស័ព្ទសាធុការថាសាធុៗ ៣ដងព្រមៗគ្នា ។

-ព្រះមហាវិមលធម្ម ប្រធានគណៈប្រតិភូថៃ បានថ្លែងសេចក្តីជាភាសាថៃ អបអរសាទរចំពោះបដិសណ្ឋារកិច្ចនៃអ្នកស្រុកញ៉ាំងអ៊ូ ដោយមានអ្នកបកប្រែជាភាសាភូមា ។

- ព្រះមហាប្រឌិត ប្រទេសលាវ ថ្លែងសេចក្តីជាភាសាថៃ ដោយមានអ្នកបកប្រែជាភាសាភូមាដែរ ។

- សេចក្តីថ្លែងភិក្ខុមួយរូបជាតំណាងមហាពោធិសមាគម ។

- សេចក្តីថ្លែង ភិក្ខុធីបង្ករ តំណាងប្រទេស ប៉ាគីស្ថាន ។

-សេចក្ដីថ្លែង ព្រះញាណតិលោកមហាថេរ(ជាតិអល្លឺម៉ង់) តំណាងប្រទេសអល្លឺម៉ាញ ។

-សេចក្ដីថ្លែង អ៊ូចន្ទ្រមុនីមហាថេរ ជាតិភូមា នៅក្រុងកុសិនារា ។

-សេចក្ដីថ្លែង ភិក្ខុ ឆាតត្នេរ តំណាងប្រទេស វៀតណាម ។

នៅទីបំផុតលោកចៅហ្វាយស្រុកញ៉ាន់អ៊ូ ថ្លែងសេចក្ដីតបជាភាសាភូមា មហាសន្និបាតទទួលអំណរ ៗ ពេលនោះ រាត្រីកាលក៏កន្លងទៅយូរណាស់ហើយ ទើបមហាសន្និបាតបានលើកពេលប្រជុំ ។ ប្រតិភូទាំងអស់ត្រូវត្រឡប់ទៅទីសំណាក់នៅទីផ្សេងៗរៀងខ្លួនវិញ ។

---

## ថ្ងៃព្រហស្បតិ៍ ១១ រោច ខែវិសាខ (២៧ ឧសភា)

ពេលព្រឹក ប្រតិភូទាំងអស់ធ្វើបាតកសកិច្ចនៅលើនាវាដដែល ៗ បន្ទាប់ពីនោះមក ពួកពុទ្ធបរិស័ទអ្នកស្រុកញ៉ាន់អ៊ូ មានលោកចៅហ្វាយស្រុកជាប្រធាន បានដង្ហែព្រះពុទ្ធរូប ៦ ព្រះអង្គមកប្រគេន ដោយបានផ្សងចាប់ស្លាកពីលើកទៅទីប្រជុំរបស់គេឯណោះ ។

លើកដំបូង ព្រះពុទ្ធរូបមានតែ ៦ ព្រះអង្គ ឯគណៈប្រតិភូមានច្រើនប្រទេស មិនដឹងជានឹងត្រូវប្រគេនប្រគល់ទៅគណៈប្រតិភូជាតិណាខ្លះ? ម្លោះហើយទើបត្រូវផ្សង ហើយចាប់ស្លាក ដែលបានលទ្ធផលដូចខាងក្រោមនេះ៖

១- កម្ពុជា

២- ថៃ

៣- អល្លឺម៉ាញ

៤- លង្កា

៥- នេប៉ាល

៦- ឥណ្ឌូណេស៊ី

លើកទី ២ ព្រះពុទ្ធរូបមានច្រើនបែបច្រើនយ៉ាង ជាវិការៈនៃថ្មក៏មាន ជាវិការៈនៃឈើក៏មាន មិនដឹងជាត្រូវប្រគេនព្រះពុទ្ធរូបអង្គណាទៅគណៈប្រតិភូប្រទេសណា បណ្ដាប្រទេសទាំង ៦ ខាងលើនេះ? ទើបត្រូវផ្សងហើយចាប់ស្លាកម្ដងទៀត ដែលបានលទ្ធផលដូចខាងក្រោមនេះ៖

១ - កម្ពុជា  បានព្រះពុទ្ធរូបបូរាណកន្លង៨០០ឆ្នាំទៅហើយជាវិការៈនៃឈើម៉ៃសាក់  ទ្រង់ឃ្លុំចីវរពាក់ផ្ទត់សង្ឃាដីពីលើ ព្រះហស្ថខាងស្តាំកាន់ផ្លែស្រម៉  ។




ព្រះពុទ្ធរូបបូរាណកន្លង៨០០ឆ្នាំមកហើយជាវិការៈនៃឈើម៉ៃសាក់ទ្រង់ឃ្លុំចីវរព្រះហស្តខាងស្តាំកាន់ផ្លែស្រម៉ដែលសង្ឃបីចុះពីអាកាសយាន ។

២ – ថៃ  បានព្រះពុទ្ធរូបបូរាណជាវិការៈនៃឈើម៉ៃសាក់ដែរ  ។

៣ – អល្លឺម៉ាញ  បានព្រះពុទ្ធរូបថ្មកែវ  ។

៤ – ពរដ្ឋា  បានព្រះពុទ្ធរូបជាវិការៈនៃឈើខ្មឹម  ។

៥ – នេប៉ាល  បានព្រះពុទ្ធរូបជាវិការៈនៃឈើខ្មឹម  ។

៦ – ឥណ្ឌូណេស៊ី  បានព្រះពុទ្ធរូបជាវិការៈនៃថ្មកែវ  ។

ប្រតិភូទាំង ៦ ប្រទេសខាងលើនេះ បានទទួលព្រះពុទ្ធរូបទាំងនេះហើយក៏អនុមោទនាជូនកុសលដល់អ្នកស្រុករ៉ង្គូននៅលើនាវានោះឯង  ។

មួយសន្ទុះក្រោយមក មហានាវានោះ ក៏ចេញចាកស្រុករ៉ង្គូនបន្តដំណើរទៅទៀត ។  ក្រោយដែលបានសម្រេចកត្តកិច្ចរួចហើយ  នៅវេលាម៉ោង១០និង៣០នាទី  នាវាបានទៅដល់ស្រុកឧក្រាំយ៉ា  ហើយចតឈប់នៅទីនោះ ។  ប្រតិភូទាំងអស់នាំគ្នាអើតងើតមើលទៅត្រើយសងខាងទន្លេឃើញរន្ទាដែកច្រើនច្រាងកប់មិនអស់ ។

ទីនេះហើយជាកន្លែងអណ្តូងប្រេងសាំង-ប្រេងកាត ដែលគេដម្លើងគ្រឿងម៉ាស៊ីនស្រូបយកប្រេងបង្ហូរទៅក្នុងតម្រងបញ្ចេញប្រេងសាំង-ប្រេងកាតនាំយកផលិតផលនោះមកប្រើប្រាស់ ទាំងចំណាយទៅប្រទេសជិតខាងផង ។

ពីទីនេះទៅក្រុងរង្គូន ចម្ងាយ ៤៨០គ.ម. មានផ្លូវគមនាគមន៍ទាំង៣ប្រភេទ គឺផ្លូវគោក-ទឹក-អាកាស ។

ម៉ោង ១១-៣០នាទី ប្រតិភូទាំងអស់ ឡើងពីនាវាទៅស្ថានីយយន្តហោះឧក្យាំយ៉ាដែលនៅជិតកំពង់នោះ ។

ម៉ោង ១២ ព្រះសង្ឃខ្មែរ - ថៃ និងព្រះមហាថេរភូមា ៖ ចំនួន២៦រូប ព្រមទាំងឧបាសក២នាក់ថែមទៀត រួមទាំងអស់២៨រូប ឡើងអាកាសយានទី១ ចេញដំណើរត្រឡប់មកក្រុងរង្គូនវិញ ។

ពួកប្រតិភូ ពុំអាចមកក្នុងថ្ងៃនោះ ទាំងអស់គ្នាបាន ដោយមេឃពុំស្រួល កាលមានភ្លៀងខ្យល់ខ្លាំង អាកាសយានមិនហ៊ានទៅទទួលយក ដរាបដល់ថ្ងៃស្អែកទើបបានមកទាំងអស់គ្នា ។

យន្តហោះទី១ដែលយើងជិះក្នុងថ្ងៃនោះមក បានមកដល់ស្ថានីយអាកាសយានមង្គលដុងក្រុងរង្គូន ទាំងកំពុងភ្លៀងជ្រោំ នៅវេលាម៉ោង ១៤និង ១០ នាទី ។ សមាជិកគណៈកម្មការរបស់ពុទ្ធសាសនសភាបានយករថយន្តតូច-ធំ មករង់ចាំទទួលសម្តេចនិងព្រះសង្ឃទាំងអស់ មកកាន់មហាកុដិបុព្វារិវេហាទីលំនៅដើមរបស់យើងវិញ ។

## ថ្ងៃសុក្រ ១២ រោចខែវិសាខ (២៨ ឧសភា)

វេលាម៉ោង១០លោកអ៊ូតាន់សេង លេខាធិការនៅក្រសួងធម្មការ បានយករថយន្តតូច-ធំមកនិមន្តព្រះសង្ឃខ្មែរ-ថៃ-លាវ មានចំនួនរួមទាំងអស់៣៧ រូប ដង្ហែជាក្បួនដូចកាលទៅសណ្ឋាគារឯកឧត្តមនាយករដ្ឋមន្ត្រីនិងឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការ, ទៅទទួលភត្តាហារនាគេហស្ថានរបស់លោក ។ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងធម្មការព្រមទាំងលោកជំទាវក៏បានអញ្ជើញទៅជាភ្ញៀវក្នុងឱកាសនោះដែរ ។ ម្ហូបអាហារមានបរិបូរពោរពាស ។ អាត្មាសូមបញ្ជាក់ថា ទោះបីទៅទទួលភត្តាហារនៅទីណា ហើយបរិបូរពាសពេញយ៉ាងណាក៏ដោយ គង់សុទ្ធតែជាម្ហូបអាហាររបស់ជាតិគេទាំងអស់ ឥតមានម្ហូបអាហារបរទេសចូលលាយឡំផងទេ ។

លុះសម្រេចភត្តកិច្ចរួច សម្តេចបានប្រទានសីល ហើយផ្តើមចំរើនព្រះបរិត្តពុទ្ធមន្ត សូត្រ ករណីយ.... ឥតិបិ សោ.... ស្វាក្ខាតោ...... សុប្បដិបន្នោ...... អរញ្ញេ.... ឧត្តាភេត... ភវតុសព្វ.... ។

លុះដល់ត្រឡប់មកវិញក៏មានក្បួនជូនដូចកាលទៅដែរ ។

ម៉ោង ១៣ សម្តេច, ព្រះវិន័យធរអនុគណ និងព្រះវិរធម្មវរមហាថេរបានទទួលនិមន្តទៅកាន់ពិធីបញ្ចុះសីមា

នៅវត្ត ជៅហ្វោគូ, តម្បន់ហ្វោគូ ចម្ងាយពីក្រុងរ៉ង្គូនប្រហែលជាង ៣០ គ.ម. ។ ឮថា មានក្បួនពុទ្ធបរិស័ទឈរចាំទទួលរាំងកណ្ដាលភ្លៀងដែលទទឹកស្រែកក់ ដើម្បីប្រគេនក្បួនផ្កាហើយសូត្រធម៌ទទួលផង ។ ឮថា ក្នុងតម្បន់នោះមានភូមិ ៤៨ ឯក្នុងទីប្រជុំបុណ្យនោះ មានមនុស្សប្រហែល ៣០០០ នាក់ ។ ដរាបដល់ម៉ោង ១៩ ទើបសម្ដេចនិងព្រះថេរៈទាំងពីររូបត្រឡប់មកដល់ទីកន្លែងវិញ ។

ម៉ោង ២២ ភិក្ខុ អ៊ូ ១ មាចារៈ ដែលសម្ដេចបានចាត់ឲ្យទៅព្រមានកន្លែងអាកាសយាន បម្រុងនឹងត្រឡប់មកក្រុងបាងកកប្រទេសថៃវិញក្នុងថ្ងៃស្អែកនោះ ទើបបានទទួលទូរស័ព្ទពីក្រុមហ៊ុនយន្តហោះ ប្រាប់ថាយើងបានឱកាសនឹងត្រឡប់មកក្នុងថ្ងៃស្អែកហើយ ត្រូវរៀបចំប្រដាប់ប្រដា ។ល។

## ថ្ងៃសៅរ៍ ១៣ រោច ខែវិសាខ (២៩ ឧសភា)

ម៉ោង ៩ និង ៣០ នាទី ទើបក្ញីបាស់ ព្រះវេនេត មហាថេរ ញ៉ោង យ៉ាន់ សាយ៉ាឌូ បាននិមន្តសម្ដេច, ព្រះឧបាលិវង្ស, ព្រះធម្មវង្សាធិបតី, ព្រះវីរធម្មវរមហាថេរ និង ព្រះមហា គ.ស. ធម្មធីរោ ទៅទទួលបាតរាសាហារ នៅវត្ត សាសនៈ យុគ្គតា, (កន្លែងដែលសម្ដេចនិងអាត្មា បានសំណាក់អាស្រ័យកាលពីឆ្នាំមុន) ជាទីបង្ហាត់បង្រៀនខាងវិបស្សនាធុរៈ ទាំងជាប្រមុខលើទីវិបស្សនាធុរៈនានាក្នុងប្រទេសភូមាផង ។ កន្លែងនេះហើយ ដែលសម្ដេចបានផ្ដាំផ្ញើបម្រុងឲ្យព្រះមហា គ.ស. ធម្មធីរោ នៅហាត់រៀន បន្ទាប់អំពីពេលបិទសម័យប្រជុំ ទី ១ នៃឆដ្ឋសង្គាយនាតទៅ ។ ព្រះថេរដែលបង្ហាត់បង្រៀនខាងវិបស្សនាធុរៈក្នុងទីនេះ គឺ ព្រះអគ្គមហាបណ្ឌិត ភទន្ត សោភណ ជាបុច្ឆកត្ថេរ ក្នុងឆដ្ឋសង្គាយនា ។ ព្រះមហាថេរអង្គនេះពុទ្ធបរិស័ទ នៅប្រទេសភូមាគោរពរាប់អានថាលោកមានគុណសម្បត្តិសមត្ថភាពដ៏បរិបូណ៌ខាងគន្ថធុរៈនិងវិបស្សនាធុរៈ ។ ព្រះមហាថេរអង្គនេះ បាននិមន្តមកកាន់ប្រទេសយើងម្ដងជាមួយនឹងព្រះវេនេតមហាថេរ ញ៉ោង យ៉ាន់ សាយ៉ាឌូ ក្នុងពិធីបុណ្យទទួលព្រះបរមសារីរិកធាតុនិងព្រះអគ្គសាវកធាតុ កាលពីថ្ងៃ ទី ៥ តុលា គ.ស. ១៩៥២ ។

ម៉ោង ១៧ ក្រោយដែលបានលាគលាឥស្សរជនជាតិភូមាហើយ, យើងទាំងអស់គ្នាមានសម្ដេចជាប្រធាន បានចេញដំណើរចាកបុព្វវិទេហមហាកុដិ ទៅស្ថានីយយន្តហោះមង្គលដុន ដោយមានឥស្សរៈជននិងក្បួនជូននាយទាហានជិះរថក្រយានយន្តហែហមអមមុខក្រោយមកផង ។ ក្រៅពីភិក្ខុប្រតិភូខ្មែរ ៥ រូប ដែលត្រូវនៅបំពេញកិច្ចការនៃឆដ្ឋសង្គាយនា ដរាបដល់បិទសម័យប្រជុំលើកទី ១ នោះ, ភិក្ខុអ៊ូ ១ មាចារៈ ១ ម៉ោងបាថ្វេ ១ និងឧបាសិកា

ស៊ុំឈឿន ជាញោមអាត្មា ១ ទាំង ៣ រូបនេះ ក៏បានសុំនៅបន្តពេលចាំមកជាខាងក្រោយ ។

លុះមកដល់ស្ថានីយយន្តហោះ បានបំពេញកិច្ចលិខិតឆ្លងដែនទាំងចំណីប្រដាប់ប្រដាសព្វគ្រប់ហើយ នៅវេលាម៉ោង២០ យើងទាំងអស់គ្នា ក៏បានលាគណអ្នកជូនដំណើរមកទាំងប៉ុន្មាន ឡើងអាកាសយានថៃកង្ហាល់៤ ដែលទើបនឹងត្រឡប់មកពីក្រុងកល់កត្តា ចេញដំណើរឆ្ពោះមកក្រុងទេពមហានគរ(បាងកក)ជាមួយនឹងព្រះសង្ឃនិងគ្រហស្ថជាតិថៃនឹងលាវខ្លះ ៗ ម៉ោង២២កូមា គឺម៉ោង២២-៣០ (ថៃ) ម៉ោង២៣-៣០ (កម្ពុជា) យន្តហោះធុនធំនេះ បាននាំយើងមកដល់ខាងលើក្រុងបាងកកដែលយើងអាចស្គាល់បានយ៉ាងជាក់ ដោយឃើញពន្លឺភ្លើងអគ្គិសនីបំភ្លឺផ្កាភ្ញី លព្រាលភ្លើតភ្លើនជាទីទស្សនា ។

យន្តហោះបានបន្ទាបខ្លួនចុះចតនៅស្ថានីយអាកាសយាន ដនមឿង ឥតមាននរណាម្នាក់មកចាំទទួលយើងសោះ ព្រោះទូរលេខដែលសម្ដេចបានឲ្យវាយមកពីប្រទេសភូមាកាលពីព្រឹកនោះ មិនទាន់មកដល់នៅឡើយ ប៉ុន្តែទុកណាជាដូច្នោះ ក៏មិនជាអ្វី អាត្មាខំប្រឹងបំពេញកិច្ចការ រឿងលិខិតឆ្លងដែននឹងការទទួលយកប្រដាប់ប្រដាពីក្រុមហ៊ុនយន្តហោះវិញពីរនាក់នឹងអ្នកមហាញូង-ជាឆអស់រយៈកាលចំនួនមួយម៉ោង ក៏បានហើយស្រេច ទើបយើងទាំងអស់គ្នាឡើងជិះរថយន្តរបស់បរិស័ទអាកាសយានថៃ បណ្ដាប់ឲ្យនាំសំដៅទៅកាន់វត្តតិសប្លធុតារាម (ថានង-វ៉ង់ឌិត)ទាំងកណ្ដាលអធ្រាត្រស្ងាត់ ៗ ភិក្ខុសង្ឃក្នុងវត្ត ដែលសិងលក់ហើយក៏ភ្ញាក់ឡើងឈូឆរអ៊ូអរទទួលយើងមានសម្ដេចជាប្រធាន ហើយសំណេះសំណាលប្រាស្រ័យដកបដល់ជិតផុតរាត្រីកាល ទើបបែកចាកគ្នាទៅកាន់ទីកន្លែងរៀងខ្លួន ។

## ថ្ងៃអាទិត្យ ១២ រោច ខែវិសាខ (៣០ ឧសភា)

វេលាព្រឹក, អាត្មានឹងអ្នកមហាញូង-ជាឆបានទៅឯស្ថានទូតខ្មែរ ដើម្បីសុំឲ្យវាយទូរលេខមកប្រទេសខ្មែរ ។ ឯកឧត្តម ឌី.ភិមស្ល បានជ្រាបដំណឹងហើយ ក៏នាំគ្នាមកធ្វើគារវពន្ធថ្វាយបង្គំសម្ដេចឯវត្តតិសប្លធុតារាមព្រមទាំងពុទ្ធបរិស័ទខ្មែរ-ថៃខ្លះ ដែលទើបបានទទួលដំណឹងដូចគ្នា ៗ ក្នុងថ្ងៃនេះ ពុំមានការអ្វីប្លែកនឹងពណ៌នាទេ ។

## ថ្ងៃចន្ទ ១៤ រោច ខែវិសាខ (៣១ ឧសភា)

ម៉ោង ៩ ព្រឹក ព្រះសីលក្ខន្ធ សោភិត រាជាគណៈជាតិថៃ ចៅអធិការវត្តព្រះពិរេន្ទ្រនឹងនាយ

ប្រាសាណា ស.តាន់សគុណ បានយកថយន្តពីរមកទទួលសម្តេចនីងយើងទាំងអស់គ្នា ទៅកាន់វត្ត សាមដ្យា (សាមពញា) ដែលនៅឆ្ងាយពីវត្តតិស្សធុតារាមប្រមាណ ៤គ.ម. ដែលជាទីអប់រំភិក្ខុសង្ឃថេរក្នុងព្រះពុទ្ធសាសនាចក្រប្រៀនរាល់ឆ្នាំ ។ ទីប្រជុំក្នុងវត្តនោះជារោងមួយ យ៉ាងធំទូលំទូលាយ មានដំបូលប្រក់ក្បឿងសំយោគ តាមចុះ ឥតមានជញ្ជាំង មានកង្ហារនីងភ្លើងអគ្គិសនី ការពារងឹតនីងកំដៅ ។ ពេលនោះជាវេលាកំពុងប្រជុំអប់រំ, មានព្រះថេរានុត្ថេរៈ ដែលមកពីគ្រប់ខេត្តស្រុកចំនួន ៧៥៦រូប ត្រូវមកនៅសំណាក់អាស្រ័យនៅវត្តនានា ក្នុងក្រុងចំនួន ២១ ថ្ងៃ ។ ភិក្ខុមួយរូប ៗ គង់លើកៅអីមួយដែលមានតុសរសេរតូចមួយនៅពីមុខដាច់ដោយឡែកៗ ពីគ្នាជាជួរ ៗ, ផ្ចិតផ្ចង់ស្មារតីស្តាប់ព្រះថេរអ្នកថ្លែងបាឋកថាពង្រីកសំឡេងដោយឧគ្ឃោសនស័ព្ទដែលឈរនៅលើវេទិកាលំអដោយពុទ្ធាសនៈអំពីខាងក្រោយ ។ ពេលនោះយើងបានឃើញព្រះទេពវេទី រាជាគណៈថ្នាក់ទី ៣ ចៅអធិការវត្ត សាមដ្យា ជាមេគណៈក្រុងទេពមហានគរ (បាងកក) កំពុងថ្លែងសេចក្តីអំពីធម៌ដែលអ្នកគ្រប់គ្រងគេអ្នកប្រៀនប្រដៅគេត្រូវមានត្រូវប្រព្រឹត្ត ។ល។

សម្តេចនីងយើងទាំងអស់គ្នា ត្រូវគេនិមន្តឲ្យគង់លើអាសនៈដ៏សមគួរ ហើយក៏ផ្ចិតផ្ចង់ស្តាប់បាឋកថារបស់ព្រះទេពវេទីនោះ ដរាបដល់ម៉ោង ១០ ។

លុះចប់ហើយព្រះ ទេពវេទី ចុះពីលើវេទិកា មកសំដែងសេចក្តីគោរពគួរសមដ៏សណ្ឋារៈចំពោះសម្តេច ។

-សម្តេចបានណែនាំឲ្យស្គាល់ព្រះសង្ឃដែលតាមហែទៅទាំងអស់ ។

–បន្ទាប់មក ព្រះទេពវេទី បានណែនាំឲ្យសង្ឃមហាសន្និបាតឲ្យបានស្គាល់សម្តេច ។

-ព្រះសង្ឃទាំងអស់ក៏ក្រោកឈរប្រណម្យអញ្ជលីចំពោះសម្តេច ។

តាមសេចក្តីនិមន្តរបស់ព្រះទេពវេទី, សម្តេចបានឡើងលើវេទិកា ថ្លែងជាកថាថា :

"ខ្ញុំករុណាបានឮថាមានការអប់រំបែបនេះមកយូរហើយ ប៉ុន្តែរកពេលឱកាសនឹងមកមិនបាន, ទើបតែពេលនេះដែលខ្ញុំករុណាត្រឡប់ពីទឹកដីសន្តិភាពអាមេរិកនាទៅប្រទេសភូមាមកវិញ ក៏ត្រូវចំនឹងពេលមហាសន្និបាតនេះ ក៏ជាលាភដ៏ឧត្តមដែលខ្ញុំករុណាបានមកជួបឃើញ, ខ្ញុំករុណាមានអំណរណាស់ ។ ប្រទេសខ្មែរក៏មានការអប់រំបែបនេះដែរ ក្នុងអនុសំវច្ឆរមហាសន្និបាតដែលត្រូវមានក្នុង ១ ឆ្នាំម្តងរាល់ឆ្នាំ ប៉ុន្តែពុំបានយូរថ្ងៃទេ ។ ខ្ញុំករុណាសង្ឃឹមថា ដោយសារការអប់រំបែបនេះព្រះពុទ្ធសាសនានឹងបានល្អតលាស់ចំរើន ។ល។

នៅទីបំផុតសម្តេចបានប្រសិទ្ធិពរ ដោយគាថា តេ អត្ថលទ្ធា.... ទុក្ខរោគភយា វេរា ។ បេ ។ ជីវសិទ្ធី ភវន្តុ តេ ។

បន្ទាប់មកយើងទៅមើលរោងឆាន់ប្រក់ស្លឹកធំទូលំទូលាយសម្រាប់ ព្រះសង្ឃចំនួន ៧០០ បាយរូបនោះ ។

ឃើញពួកឧបាសក-សិកា កំពុងចាត់ចែងភត្តាហារដោយបច្ច័យនៃរដ្ឋាភិបាលផង នៃអ្នកមានសទ្ធាផង រួបរួមគ្នាធ្វើ ។ គេរៀបតុជាជួរៗ ដែលមានជើងម៉ាព័ទ្ធជុំវិញ សំរាប់ភិក្ខុសង្ឃ ៨ រូបៗ ឆាន់រួម ១ តុៗ ។

នៅទីបំផុត យើងបានដើរមើលទីវត្ត សាមដ្ឋា ហើយក៏ត្រឡប់មកវត្តតិស្សាដុតារាមវិញ ។

ពីម៉ោង ១៧ ទៅម៉ោង ១៩ យើងទាំងអស់គ្នាមានសម្តេចជាប្រធានបានទៅមើលឈាបនដ្ឋាន គឺទីសម្រាប់ធ្វើឈាបនកិច្ច ដែលគេកសាងឡើងតាមរបៀបទំនើបនាំឲ្យអស់ឧសតិច ហើយគ្មានដុំក្លិនអាសោចផង នៅវត្តព្រះពីរេន្ទ្រ នឹងវត្តចក្រវត្តិ ។ សម្តេចបានពេញព្រះហឫទ័យនឹងឈាបនដ្ឋានបែបទំនើបនេះណាស់ មានបំណងចង់ឲ្យកើតនៅទីវត្តឧណ្ណាលោមមួយដែរ ។ មានគេប្រគេនផែនទីការកសាងឈាបនដ្ឋាន ចំពោះសម្តេចៗ បានយកមកផងដែរ ។

បន្ទាប់ពីនោះ សម្តេចនឹងយើងទាំងអស់គ្នាឈៀងចូលទៅវត្តបញ្ចមបពិត្រដែលសម្តេចនឹងអាត្មាបាននៅ-សំណាក់អាស្រ័យកាលទៅប្រទេសភូមាពីឆ្នាំមុនចំនួនពីរបីរាត្រី ដើម្បីសម្តែងសេចក្តីគួរសម ហើយបានប្រគេនអនុស្សាវរណ៍វត្ថុ ចំពោះសម្តេចព្រះព្រះវនរ័ត សង្ឃនាយកប្រទេសថៃ ។

---

## ថ្ងៃអង្គារ ១ កើតខែជេស្ឋ (១ មិថុនា)

ថ្ងៃនេះពុំមានការប្លែកនឹងយកមកថ្លែងទេ

---

## ថ្ងៃពុធ ២កើត ខែជេស្ឋ (២មិថុនា)

ពេលព្រឹកវេលាម៉ោង ១០ លោកប្យាឌិ លេខាធិការទី១នៃស្ថានទូតភូមាប្រចាំប្រទេសថៃ (តំណាងឯកឧត្តមអគ្គរាជទូត ដែលពុំនៅដោយមានធុរៈទៅកាន់ប្រទេសភូមា) បានយករថយន្តមកនិមន្តព្រះសង្ឃគណៈប្រតិភូខ្មែរនឹងលាវទៅទទួលភត្តាហារនៅគេហស្ថានផ្ទាល់របស់លោក សំដែងសេចក្តីគោរពនឹងអំណរ ដែលគណៈប្រតិភូទាំងពីរប្រទេសនេះ បានទៅបំពេញកិច្ចការជ្រោមជ្រែងធ្វើឆដ្ឋសង្គាយនានៅប្រទេសភូមា ។ល។ ទោះបីនៅក្នុងប្រទេសថៃដូច្នេះក៏ដោយ លោកលេខាធិការទី ១ ក៏នៅតែរៀបម្ហូបអាហារជារបៀបភូមាប្រគេនព្រះសង្ឃឆាន់ដែរ សឲ្យឃើញថាគេប្រកាន់ប្រពៃណីជាតិជាប់ជានិច្ច ។

---

## ថ្ងៃព្រហស្បតិ៍ ៣ កើត ខែជេស្ឋ (៣ មិថុនា)

ព្រះតេជគុណចៅអធិការនាមឥន្ទ វត្តតិស្សាឧការាម (ចាងក៉ាងមិត) ដោយចង់សម្ដែងសេចក្ដីគោរពនឹងបដិសណ្ឋារៈដ៏ខ្ពង់ខ្ពស់ចំពោះគណៈប្រតិភូមានសម្ដេចជាប្រធាន ក៏ផ្ដើមធ្វើជាពិធីបុណ្យជាខ្សោរិកប្រគេនភត្តាហារចំពោះយើងទាំងអស់គ្នា នឹងព្រះសង្ឃខ្មែរ ដែលនៅប្រទេសថៃរួមទាំងអស់ប្រមាណ ១០០ រូប ។ នៅវេលារសៀលម៉ោង ១៤ នឹង ៤៥ នាទី ដោយសេចក្ដីអារាធនា សម្ដេចបានសម្ដែងធម៌ទេសនាជាភាសាខ្មែរអំពីពិធីសង្គាយនានៅប្រទេសភូមា នឹងអំពីនាយកធម៌ជាដើម តាមគួរដល់វេលា ។

តាំងអំពីសម្ដេចចេញចាកប្រទេសភូមា នឹងមកឈប់សំនៅក្រុងបាងកកចំនួន ៥ ថ្ងៃនេះ សម្ដេចតែងទទួលបដិ-សណ្ឋារៈចំពោះភ្ញៀវទាំងសង្ឃទាំងគ្រហស្ថដែលមកគោរពថ្វាយបង្គំពេញៗកុដិទាំងពេលថ្ងៃ ពេលយប់ជាប់ជានិច្ច ។

---

## ថ្ងៃសុក្រ ៤ កើត ខែជេស្ឋ ( ៤ មិថុនា)

ថ្ងៃនេះយើងត្រូវចេញចាកក្រុងបាងកក មកកាន់ប្រទេសកម្ពុជាវិញ ។

វេលាម៉ោង ៦ ព្រឹក យើងធ្វើបាតកសកិច្ចនៅវត្ត តិស្សាឧការាម ហើយស្រេច គណៈប្រតិភូនឹងព្រះសង្ឃ ព្រមទាំងឧបាសកឧបាសិកា ខ្មែរ-ថៃ ដែលមកជូនដំណើរទាំងប៉ុន្មានឡើងរថយន្តចេញពីវត្ត តិស្សាឧ-ការាមឆ្ពោះមកកាន់អាកាសយានដ្ឋានដងមឿង ដោយមានបុគ្គលិកស្ថានទូតខ្មែរ មានឯកឧត្ដមធី-គីមសួ អគ្គរាជទូតជាប្រធាន ព្រមទាំងព្រះសង្ឃ នឹងឧបាសកឧបាសិកាជាតិខ្មែរ-ថៃ ជាច្រើនជូនដំណើរមកផង ។ ម៉ោង ៨ នឹង ៣០ នាទី (ថៃ) ម៉ោង ៩ នឹង ៣០ នាទី (កម្ពុជា) អាកាសយានថៃ បាននាំយើងទាំងអស់គ្នាចេញពីស្ថានីយដងមឿងឆ្ពោះតាមអាកាសមាគ៌ាមកដល់ស្ថានីយអាកាសយានពោធិ៍ចិនតុងនៅវេលាម៉ោង ១១ នឹង ៣០ នាទី ដោយសុវត្ថិភាព ។ (ការរៀបទទួលសម្ដេចព្រះមហាសុមេធាធិបតី នៅនាស្ថានីយអា-កាសយានពោធិ៍ចិនតុង ដូចមានរៀបរាប់នៅទស្សនាវដ្ដី សមាគមមិត្រសាលាបាលីលេខ ៥ ទំព័រ ១៤ ស្រាប់ ។

មហា ប៊ិន-ហោ៊ី សួរបញ្ជាក់តទៅទៀតថា.- បាទ, ចុះព្រះភិក្ខុសង្ឃដែលនិមន្តពីប្រទេសផ្សេងៗមកប្រជុំក្នុងមហាសន្និបាតឆដ្ឋសង្គាយនានោះ មានស្បង់ចីពរនឹងរបៀបស្លៀកដណ្ដប់ឃ្លុំគ្រងដូចគ្នាទាំងអស់ ឬក៏មានផ្សេងពីគ្នាខ្លះដែរ?

ព្រះគ្រូសង្ឃសត្ថាតបថា:- ទាំងភិក្ខុទាំងសាមណេរមានការឃ្លុំ-គ្រងដូចៗគ្នា, ក្រៅពីការចូលក្នុងភូមិស្រុក,

ដណ្ដាប់ចីពរបែបដូចគ្នានឹងលោកសង្ឃក្នុងប្រទេសខ្មែរដែរ ។ ស្បង់-ចីពរ-សង្ឃាដី សុទ្ធតែដេរថ្នេរមូលដូចៗគ្នា មិនឃើញមានស្បង់ចីពរដេរប្រក់ទេ, ឃើញប្រើសុទ្ធតែចីវរបញ្ចខណ្ឌ មានផ្ទាំង៥ មានកន្ទៀង១០ដូចៗគ្នា ។ ត្រៃចីវររបស់អ្នកបួសនៅប្រទេសភូមា សុទ្ធតែជ្រលក់ក្រាក់ខ្មុកខ្ទឹមស្វិះ អាត្មាដឹងពុំសព្វគ្រប់ ពីព្រោះអាត្មាបានសួរគេប្រាប់ថាត្រៃចីវរនៅប្រទេសភូមា សុទ្ធតែឧបាសកអ្នកដេរសម្រាប់ជាវ គេដេរដាក់គណ្ដុំហើយស្រេច រួចគេជ្រលក់ឲ្យមានពណ៌គួរដល់ការប្រើបានតែម្ដង, ដល់ប្រើទៅ បើត្រូវការគក់លាង គ្រាន់តែលាងដោយទឹកក្ដៅឲ្យតែជ្រះក្អែលប៉ុណ្ណោះ, លាងទឹកក្ដៅទៅ មិនចេញ មិនហើរពណ៌សម្បុរទេ, បើត្រូវការជ្រលក់ថែមទៀត មានឧបាសកគេសុំយកទៅជួលជាងជ្រលក់ឲ្យ ជ្រលក់រួចហើយគេយកមកប្រគេនលោកវិញ, លោកសង្ឃនៅប្រទេសភូមាមិនសូវមានការព្រួយពីរឿងជ្រលក់ចីវរទេ ។ អំពីទឹកជ្រលក់នោះ គេប្រាប់ថា គេមិនដឹងដែរ ពីព្រោះសួរជាងជ្រលក់ៗគេលាក់គេមិនព្រមប្រាប់ ។ ជាងជ្រលក់ទាំងឡាយនោះសុទ្ធតែបានរៀនវិធីជ្រលក់ពីប្រទេសក្រៅ សុទ្ធតែមានសិទ្ធិផ្ដាច់មុខរបស់គេ ។ សម្ដេចខំទទូចសួរពីវិធីជ្រលក់ចីវរនេះណាស់ ប៉ុន្តែសួរពុំបានការ, ព្រោះសម្ដេចពេញព្រះទ័យនឹងពណ៌ចីវរភូមាណាស់ ដ្បិតសម្ដេចបានសង្កេតឃើញថា ពណ៌ចីវរភូមាច្រើនសមនឹងព្រះវិន័យ គួរតែយកតម្រាប់តាម ។ ដោយសម្ដេចពេញព្រះទ័យយ៉ាងនេះ បានជាតាំងពីយូរឆ្នាំណាស់ហើយ ដរាបមកដល់សព្វថ្ងៃនេះឃើញសម្ដេចប្រើតែចីវរជ្រលក់ខ្ទឹមខ្មុកជានិច្ច, គួរណាស់តែព្រះសង្ឃខ្មែរត្រិះរិះហើយយកតម្រាប់តាម ។

អាត្មាសុំបញ្ចប់សម្ភាសន៍ត្រឹមប៉ុណ្ណោះ ។ សូមប្រតិស្ឋអធិស្ឋានកុសលពលីដែលគណៈប្រតិភូខ្មែរបានទៅរួបរួមធ្វើពិធីឆដ្ឋសង្គាយនាជាដើម ដូចបានរៀបរាប់មកនេះ ដែលរាប់ថាជាបុណ្យវិសេសឧត្ដុង្គឧត្ដម កម្រកើតមានក្នុងព្រះ-ពុទ្ធសាសនា ព្រោះក្នុងរយៈកាល ២៥ សតវត្សនៃពុទ្ធសករាជ មានត្រឹមតែប្រាំមួយលើកនឹងគ្រានេះប៉ុណ្ណោះ, សូមលើកកុសលពលីនេះឲ្យជាព្រះរាជកុសលដ៏ពិសេសថ្វាយចំពោះព្រះប្រិយមហាវីរៈក្សត្រ ព្រះករុណាព្រះបាទ **សម្ដេចព្រះនរោត្តម សីហនុ វរ្ម័ន** ជាអម្ចាស់ជីវិត ព្រមទាំងព្រះរាជវង្សានុវង្ស នឹងព្រះរាជរដ្ឋាភិបាលដែលបានចាត់គណៈប្រតិភូខ្មែរឲ្យទៅកាន់មហាសន្និបាតនោះ ជាតំណាងប្រទេសខ្មែរ, ទាំងអស់លោក-អ្នកជាពុទ្ធបរិស័ទបព្វជិតគ្រហស្ថ ក្នុងសកលកម្ពុជរដ្ឋ មានលោកអ្នកអានសម្ភាសន៍នេះជាដើម, សូមបានប្រកបជួបប្រទះតែនឹងសេចក្ដីសុខ-ចំរើនសមតាមព្រះរាជបំណងនឹងបំណងប្រាថ្នា ចាប់តាំងពីពេលនេះអស់កាលជាអង្វែងតទៅ ! សូមឲ្យកម្ពុជ-រដ្ឋជាប្រទេសប្រតិស្ឋានព្រះពុទ្ធសាសនា ឋិតនៅក្នុងសុខភាព-វឌ្ឍនភាព នឹងសីលធម៌ ជានិច្ចនិរន្តរ៍តរៀងទៅ !

—*ចប់*—



ព្រះចេតិយ ព្រះចៅមិងដុង ដែលមានព្រះចេតិយតូចៗ ព័ទ្ធជុំវិញចំនួន ៧២៩ តម្កល់ផ្ទាំងថ្មកែវ ៧២៩ ផ្ទាំងចារិកបាលីព្រះត្រៃបិដកមួយចប់ ក្នុងគ្រាបាត់បែងធ្វើបញ្ចមសង្គាយនា នៅក្រុងមណ្ឌលេ ដ៏ប្រដាប់ដោយព្រះចេតិយជាបូជនីយស្ថានចាប់តាំងពីជើងភ្នំ រហូតដល់កំពូលភ្នំ

(ផ្ទាំងថ្មកែវនឹងអក្សរដែលចារិក នៅល្អគ្មានបាក់បែករហូតដល់សព្វថ្ងៃ)

---

អ្នកទទួលឲ្យជាវ

សូមផ្ញើចំពោះទៅលោកម៉ៅ-ម៉ី ធ្វើការនៅក្រសួងមហាផ្ទៃ ក្រុងភ្នំពេញ ។

**adresse :** *Monsieur* **Mao-Mey** *Ministère de l'intérieur P. Penh*